# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ៩



វត្តនិគ្រោធវ័ន "គល់ទទឹង"

# អភិធម្មត្ថសង្គហៈ

# បរិច្ឆេទទី ៩

វត្តនិគ្រោធវ័ន “គល់ទទឹង”

រៀបរៀងដោយ **ភិក្ខុ អគ្គធីរោ គង់ សុមិត្ត**

ព.ស. ២៥៥៥

# សម្ដែងព្រះអភិធម្ម នៅឋានតាវត្តិង្ស

កាលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ចាំព្រះវស្សាទី៧ នៅឋានតាវត្តិង្សទេវលោក ក្នុងគ្រាដែលបានសំដែងយមកបាដិហារ្យផ្ចាញ់ពួកតិរ្ថិយរួចហើយ បានគង់លើសិលាសនៈ ឈ្មោះបណ្ឌុកម្ពល ក្រោមដើមបារិឆត្ត ទ្រង់ព្រះសិរីសោភា ដូចព្រះអាទិត្យឧទ័យឡើងលើភ្នំយុគន្ធរ ដែលពួកនៃទេវតាទាំងឡាយក្នុងមុឺនចក្រវាឡបានមកប្រជុំគ្នា ហែហមសម្ដេចព្រះបរមសាស្ដាចារ្យ ទ្រង់ធ្វើសន្តុសិតទេវបុត្រដែលធ្លាប់ជាពុទ្ធមាតា ឱ្យជាប្រធាននៃពួកទេវតាទាំងឡាយ ហើយត្រាស់កថាមគ្គព្រះអភិធម្មថា "**កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា**"ជាដើម ទ្រង់សម្ដែងដោយន័យនេះ ជាប់តរហូតអស់មួយព្រះវស្សា ដោយតេជៈនៃព្រះសព្វញ្ញុតញ្ញាណនោះ ។ ក៏កាលដែលទ្រង់សម្ដែងធម៌នោះ ក្នុងវេលាភិក្ខាចារទ្រង់និម្មិតព្រះពុទ្ធនិមិត្តដោយទ្រង់អធិដ្ឋានថា "ព្រះពុទ្ធនិមិត្ត

នេះ ចូរសម្តែងធម៌ ឈ្មោះប៉ុណ្ណោះ ដរាបដល់តថាគតមក” ហើយក៏ស្តេចយាងទៅព្រៃហេមពាន្ត ទ្រង់ទំពាឈើស្ទន់ ឈ្មោះនាគលតា ខ្ពុរព្រះឱស្ឋក្នុងស្រះអនោតត្ត នាំបិណ្ឌបាត អំពីឧត្តរកុរុទ្វីប បានធ្វើភត្តកិច្ចក្នុងរោងធំទូលាយហើយ ។ ព្រះសារីបុត្រទៅធ្វើវត្តចំពោះព្រះសាស្តាក្នុងទីនោះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ជាទេវតារបស់ទេវតា ជាអ្នកនាំវិសេសអង្គនោះ កាលទ្រង់សំដែងអភិធម្មណា ដល់ទេវតាទាំងឡាយហើយ ក៏បានត្រាស់ប្រាប់ដល់ព្រះសារីបុត្តត្ថេរ អ្នកឧបដ្ឋាកព្រះមហេសីជាម្ចាស់ ក្នុងអនោតត្តស្រះ ដោយន័យ (សង្ខេប) ទៀតថា “ម្នាលសារីបុត្រ ថ្ងៃនេះតថាគតបាន សម្តែងធម៌ឈ្មោះប៉ុណ្ណោះ អ្នកចូរប្រាប់ដល់(ភិក្ខុ ៥០០) ជាកូនសិស្សរបស់អ្នក” ព្រះថេរៈបានស្តាប់ហើយ ក៏បាន និមន្តមកកាន់លំនៅឋាន ហើយប្រាប់ដល់ភិក្ខុទាំងឡាយ, ព្រះអភិធម្មនោះ ដែលភិក្ខុទាំងឡាយបានទ្រទ្រង់ចាំទុកហើយ ដោយប្រការយ៉ាងនេះ ។

# ជីវប្រវត្តិសង្ខេប

ភិក្ខុ **គង់-សុមិត្ត** គង់នៅពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន គល់ទទឹង

ញោមប្រុស ឈ្មោះ គង់-តិក(ស្លាប់) ញោមស្រី ឈ្មោះ ហុក-តាង រស់នៅក្នុងភូមិខ្វិត ឃុំព្រែកខ្ពប ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

កើតនៅថ្ងៃព្រហស្បតិ៍ ៩ កើត ខែមិគសិរ ឆ្នាំ ថោះ ព.ស. ២៥១៩ - គ.ស. ១៩៧៦ ។ មានបងប្អូន ៧ នាក់ គឺ ប្រុស ៥ នាក់ ស្រី ២ នាក់. ជាកូនពៅ

ក្នុងកុមារ បានចូលរៀនសាលារដ្ឋ (ក្តាំងឆា និង ព្រែកហ្លួង)ដល់ថ្នាក់ទី ៨ ។

ក្នុងព.ស.២៥៣៧ មានអាយុ១៩ឆ្នាំ បួសជាសាមណេរ ក្នុងសំណាក់ឧបជ្ឈាយ៍ ព្រះនាម ឡូយ-លឿង វត្តស្លាកែត មកគង់នៅវត្តក្តាំងឆា ខេត្តបាត់ដំបង ។

ព.ស. ២៥៣៨ មានអាយុគ្រប់ ២០ បានឧបសម្បទាជាភិក្ខុភាវៈ ។ ព.ស. ២៥៣៩ មកគង់នៅវត្តសមសាន្ត (ខេត្តបាត់ដំបង) រៀនវិន័យ-អភិធម្ម ។ ព.ស. ២៥៤០ មកនៅវត្តនិគ្រោធវ័ន ខេត្តកណ្ដាល រៀនធម៌វិន័យបន្ត ។ ព.ស. ២៥៤១ ចេញទៅគង់នៅវត្តខេមវ័ន (ខេត្តកំបាម) បង្រៀនធម៌វិន័យ ។ ព.ស. ២៥៤៥ បានត្រឡប់មកវត្តនិគ្រោធវ័នវិញហើយលាសិក្ខា បានខិតខំ រៀបចំ និងជួយសរសេរសៀវភៅធម៌-វិន័យ ។ ព.ស. ២៥៤៦ បានបួសជាសាមណេរវិញទៀត ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ ព្រះនាម យី-ទិត វត្តកោះក្របី ឃុំព្រែកថ្មី ស្រុកគៀនស្វាយ ខេត្តកណ្ដាល បានជួយបង្រៀនព្រះវិន័យដល់ព្រះសង្ឃ ក្នុងវត្តនិគ្រោធវ័ន ។ ព.ស. ២៥៤៧ បានឧបសម្បទាជាភិក្ខុ បានបង្រៀនព្រះវិន័យដល់ព្រះសង្ឃ បង្រៀនអភិធម្មដល់ដូនជី ក្នុងវត្តនិគ្រោធវ័ន និងខិតខំរៀបចំសៀវភៅធម៌-វិន័យរហូតមក ។

# អភិធម្មត្ថសង្គហកថា

គម្ពីរអភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ព្រះអនុរុទ្ធាចារ្យ បានចងក្រងឡើង ។

អភិធម្មត្ថសង្គហៈ មាន ៩ បរិច្ឆេទ គឺ

បរិច្ឆេទទី១ ចិត្តសង្គហវិភាគ ការសម្តែងសង្គ្រោះនិងចែកចិត្ត ៨៩ ឬ១២១

បរិច្ឆេទទី២ ចេតសិកសង្គហវិភាគ ការសម្តែងសង្គ្រោះនិងចែកចេតសិក ៥២

បរិច្ឆេទទី៣ បកិណ្ណកសង្គហៈ ការសម្តែងសង្គ្រោះនិងចែកបកិណ្ណក ៦ ពួក

បរិច្ឆេទទី៤ វិថីសង្គហវិភាគ ការសម្តែងសង្គ្រោះនិងចែកវិថីចិត្ត

បរិច្ឆេទទី៥ វិថីវិមុត្តសង្គហវិភាគ ការសម្តែងសង្គ្រោះនិងចែកវិថីវិមុត្ត

បរិច្ឆេទទី៦ រូបសង្គហវិភាគ-និព្វានបរមត្ថ ការសម្តែងសង្គ្រោះ
និងចែករូបនិងនិព្វាន

បរិច្ឆេទទី៧ សមុច្ចយសង្គហវិភាគ ការសម្តែងសង្គ្រោះនិង
ចែកពួកធម៌ជាក្រុម ៗ

បរិច្ឆេទទី៨ បច្ចយសង្គហវិភាគ ការសម្តែងសង្គ្រោះនិង
ចែកបច្ច័យ១២ និង២៤

បរិច្ឆេទទី៩ កម្មដ្ឋានវិភាគ ការសម្តែងចែកកម្មដ្ឋាន
៤០ និងវិបស្សនា ។

សៀវភៅអភិធម្មនេះ ព្រះអនុរុទ្ធាចារ្យបានប្រមូលចង ក្រងអំពីបិដក និងអដ្ឋកថា ហើយបានចែកជាបរិច្ឆេទតាម ប្រភេទនៃបរមត្ថធម៌ ដើម្បីងាយស្រួលក្នុងការសិក្សា គឺ បរិច្ឆេទទី១ សម្តែងចិត្តបរមត្ថ, បរិច្ឆេទទី២ សម្តែងចេតសិក បរមត្ថ, បរិច្ឆេទទី៣, ៤, ៥ សម្តែងចិត្តបរមត្ថ និងចេតសិក បរមត្ថរួមគ្នា, បរិច្ឆេទទី ៦ សម្តែងរូបបរមត្ថ, និងនិព្វាន បរមត្ថ, បរិច្ឆេទទី៧, ៨, ៩ សម្តែងបរមត្ថទាំង ៤ រួមគ្នា ។

# បុព្វកថា

សៀវភៅអភិធម្មនេះ ខ្ញុំបានសរសេរក្នុងព.ស. ២៥៤៥ ចប់នៅក្នុងព.ស. ២៥៤៧ ។ ព.ស. ២៥៥២ បានរៀបចំជាសៀវភៅធំ ឈ្មោះថា អភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ។ ព.ស. ២៥៥៥ ដោយសេចក្តីត្រូវរបស់អ្នកសិក្សា ក៏បានចែកតាមបរិច្ឆេទនីមួយ ៗវិញ ដើម្បីងាយកាន់សិក្សា ។

ការរៀបចំសៀវភៅអភិធម្មត្ថសង្គហៈនេះ បានចប់សព្វគ្រប់ ហើយ បើមានពាក្យឬសេចក្តីណានៅខុស ក៏សូមអភ័យទោស និងសូមមេត្តាកែ សម្រួលផងចុះ ។

គម្ពីរព្រះអភិធម្ម ជាគម្ពីរដែលសម្តែងឡើងនូវធម៌ពិត គឺ សច្ចធម៌ បរមត្ថធម៌ និងបង្ហាញនូវផ្លូវបដិបត្តិឆ្ពោះទៅរកទីរំលត់ទុក្ខ គឺ ព្រះនិព្វាន ។ សត្វលោកដែលកើតមកសុទ្ធតែមានអវិជ្ជា និងតណ្ហាគ្រប់គ្នា មានតែព្រះពុទ្ធនិងព្រះបច្ចេកពុទ្ធទេ ដែលអាចត្រាស់ដឹងនូវធម៌ពិត កម្ចាត់អវិជ្ជាបានដោយខ្លួនព្រះអង្គឯង ក្រៅពីនោះ ត្រូវតែអាស្រ័យ

ព្រះពុទ្ធ ដែលទ្រង់មានព្រះទ័យមហាករុណាសម្តែងប្រាប់ ទើបអាចយល់ដឹងស្គាល់ធម៌ពិត និងបានឃើញផ្លូវបដិបត្តិដល់ព្រះនិព្វានជាទីរំលត់ទុក្ខបាន ។

កាលបើពុទ្ធបរិស័ទទាំងអស់ សិក្សានូវព្រះអភិធម្មបានយល់ដឹងហើយ បញ្ញាក៏កើតឡើង បានឃើញនូវសភាវធម៌ពិតទាំងដែលយើងសព្វថ្ងៃបានជួប បានទាន់ព្រះធម៌កំពុងឋិតនៅសម្រាប់ក្រេបជញ្ជក់ធម្មរស ហើយធ្វើឱ្យយើងមានសម្រស់ក្នុងជីវិត មិនឋិតនៅក្នុងភាពស្ងិតស្រពោន និងសម្រេចមគ្គផលតាមឧបនិស្ស័យដែលយើងបានសន្សំមក, ព្រោះហេតុដូច្នេះទើបខ្ញុំព្យាយាមរៀបចំសៀវភៅនេះឡើង ។ ម្យ៉ាងទៀត សៀវភៅនេះ ក៏ដូចជាសាវ័កមួយអង្គដែលឈ្លាសវៃនាំយកព្រះពុទ្ធដីកាមកប្រាប់ ហើយពន្យល់សេចក្តីនោះ ឱ្យយើងបានយល់ដឹងឬចាត់ថា ជាគ្រូក៏បាន ។

ការរៀបចំសៀវភៅធម៌នេះ ជាបុណ្យកុសលមួយ

យ៉ាងល្អប្រសើរ ដែលខ្ញុំព្រះករុណា អាត្មាភាព និងពុទ្ធបរិស័ទទាំងឡាយ បានរួបរួមសាមគ្គីជួយឧបត្ថម្ភ ដោយកម្លាំងកាយចិត្ត និងថវិកា ជាចេតនាមហាកុសលថ្នាក់ធម្មទាន និងធម្មបូជា យ៉ាងពេញចិត្តគ្រប់ ៗគ្នា ។ ដោយអំណាចនៃបុណ្យនេះ នឹងនាំឱ្យបានទទួលនូវសេចក្តីសុខ ជាពិសេស គឺបាននូវបញ្ញាដែលជាពន្លឺញាំងជីវិតឱ្យរុងរឿងគ្រប់ ៗ ជាតិរហូតដល់បានលះបង់នូវមន្ទិលគឺ កិលេស ដែលយើងគ្រប់ ៗ គ្នាចង់បាននូវ ការត្រាស់ដឹងនូវសច្ចធម៌ ឃើញច្បាស់នូវព្រះនិព្វាន ដែលជាទីបំផុតទុក្ខ ។ ម្យ៉ាងទៀត បញ្ញានេះឯង អាចឱ្យសម្រេចតាមសេចក្តីប្រាថ្នានោះបាន ។

ខ្ញុំព្រះករុណាអាត្មាភាព សូមអនុមោទនានូវបុណ្យកុសលរបស់ពុទ្ធបរិស័ទ ទាំងអស់ ដែលបានឧបត្ថម្ភថវិកាជាធម្មទាន និងការខិតខំសិក្សានេះ ។ ម្យ៉ាងទៀត សូមពុទ្ធ

បរិស័ទទាំងអស់ អនុមោទនាយកនូវបុណ្យដែលខ្ញុំព្រះករុណាអាត្មាភាព បានរៀបចំបោះពុម្ពព្រះអភិធម្មនេះផងចុះ ។ សូមឱ្យពុទ្ធបរិស័ទទាំងអស់ មានបញ្ញា ភ្លឺថ្លាមោះមុត ជាគ្រឿងត្រាស់ដឹងនូវសច្ចធម៌ សូមបានសម្រេចនូវសម្បត្តិលោកិយៈ និងលោកុត្តរៈ មានចិត្តល្អបរិសុទ្ធរួចផុតចាកទុក្ខ ដល់ព្រះនិព្វានគ្រប់ ៗ គ្នា កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអនុមោទនា !!!

ថ្ងៃ១៥កើត ខែស្រាព ឆ្នាំថោះ ត្រីស័ក ព.ស.២៥៥៥

# ឯកសារវិគ្រោះ

| អក្សរកាត់ | អក្សរពេញ | ភាគគម្ពីរ |
|---|---|---|
| ទីឃ. មហា. | ទីឃនិកាយ មហាវគ្គ | បិដកភាគ ១៦. ១៧. |
| មជ្ឈិ. មូល. | មជ្ឈិមនិកាយ មូលបណ្ណាសក | បិដកភាគ ២០. ២១. |
| មជ្ឈិ. មជ្ឈិ. | មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក | បិដកភាគ ២៣. |
| មជ្ឈិ. ឧប. | មជ្ឈិមនិកាយ ឧបរិបណ្ណាសក | បិដកភាគ ២៨. |
| សំយុ. និទា. | សំយុត្តនិកាយ និទានវគ្គ | បិដកភាគ ៣២ |
| សំយុ. មហា. | សំយុត្តនិកាយ មហាវារវគ្គ | បិដកភាគ ៣៧. ៣៨. ៣៩. |
| ខុទ្ទ. ធាឋ. | ខុទ្ទកនិកាយ ខុទ្ទកបាឋ | បិដកភាគ ៥២ |
| ខុទ្ទ. បដិ. | ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ | បិដកភាគ ៦៩. ៧០. ៧១. |
| អភិ. សង្គ. | អភិធម្ម ធម្មសង្គណី | បិដកភាគ ៧៨. ៧៩. |
| អភិ. បដ្ឋា. | អភិធម្ម មហាបដ្ឋាន | បិដកភាគ ៩៤. |

អត្ថយោជនា, វិសុទ្ធិមគ្គ, អភិធម្មត្ថសង្គហដីកា,

លេខដែលនៅបន្ទាប់គឺ ខាងដើមជាភាគគម្ពីរ កណ្តាលជាលេខឃ្នាប ខាងចុងជាលេខទំព័រ ឧទាហរណ៍ : ១៧. ១១៦/២៥៤ គឺ បិដកភាគ ១៧ លេខឃ្នាប ១១៦ ទំព័រ ២៥៤ ។

# បញ្ជីមាតិកា អភិធម្មត្ថសង្គហៈ

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


សម្តែងព្រះអភិធម្ម នៅឋានតាវត្តិង្ស ... ... ... ... ... ក

ជីវប្រវត្តិសង្ខេបគ ... ... ... ... ... ... ... ... ... ... ... គ

អភិធម្មត្ថសង្គហកថា ... ... ... ... ... ... ... ... ... ... ... ង

បុព្វកថា ... ... ... ... ... ... ... ... ... ... ... ... ... ... ... ឆ

ឯកសារវិគ្រោះ ... ... ... ... ... ... ... ... ... ... ... ... ... ដ

បញ្ជីមាតិកា ... ... ... ... ... ... ... ... ... ... ... ... ... ... ឋ

**អភិធម្មត្ថសង្គហៈ បរិច្ឆេទទី ៩ កម្មដ្ឋានវិភាគ**

សង្គហគាថាទី១ កម្មដ្ឋាន ២ យ៉ាង ... ... ... ... ... ១

១-សមថកម្មដ្ឋាន ... ... ... ... ... ... ... ... ... ... ... ... ... ២

សមថកម្មដ្ឋាន ៤០ ... ... ... ... ... ... ... ... ... ... ... ... ៣

សប្បាយភេទ ... ... ... ... ... ... ... ... ... ... ... ... ៥

ភាវនាភេទ ... ... ... ... ... ... ... ... ... ... ... ... ... ៧

ន័យនៃកម្មដ្ឋាន ៤០ ... ... ... ... ... ... ... ... ... ... ៨

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ


ប្រភេទនៃអារម្មណ៍ ... ... ... ... ... ... ... ... ... ... ... ... ១២

អធិប្បាយ ចរិតដែលជាមូល ៦ ... ... ... ... ... ... ១៤

កម្មដែលជាបុព្វហេតុ ... ... ... ... ... ... ... ... ... ... ២៣

មើលលក្ខណៈចរិតមនុស្ស ... ... ... ... ... ... ... ... ២៨

សង្គហគាថាទី២ ចរិត ៥ យ៉ាង ... ... ... ... ... ... ២៨

អធិប្បាយ ការនាទិងនិមិត្ត ... ... ... ... ... ... ... ... ៣០

អធិប្បាយពាក្យថា កសិណ ... ... ... ... ... ... ... ៣២

អធិប្បាយ អសុភ ១០ ... ... ... ... ... ... ... ... ... ៣៤

អធិប្បាយ អនុស្សតិ ... ... ... ... ... ... ... ... ... ... ៣៦

អនុស្សតិ មាន ១០ យ៉ាង គឺ ... ... ... ... ... ... ៣៦

អធិប្បាយ អប្បមញ្ញា ៤ ... ... ... ... ... ... ... ... ៣៩

លក្ខណៈអប្បមញ្ញា ៤ ... ... ... ... ... ... ... ... ... ៤២

អធិប្បាយ អាហារេបដិកូលសញ្ញាជាដើម ... ... ... ៤៣

អធិប្បាយ កម្មដ្ឋានដែលសមគួរនឹងចរិត ... ... ... ៥២

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


អធិប្បាយ កម្មដ្ឋានដល់អប្បនា និងមិនដល់ ... ... ៥៤

អធិប្បាយ ន័យនៃនិមិត្ត ៣ ... ... ... ... ... ... ... ៦០

អធិប្បាយ វសី ៥ ... ... ... ... ... ... ... ... ... ៦២

អធិប្បាយរូបជ្ឈានលះអង្គដែលគ្រោតគ្រាតជាដើម ៦៤

កម្មដ្ឋាន ១០ មិនដល់អប្បនា ... ... ... ... ... ... ... ៦៦

អធិប្បាយ អភិញ្ញា ៥ ... ... ... ... ... ... ... ... ៦៧

អធិប្បាយ អារម្មណ៍របស់អភិញ្ញា៥ ដោយសង្ខេប ៧០

អធិប្បាយ សេចក្ដីផ្សេងគ្នានៃអភិញ្ញា ៥ ... ... ... ៧៣

២-វិបស្សនាកម្មដ្ឋាន ... ... ... ... ... ... ... ... ... ... ... ... ... ៧៧

វិបស្សនាញាណ ១០ ... ... ... ... ... ... ... ... ... ... ៧៨

ប្រភេទនៃវិសុទ្ធិ ៧ ... ... ... ... ... ... ... ... ... ... ... ៧៩

សង្គហគាថាទី៣-៤ សរុបវិសុទ្ធិ ៧ ... ... ... ... ... ៨៣

ប្រភេទនៃវិមោក្ខ ... ... ... ... ... ... ... ... ... ... ... ... ៨៤

ប្រភេទនៃបុគ្គល ... ... ... ... ... ... ... ... ... ... ... ៨៦

**មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ**


ប្រភេទនៃសមាបត្តិ ... ... ... ... ... ... ... ... ... ... ... ... ៨៧

សង្គហគាថាទី៥ ... ... ... ... ... ... ... ... ... ... ... ... ... ៨៩

អធិប្បាយ វិបស្សនាកម្មដ្ឋាន ... ... ... ... ... ... ... ... ៩០

អធិប្បាយត្រៃលក្ខណ៍ ... ... ... ... ... ... ... ... ... ... ៩១

អធិប្បាយ វិបស្សនាញាណ ១០ ... ... ... ... ... ... ៩២

អធិប្បាយ មគ្គមានឈ្មោះ ៣ យ៉ាង ... ... ... ... ៩៤

អធិប្បាយ វិសុទ្ធិ ៧ ... ... ... ... ... ... ... ... ... ... ៩៥

អធិប្បាយ សីលវិសុទ្ធិ ... ... ... ... ... ... ... ... ... ៩៥៥

អធិប្បាយ ចិត្តវិសុទ្ធិនិងទិដ្ឋិវិសុទ្ធិ ... ... ... ... ... ... ៩៦

១-លក្ខណាទិចតុក្កៈរបស់ផស្សៈ ... ... ... ... ... ... ៩៨

២-លក្ខណាទិចតុក្កៈរបស់បឋវី ... ... ... ... ... ... ៩៨

៣- លក្ខណាទិចតុក្កៈរបស់នាម ... ... ... ... ... ... ៩៩

៤- លក្ខណាទិចតុក្កៈរបស់រូប ... ... ... ... ... ... ... ៩៩

អធិប្បាយ កង្ខាវិតរណាវិសុទ្ធិ ... ... ... ... ... ... ... ១០០

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ

អធិប្បាយ មគ្គាមគ្គញាណទស្សនវិសុទ្ធិ … … … … ១០២
អធិប្បាយ បដិបទាញាណទស្សនវិសុទ្ធិ … … … … ១១១
អធិប្បាយ ញាណទស្សនវិសុទ្ធិ … … … … … … ១១៤
អធិប្បាយ សង្គហគាថាទី ៣ … … … … … … … ១១៩
អធិប្បាយ អនុបស្សនា ៣ នៃវិមោក្ខមុខ … … … ១២៣
អធិប្បាយ មគ្គ មានឈ្មោះ ៣ យ៉ាង … … … … ១២៥
អធិប្បាយ ប្រភេទបុគ្គលនិងសមាបត្តិ … … … … ១២៨
ប្រភេទសមាបត្តិ … … … … … … … … … … … … ១២៩
អវសានគាថានៃបករណ៍ … … … … … … … … … ១៣២

# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ៩ កម្មដ្ឋានវិភាគ

*នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។*

## សង្គហគាថា

១ សមថវិបស្សនានំ ភាវនានមិតោ បរំ

កម្មដ្ឋានំ បវក្ខាមិ ទុវិធម្បិ យថាក្កមំ ។

*តពីនេះ ខ្ញុំនឹងពោលកម្មដ្ឋាន ២ យ៉ាងនៃសមថភាវនា និងវិបស្សនាភាវនា តាមលំដាប់ដូចតទៅ ។*

*កម្មដ្ឋាន មាន ២ យ៉ាង*

*១_សមថកម្មដ្ឋាន*

*២_វិបស្សនាកម្មដ្ឋាន*

# ១-សមថកម្មដ្ឋាន

បណ្ដាកម្មដ្ឋានទាំង ២ យ៉ាងនោះ បណ្ឌិតគប្បីជ្រាប

**សមថកម្មដ្ឋានសង្គហៈ** ដោយន័យ ៧ យ៉ាង ក្នុងសមថសង្គហៈមុន គឺ ១-កសិណ ១០ យ៉ាង, ២-អសុភៈ ១០ យ៉ាង, ៣-អនុស្សតិ ១០ យ៉ាង, ៤-អប្បមញ្ញា ៤ យ៉ាង, ៥-អាហារេ បដិកូលសញ្ញា ១ យ៉ាង, ៦-ចតុធាតុវវត្ថានៈ ១ យ៉ាង, ៧-អរូបសមាបត្តិ ៤ យ៉ាង ។

**ចរិតសង្គហៈ** ៦ គឺ ១-រាគចរិត ២-ទោសចរិត ៣-មោហចរិត ៤- វិតក្កចរិត ៥-សទ្ធាចរិត ៦-ពុទ្ធិចរិត

**ភាវនា** ៣ យ៉ាង : ១.បរិកម្មភាវនា ២.ឧបចារភាវនា ៣.អប្បនាភាវនា

**និមិត្ត** មាន ៣ យ៉ាង : ១.បរិកម្មនិមិត្ត ២.ឧគ្គហនិមិត្ត ៣.បដិភាគនិមិត្ត

# សមថកម្មដ្ឋាន ៤០

គប្បីជ្រាបយ៉ាងណា ?

គប្បីជ្រាបយ៉ាងនេះថា ៖

កសិណវត្ថុទាំង ១០ យ៉ាង នេះ គឺ បឋវីកសិណ ១ អាបោកសិណ ១ តេជោកសិណ ១ វាយោកសិណ ១ នីលកសិណ ១ បីតកសិណ ១ លោហិតកសិណ ១ ឱទាតកសិណ ១ អាកាសកសិណ ១ អាលោកកសិណ ១ ។ នេះឈ្មោះថា កសិណ ១០ យ៉ាង ។

**សាកសព ១០ យ៉ាងនោះ គឺ ៖**

**១- ឧទ្ធុមាតកៈ** សាកសពហើមប៉ោង

**២- នីលកៈ** សាកសពមានពណ៌ខៀវ

**៣- វិបុព្វកៈ** សាកសពមានខ្ទុះហូរចេញ

**៤- វិច្ឆិទ្ទកៈ** សាកសពដែលកាត់ដាច់ពាក់កណ្តាល

៥. **វិក្ខាយិតកៈ** សាកសពដែលមានសត្វខាំកកេរស៊ី

៦. **វិក្ខិត្តកៈ** សាកសពដែលមានដៃនិងជើងដាច់ខ្ចាត់ខ្ចាយ

៧. **ហតវិក្ខិត្តក** សាកសពដែលកាប់សាច់ចិញ្ច្រាំចោលរាត់រាយ

៨. **លោហិតកៈ** សាកសពដែលមានឈាមហូរប្រឡាក់

៩. **បុឡុវកៈ** សាកសពដែលមានដង្កូវចោះច្រើន

១០. **អដ្ឋិកៈ** សាកសពដែលជារាងឆ្អឹង

នេះឈ្មោះថា អសុភៈ ១០ យ៉ាង ។

អនុស្សតិ ១០ យ៉ាង : ១.ពុទ្ធានុស្សតិ ២.ធម្មានុស្សតិ ៣.សង្ឃានុស្សតិ ៤.សីលានុស្សតិ ៥.ចាគានុស្សតិ ៦.ទេវានុស្សតិ ៧.ឧបសមានុស្សតិ ៨.មរណានុស្សតិ ៩.កាយគតាសតិ ១០.អានាបានស្សតិ ។

**អប្បមញ្ញា ៤** : ភាវនាទាំង ៤ នេះ គឺ មេត្តា ១ ករុណា ១ មុទិតា ១ ឧបេក្ខា ១ នេះឈ្មោះថា អប្បមញ្ញា ៤ និងហៅថា ព្រហ្មវិហារធម៌ ៤ ក៏បាន ។

**សញ្ញា ១** : អាហារេបដិកូលសញ្ញា នេះឈ្មោះថា សញ្ញា ។

**វវត្ថាន: ១** : ចតុធាតុវវត្ថាន: គឺ ការកំណត់ធាតុ ៤ នេះឈ្មោះថា វវត្ថាន:

**អរូបសមាបត្តិ ៤** : អាកាសានញ្ចាយតន: ១ វិញ្ញាណញ្ចាយតន: ១ អាកិញ្ចញ្ញាយតន: ១ និង នេវសញ្ញានាសញ្ញាយតន: ១ នេះឈ្មោះថា អរូប ៤ ។

ក្នុងសមថនិទ្ទេស រួមជាកម្មដ្ឋាន ៤០ យ៉ាង ដោយប្រការទាំងពួង ដូច្នេះឯង ។

## សប្បាយភេទ

សមថកម្មដ្ឋាន ៤០ មានសប្បាយផ្សេងគ្នា ក៏ក្នុងចរិតទាំងឡាយ គឺ ៖

+ អសុភ ១០ និងកោដ្ឋាសភាវនា ពោលគឺ កាយគតាសតិ ១ ជាសប្បាយដល់មនុស្សរាគចរិត ។

\+ អប្បមញ្ញា ៤ និងវណ្ណកសិណ ៤ មាននីលកសិណជាដើម ជាសប្បាយដល់មនុស្សទោសចរិត ។

\+ អានាបានសតិ ១ ជាសប្បាយដល់មនុស្សមោហចរិត និងមនុស្សមានវិតក្កចរិត ។

\+ អនុស្សតិ ៦ មានពុទ្ធានុស្សតិជាដើម ជាសប្បាយដល់មនុស្សសទ្ធាចរិត ។

\+ មរណានុស្សតិ ១ ឧបសមានុស្សតិ ១ អាហារេបដិកូលសញ្ញា ១ និង ចតុធាតុវវត្ថានៈ ១ ជាសប្បាយដល់មនុស្សពុទ្ធិចរិត ។

ចំណែកកម្មដ្ឋានទាំងអស់ ដែលនៅសល់ ជាសប្បាយដល់មនុស្សមានចរិតគ្រប់យ៉ាង ។

** បណ្ដាកសិណ( វត្ថុ )ទាំងនោះ កសិណមានវង្វង់ធំទូលាយ ជាសប្បាយដល់មនុស្សមោហចរិត ។ កសិណវង្វង់តូច ជាសប្បាយដល់មនុស្សវិតក្កចរិត ។

នេះជាប្រភេទនៃសប្បាយ ក្នុងអធិការពោលអំពីចរិតនុ៎ះឯង ។

## ភាវនាភេទ

ក៏ក្នុងភាវនាទាំង ៣. បរិកម្មភាវនា រមែងមាននៅក្នុងកម្មដ្ឋានទាំងពួងតែម្តង. ឧបចារភាវនា រមែងសម្រេចនៅក្នុងកម្មដ្ឋាន ១០ គឺ អនុស្សតិ ៨ ខាងដើម មានពុទ្ធានុស្សតិជាដើម អាហារេបដិកូលសញ្ញា ១ និងចតុធាតុវវត្ថានៈ ១ មិនមានអប្បនា ។

ចំណែកក្នុងកម្មដ្ឋាននៅសល់ ៣០ រមែងសម្រេចបានទាំងឧបចារភាវនា និងអប្បនាភាវនា ។

ក្នុងកម្មដ្ឋានទាំង៣០នោះ មានរូបាវចរឈាន២៦ គឺ ៖

១- កសិណ ១០ យ៉ាង បានសម្រេចដល់បញ្ចមជ្ឈាន

២- អានាបានៈ ១ យ៉ាង បានសម្រេចដល់បញ្ចមជ្ឈាន

៣- អសុភៈ ១០ យ៉ាង បានសម្រេចដល់បឋមជ្ឈាន

៤- កាយគតាសតិ ១ យ៉ាង បានសម្រេចដល់បឋមជ្ឈាន
៥- អប្បមញ្ញា ៣ យ៉ាង បានសម្រេចដល់ចតុត្ថជ្ឈាន
៦- ឧបេក្ខា ១ យ៉ាង បានសម្រេចដល់បញ្ចមជ្ឈាន

ចំណែកអរូបាវចរឈាន ៤ បានសម្រេចដល់អរូបជ្ឈាន ៤ ទុំះឯង

នេះជាប្រភេទនៃភាវនាក្នុងកម្មដ្ឋាន ៤០ ។

## ន័យនៃកម្មដ្ឋាន ៤០

ក្នុងនិមិត្តទាំងឡាយ បរិកម្មនិមិត្ត និងឧគ្គហនិមិត្ត រមែងមាននៅក្នុងកម្មដ្ឋានគ្រប់យ៉ាងតែម្តង ដោយបរិយាយតាមសមគួរ ។ ចំណែកបដិភាគនិមិត្ត បានចំពោះក្នុងកសិណ ១០ អសុភ ១០ កាយគតាសតិ ១ និងអានាបានស្សតិ ១ ប៉ុណ្ណោះ ។

ពិតមែន ឧបចារសមាធិ និងអប្បនាសមាធិ ប្រាថ្នា យកនូវបដិភាគនិមិត្ត ក្នុងកម្មដ្ឋាន ២២ នោះ រមែងប្រព្រឹត្ត ទៅ ។ តើយ៉ាងណា ?

កាលព្រះយោគាវចរដែលជាអាទិកម្មិក កាន់យកនិមិត្ត ក្នុងកសិណ មានមណ្ឌលនៃបឋវីកសិណជាដើម អារម្មណ៍ នោះ លោកហៅថា បរិកម្មនិមិត្ត និងភាវនានោះ ឈ្មោះថា បរិកម្មភាវនា ។ ក៏ឯនិមិត្តនោះ ជានិមិត្តដែលចិត្តកំណត់បាន ល្អហើយ មកកាន់គន្លងនៃមនោទ្វារ ដូចមើលឃើញដោយ ភ្នែកក្នុងវេលាណា អារម្មណ៍នុ៎ះឯង ឈ្មោះថា ជាឧគ្គហនិមិត្ត និងភាវនានោះ រមែងតាំងមាំក្នុងវេលានោះ ។ ក៏កាលព្រះ យោគាវចរនោះ មានចិត្តតាំងមាំជាសមាធិយ៉ាងនោះ ហើយ ព្យាយាមភាវនា ដោយបរិកម្មសមាធិក្នុងឧគ្គហនិមិត្តនោះ តពី ឧគ្គហនិមិត្តនោះ ក្នុងវេលាណា អារម្មណ៍សម្រេចដោយភាវនា ពោលគឺ ផុតចាកវត្ថុធម៌ មាននិមិត្ត ប្រាកដដូចឧគ្គហនិមិត្ត

នោះ ស្ងប់ស្ងៀមហើយ ត្រង់ជួរល្អហើយ ក្នុងវេលានោះ លោកហៅថា បដិភាគនិមិត្តកើតឡើងហើយ ។ ចាប់ផ្តើមពីត្រឹមនោះ ឧបចារភាវនា ពោលគឺ កាមាវចរសមាធិ ក៏លះអន្តរាយបានហើយ រមែងឈ្មោះថា ភាវនាសម្រេចហើយ ក្នុងលំដាប់នោះ បដិភាគនិមិត្តរបស់ព្រះយោគាវចរ អ្នកសេពរឿយ ៗ ដោយឧបចារសមាធិនោះ រមែងអែបជិតសម្រេចជារូបាវចរបឋមជ្ឈាន ។

តពីនោះ ព្រះយោគាវចរធ្វើបឋមជ្ឈាននោះ ឱ្យជំនាញដោយភាពជាអ្នកមានវសីទាំង ៥ គឺ

***អាវជ្ជនវសី*** ជំនាញក្នុងការនឹក ១ ***សមាបជ្ជនវសី*** ជំនាញក្នុងការចូល ១ ***អធិដ្ឋានវសី*** ជំនាញក្នុងការតាំងមាំ ១ ***វុដ្ឋានវសី*** ជំនាញក្នុងការចេញ ១ ***បច្ចវេក្ខណវសី*** ជំនាញក្នុងការពិចារណា ១

ព្យាយាមជានិច្ច ដើម្បីលះអង្គដែលគ្រោតគ្រាត មាន

វិតក្កជាដើម ដើម្បីកើតឡើងនៃអង្គដែលល្អិត មានវិចារៈជាដើម រមែងសម្រេចទុតិយជ្ឈានជាដើម បានដោយលំដាប់តាមសមគួរ ។ បដិភាគនិមិត្ត រមែងមាននៅក្នុងកម្មដ្ឋាន ២២ មានបឋវីកសិណជាដើមយ៉ាងនេះ ដោយប្រការដូច្នេះ ។

កម្មដ្ឋានដែលនៅសល់ ១៨[១] គឺ អប្បមញ្ញា ៤ រមែងប្រព្រឹត្តទៅ ក្នុងអារម្មណ៍បញ្ញត្តិថា សត្វ ។ កំបណ្តាកសិណ វៀរអាកាសកសិណ យ៉ាងណាមួយ កាលព្រះយោគាវចរបើកចេញហើយ ធ្វើបរិកម្មអាកាសដែលខ្ទនបាន ដោយអំណាចភាពមិនមានទីបំផុត អរូបជ្ឈានទីមួយ ក៏កើតឡើង ។

ពេលធ្វើបរិកម្មនូវអរូបវិញ្ញាណទីមួយនុ៎ះឯង ដោយអំណាចការមិនមានទីបំផុត អរូបជ្ឈានទី ២ រមែងកើតឡើង ។

ពេលធ្វើបរិកម្មនូវការមិនមាននៃអរូបវិញ្ញាណនោះឯង

---

១. កម្មដ្ឋានដែលនៅសល់ ១៨ មិនមានអារម្មណ៍ ជាបដិភាគនិមិត្ត ។

ថា **នត្ថិ កិញ្ចិ** ដូច្នេះ អរូបជ្ឈានទី ៣ រមែងកើតឡើង ។

ពេលធ្វើបរិកម្មនូវអរូបទីបីថា **សន្តមេតំ បណីតមេតំ** ដូច្នេះ អរូបជ្ឈានទី ៤ រមែងកើតឡើង ។

ក្នុងកម្មដ្ឋាន ១០ យ៉ាង ដែលនៅសល់ ពេលព្រះយោគាវចរប្រារព្ធអារម្មណ៍ មានពុទ្ធគុណជាដើម ធ្វើបរិកម្មកាលនិមិត្តនោះ ដែលខ្ជួនកាន់យកល្អហើយ បរិកម្ម ក៏តាំងមាំ, ឧបចារសមាធិ ក៏កើតឡើងក្នុងនិមិត្តនោះឯង ។

## ប្រភេទនៃអារម្មណ៍

ក៏កាលព្រះយោគាវចរចេញចាកបញ្ចមជ្ឈាន ដែលជាបាទនៃអភិញ្ញា ហើយពិចារណាអារម្មណ៍មានរូបជាដើម ដែលខ្ជួនគប្បីអធិដ្ឋាន ធ្វើបរិកម្មជានិច្ច រូបាវចរបញ្ចមជ្ឈាន កំពុងប្រព្រឹត្តទៅដោយអំណាចនៃអភិញ្ញា រមែងអែបជិតក្នុងអារម្មណ៍មានរូបជាដើម តាមសមគួរ ។ និងដែលឈ្មោះថា

អភិញ្ញា មាន ៥ យ៉ាងគឺ ៖

**១- ឥទ្ធិវិធៈ** សម្ដែងឫទ្ធិបានផ្សេង ៗ

**២- ទិព្វសោតៈ** ត្រចៀកទិព្វ

**៣- បរចិត្តវិជ្ជា** ដឹងចិត្តអ្នកដទៃ

**៤- បុព្វេនិវាសានុស្សតិញ្ញាណ** ញាណដែលរលឹកដល់ខន្ធដែលខ្លួនធ្លាប់នៅអាស្រ័យ ។

**៥- ទិព្វចក្ខុ** ភ្នែកទិព្វ ។

នេះជាប្រភេទនៃអារម្មណ៍ ក្នុងអធិការនៃសមថកម្មដ្ឋាននេះឯង ។

ខាងមុខនេះទៅ ខ្ញុំនឹងពោលកម្មដ្ឋាន គឺ អារម្មណ៍ដែលឈ្មោះថា ជាកម្មដ្ឋាន ព្រោះជាហេតុនៃការប្រព្រឹត្តិធ្វើនូវកម្ម, ក្នុងភាវនា ២ យ៉ាង និងភាវនាវិធី ដែលឈ្មោះថា ជាកម្មដ្ឋាន ព្រោះជាបទដ្ឋាន (ហេតុជិត) នៃការធ្វើសេចក្ដីព្យាយាមក្រៃលែងឡើង សូម្បីទាំង ២ យ៉ាងនៃភាវនា,

ដែលហៅថា សមថៈ ដោយអត្ថថា ស្ងប់ចាកនីវរណៈទាំងឡាយ, និងដែលហៅថា វិបស្សនាដោយអត្ថថា ឃើញសង្ខារដោយអាការផ្សេង ៗ មានសេចក្តីមិនទៀងជាដើម តាមលំដាប់ គឺ ដោយលំដាប់នៃសមថភាវនា និងវិបស្សនាភាវនា ។ (ស្រង់ចាកពីអភិធម្មត្ថវិភាវិនី)

## អធិប្បាយ ចរិតដែលជាមូល ៦

គប្បីជ្រាបវចនត្ថៈ តទៅ ៖

**ចរណំ ចរិតា** ប្រែថា ការប្រព្រឹត្តិ ឈ្មោះថា ចរិត ។

**រញ្ជតិ អារម្មណេ ឯតេន ធម្មេនាតិ = រាគោ** បុគ្គលរមែងត្រេកអរក្នុងអារម្មណ៍ ដោយធម៌នេះ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា រាគៈ ។

**រាគោវ ចរិតា ចរិយា បកតីតិ = រាគចរិតា** ចរិត គឺ ការប្រព្រឹត្តិ បានដល់ ការធ្វើមុន គឺ រាគៈ ព្រោះហេតុនោះ

ទើបឈ្មោះថា រាគចរិត ។

សូម្បីទោសចរិតជាដើម ក៏ន័យនេះដែរ ។

ព្រះដីកាចារ្យសម្តែងចរិតជាមូល ដោយពិស្តារទុកថា ៖

ពាក្យថា ចរិតសង្គហៈ បានដល់ ការរួមបុគ្គល ដោយអំណាចនៃចរិត ដែលជាមូល (៦ យ៉ាង) តែការប្រព្រឹត្តិរបស់បុគ្គល មាន ៦៣ យ៉ាង ដោយអំណាចចរិតលាយគ្នា ។ ពិតដូចលោកអាចារ្យពោលទុកក្នុងនាមរូបបរិច្ឆេទថា ៖

**មានចរិត ៧ ក្នុងពួកអកុសលចិត្ត ៣ មានរាគចរិតជាដើម មានចរិត ៧ ក្នុងពួកកុសលចិត្ត ៣ មានសទ្ធាចរិតជាដើម ពោលដោយការលាយចូលគ្នាទាំងក្នុងចរិតមូល ១ មូល ២ និង មូល ៣ រមែងមានពួក ៧ នៃចរិត ៧ ពួក ។**

ក្នុងគាថានេះ មានវិនិច្ឆ័យថា

| ចរិតពួក ៧ ក្នុងអកុសលតិកៈ មានរាគៈជាដើម គឺ ៖ | ពួក ៧ ក្នុងកុសលតិកៈ មានសទ្ធាជាដើម គឺ ៖ |
|---|---|
| ១- រាគចរិត | ១- សទ្ធាចរិត |
| ២- ទោសចរិត | ២- ពុទ្ធិចរិត |
| ៣- មោហចរិត | ៣- វិតក្កចរិត |
| ៤- រាគទោសចរិត | ៤- សទ្ធាពុទ្ធិចរិត |
| ៥- រាគមោហចរិត | ៥- សទ្ធាវិតក្កចរិត |
| ៦- ទោសមោហចរិត | ៦- ពុទ្ធិវិតក្កចរិត |
| ៧- រាគទោសមោហចរិត | ៧- សទ្ធាពុទ្ធិវិតក្កចរិត |

រួមចរិត ១៤ ក្នុងក្រុមទាំង ២ ព្រោះមិនលាយគ្នាចូលក្នុងតិកៈ ដែលជាអកុសល ជាមួយនឹងកុសល ៗ តែពេលប្រកបអកុសលចរិត មានរាគៈជាដើម ចូលជាមួយ និង

កុសលចរិត មានសទ្ធាជាដើម ដោយអំណាចមូល ១ គឺ

| | |
|---|---|
| មានរាគជាមូល បាន ចរិត ៧ ដូច្នេះ គឺ | ក្នុងទោសជាមូល ក៏មាន ៧ ដូចគ្នា |
| ១- រាគសទ្ធាចរិត | ១- ទោសសទ្ធាចរិត |
| ២- រាគពុទ្ធិចរិត | ២- ទោសពុទ្ធិចរិត |
| ៣- រាគវិតក្កចរិត | ៣- ទោសវិតក្កចរិត |
| ៤- រាគសទ្ធាពុទ្ធិចរិត | ៤- ទោសសទ្ធាពុទ្ធិចរិត |
| ៥- រាគសទ្ធាវិតក្កចរិត | ៥- ទោសសទ្ធាវិតក្កចរិត |
| ៦- រាគពុទ្ធិវិតក្កចរិត | ៦- ទោសពុទ្ធិវិតក្កចរិត |
| ៧- រាគសទ្ធាពុទ្ធិវិតក្កចរិត | ៧- ទោសសទ្ធាពុទ្ធិវិតក្កចរិត |

សូម្បីក្នុងន័យដែលមានមោហចរិត ជាមូល ក៏មាន ៧ ដូចគ្នា រួមចរិតដែលមានមូលមួយ បានចរិត ២១ យ៉ាង នេះ ។

ក្នុងន័យដែលមានមូល ២ គឺ មានរាគទោសជាមូល

ក៏មានចរិត ៧ ដូច្នេះគឺ ៖

១- រាគទោសសទ្ធាចរិត

២- រាគទោសពុទ្ធិចរិត

៣- រាគទោសវិតក្កចរិត

៤- រាគទោសសទ្ធាពុទ្ធិចរិត

៥- រាគទោសសទ្ធាវិតក្កចរិត

៦- រាគទោសពុទ្ធិវិតក្កចរិត

៧- រាគទោសសទ្ធាពុទ្ធិវិតក្កចរិត

សូម្បីក្នុងន័យដែលមានរាគមោហជាមូល ក៏មានចរិត ៧ ។

សូម្បីក្នុងន័យដែលមានទោសមោហជាមូល ក៏យ៉ាងនោះដែរ រមែងមានចរិត ៧ រួមក្នុងន័យដែលមានមូល ២ រមែងបានចរិត ២១ ដូចគ្នា ។

ក្នុងន័យដែលមានមូល ៣ គឺ មានរាគៈ ទោសៈ

មោហៈ ជាមូល រមែងបានមូល ១ខ្លះ ២ខ្លះ ៣ខ្លះ ដូច្នេះ គឺ

១- រាគទោសមោហៈ មានសទ្ធាចរិតជាមូល

២- រាគទោសមោហៈ មានពុទ្ធិចរិតជាមូល

៣- រាគទោសមោហៈ មានវិតក្កចរិតជាមូល

៤- រាគទោសមោហៈ មានសទ្ធាពុទ្ធិចរិតជាមូល

៥- រាគទោសមោហៈ មានសទ្ធាវិតក្កចរិតជាមូល

៦- រាគទោសមោហៈ មានពុទ្ធិវិតក្កចរិតជាមូល

៧- រាគទោសមោហៈ មានសទ្ធាពុទ្ធិវិតក្កចរិតជាមូល ។

សរុបចរិត ៦៣ គឺ ៖

១-អកុសលចរិត ៧ ប្រការ

២-កុសលចរិត ៧ ប្រការ

៣-មិស្សកចរិត ១ មូល ២១ ប្រការ

៤-មិស្សកចរិត ២ មូល ២១ ប្រការ

៥-មិស្សកចរិត ៣ មូល ៧ ប្រការ

បណ្ឌិតគប្បីជ្រាបចរិយា គឺ ការប្រព្រឹត្តិរបស់បុគ្គល ៦៣ ប្រការ យ៉ាងនេះ. តែអាចារ្យពួកខ្លះ បានបន្ថែមទិដ្ឋិចរិត មួយទៀត ទើបរួមជា ៦៤ ប្រការ ។

## សម្ដែងចរិត ៦ ដោយសភាគ ៣ ពួក

សម្ដែងចរិត ៦ ដែលជាមូលមានរាគៈជាដើម ក្នុងបុគ្គល ៦ ជាការសម្ដែងដោយសង្ខេប កាលទឹងសម្ដែងដោយពិស្ដារ លោកពោលថា ការប្រព្រឹត្តិរបស់បុគ្គលមាន ៦៣ ប្រការ ក្នុងចរិតទាំងនោះ មានកេចិអាចារ្យសម្ដែងទុកច្រើនន័យ ។

<u>ក្នុងវិសុទ្ធិមគ្គ</u> សម្ដែងចរិតនៃបុគ្គល ៦ ពួក ហើយសម្ដែងសភាគចរិត (ចរិតដែលមានចំណែកស្មើគ្នា) ទុក ៣ ពួក គឺ ៖

១- រាគចរិត សភាគជាមួយសទ្ធាចរិត

២- ទោសចរិត សភាគជាមួយពុទ្ធិចរិត

៣- មោហចរិត សភាគជាមួយវិតក្កចរិត ។

ក្នុងបណ្ដាចរិតទាំង ៦ នោះ អ្នករាគចរិត ក្នុងវេលាប្រព្រឹត្តកុសល សទ្ធាចាស់ក្លា (គឺ កម្លាំងខ្លាំង) ព្រោះសទ្ធាជាគុណជិតចំពោះរាគៈ ។ ពិតមែន នៅក្នុងផ្នែកអកុសល រាគៈជាធម៌មានទោសគួរស្រលាញ់ មិនសៅហ្មង យ៉ាងណា ក្នុងផ្នែកកុសល សទ្ធា ក៏ជាគុណមិនមានទោស មិនសៅហ្មង យ៉ាងនោះ ។ រាគៈរមែងស្វែងរកវត្ថុកាម យ៉ាងណា សទ្ធាក៏ស្វែងរកគុណ មានសីលជាដើម យ៉ាងនោះ, រាគៈមិនលះបង់ចោលនូវរបស់ដែលមិនជាប្រយោជន៍ យ៉ាងណា សទ្ធា ក៏មិនលះបង់ចោលរបស់ដែលជាប្រយោជន៍ យ៉ាងនោះ ព្រោះដូច្នោះ សទ្ធាចរិត ទើបជាសភាគ (មានចំណែកស្មើគ្នា ៥) ជាមួយរាគចរិត ។

ក៏អ្នកទោសចរិត ក្នុងវេលាប្រព្រឹត្តកុសល បញ្ញា រមែងមានកម្លាំងខ្លាំងក្លា ព្រោះបញ្ញាជាគុណជិតចំពោះទោសៈ ។ ពិតមែន នៅក្នុងផ្នែកអកុសល ទោសៈជាទោស មិនជាប់ជំពាក់មិនហួងហែង មិនតោងជាប់អារម្មណ៍ យ៉ាងណា ក្នុងផ្នែកកុសល បញ្ញាក៏ជាគុណជាតិ ដែលមិនមានការហួងហែងជាប់ជំពាក់ មិនតោងជាប់អារម្មណ៍ យ៉ាងនោះដែរ ។

មួយទៀត ទោសៈរមែងស្វែងរកទោសប៉ុណ្ណោះ សូម្បីមិនជាពិត យ៉ាងណា បញ្ញា ក៏ស្វែងរកទោសដែលជាពិតយ៉ាងនោះ ទោសៈរមែងប្រព្រឹត្តវៀរចាកសត្វយ៉ាងណា បញ្ញាក៏ប្រព្រឹត្តវៀរចាកសង្ខារ យ៉ាងនោះ ព្រោះហេតុនោះ ពុទ្ធិចរិតទើបជាសភាគ(មានចំណែកស្មើគ្នា) ជាមួយនឹងទោសចរិត ។

ក៏ព្រោះអ្នកមោហចរិត កាលព្យាយាមធ្វើកុសលធម៌ដែលមិនទាន់កើតឱ្យកើតឡើង វិតក្កៈទាំងឡាយ ដែលធ្វើ

អន្តរាយច្រើន នឹងកើតឡើងដោយច្រើន ព្រោះវិតក្កមានលក្ខណៈ ជិតចំពោះមោហៈ ក៏មោហៈ ដែលជាធម៌មិនគង់វង្ស ព្រោះសេចក្ដីខ្វល់ខ្វាយយ៉ាងណា វិតក្កៈក៏មិនគង់វង្ស ព្រោះការត្រិះរិះមានប្រការផ្សេង ៗ យ៉ាងនោះ មួយទៀត មោហៈ ញាប់ញ័រ ព្រោះមិនតាំងមាំ យ៉ាងណា វិតក្កៈ ក៏យ៉ាងនោះ ជាធម៌ញាប់ញ័រ មិនតាំងមាំ ព្រោះគិតផ្លាស់ប្ដូរប្រែប្រួលទៅរហ័ស ដូច្នោះ វិតក្កចរិត ទើបជាសភាគ (មានចំណែកស្មើគ្នា) ជាមួយនឹងមោហចរិតនុ៎ះឯង ฯ

## កម្មដែលជាបុព្វហេតុ

វិសុទ្ធិមគ្គ វិនិច្ឆ័យតាមមតិរបស់អដ្ឋកថាចារ្យទាំងឡាយក្នុងបញ្ហាថា ចរិតទាំងឡាយ មានអ្វីជាដើមហេតុនោះ ฯ ក៏អាចារ្យទាំងនោះ បានពោលពាក្យនេះទុកថា សត្វទាំងនេះ បើនិយាយពីហេតុក្នុងកាលមុន ជាអ្នកក្រាស់ដោយលោភៈក៏មាន,

ក្រាស់ដោយទោសៈក៏មាន, ក្រាស់ដោយមោហៈក៏មាន, ជាអ្នកច្រើនដោយអលោភៈក៏មាន, ច្រើនដោយអទោសៈក៏មាន, ច្រើនដោយអមោហៈក៏មាន ។

ពិតមែនហើយ ក្នុងខណៈព្យាយាមធ្វើកម្ម អ្នកណាមានលោភៈខ្លាំងក្លា អលោភៈទន់, អទោសៈ អមោហៈខ្លាំងក្លា ទោសៈមោហៈទន់, អលោភៈទន់របស់បុគ្គលនោះ រមែងមិនអាចគ្របសង្កត់លោភៈ, តែអទោសៈអមោហៈខ្លាំងក្លា រមែងអាចគ្របសង្កត់ទោសៈ មោហៈបាន ។ ព្រោះហេតុនោះ បុគ្គលនោះ កើតមកដោយអំណាចនៃបដិសន្ធិដែលកម្មនោះឱ្យផលហើយ រមែងជាមនុស្សលោភៈ មានសុខច្រើន មិនច្រើនដោយសេចក្ដីក្រោធ មានបញ្ញា មានញាណ ប្រៀបដោយវជិរៈ ។

បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានលោភៈទោសៈខ្លាំងក្លា, អលោភៈ អទោសៈទន់ តែអមោហៈខ្លាំងក្លា,

មោហៈទន់. បុគ្គលនោះ កើតមកដោយកម្មនោះឱ្យផលហើយ រមែងជាមនុស្សលោភៈផង ឆាប់ខឹងផង តែជាមនុស្សមានបញ្ញា មានញាណដែលប្រៀបដោយវជិរៈ ។

បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានលោភៈមោហៈខ្លាំងក្លា, ក្រៅពីនោះទន់ បុគ្គលនោះ បដិសន្ធិមកដោយកម្មនោះឱ្យផលហើយ រមែងជាមនុស្សលោភៈផង ជាមនុស្សល្ងង់ផង តែជាមនុស្សចិត្តត្រជាក់ មិនច្រើនដោយក្រោធ ។

មួយទៀត បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្មមានលោភៈ ទោសៈ មោហៈ ទាំង ៣ មានកម្លាំងខ្លាំងក្លា មានអលោភៈជាដើមទន់ បុគ្គលនោះ បដិសន្ធិមកដោយកម្មនោះឱ្យផលហើយ រមែងជាមនុស្សលោភៈផង ឆាប់ខឹងផង ល្ងង់ខ្លៅផង ។

ចំណែកបុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានអលោភៈ ទោសៈ មោហៈខ្លាំងក្លា ក្រៅពីនោះទន់ខ្សោយ

បុគ្គលនោះបដិសន្ធិមកដោយកម្មនោះ ឱ្យផលហើយ រមែងជាមនុស្សមិនលោភៈ និងមានកិលេសតិច សូម្បីឃើញអារម្មណ៍ជាទិព្វល្អវិសេស ក៏មិនញាប់ញ័រ តែជាមនុស្សឆោប់ខឹង មានបញ្ញាតិច ។

បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានអលោភៈ អទោសៈ មោហៈខ្លាំងក្លា ក្រៅពីនោះទន់ បុគ្គលនោះបដិសន្ធិមកដោយកម្មនោះឱ្យផល រមែងជាមនុស្សមិនលោភផង មានចិត្តត្រជាក់ផង តែជាមនុស្សល្ងង់ខ្លៅ ។

បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានអលោភៈ ទោសៈ អមោហៈខ្លាំងក្លា ក្រៅពីនោះទន់ បុគ្គលនោះ បដិសន្ធិមកដោយកម្មនោះឱ្យផលហើយ រមែងជាមនុស្សមិនលោភៈផង មានបញ្ញាផង តែជាមនុស្សឆេវឆាវ ឆាប់ខឹងក្រោធ ។

ចំណែកបុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្មកុសល មានអលោភៈជាដើម មានកម្លាំងខ្លាំងក្លា អកុសលមានលោភៈ

ជាដើមទន់ខ្សោយ បុគ្គលនោះ កាលបដិសន្ធិមកដោយកម្ម នោះឱ្យផល រមែងជាមនុស្សមិនលោភៈ មិនឆេវឆាវ ហើយ មានបញ្ញា ដូចព្រះមហាសង្ឃរក្ខិតត្ថេរ ដូច្នោះ ។

ក្នុងអធិការកម្មដែលជាបុព្វហេតុនេះ គប្បីជ្រាបថា

បុគ្គលណា ដែលលោកពោលថា លោភៈ បុគ្គលនោះ លោកហៅថា មានរាគចរិត ។

ចំណែកបុគ្គលឆាប់ខឹង ហៅថា ទោសចរិត ។

មនុស្សល្ងង់ខ្លៅ ហៅថា មោហចរិត ។

បុគ្គលមានបញ្ញា ហៅថា ពុទ្ធិចរិត ។

មនុស្សមិនលោភៈ មិនឆេវឆាវ ហៅថា សទ្ធាចរិត ព្រោះជាមនុស្សមានចិត្តជ្រះថ្លាជាប្រក្រតី ។

ម្យ៉ាងទៀត គប្បីជ្រាបថា កម្មដែលឱ្យបដិសន្ធិដែល មានបុព្វហេតុ មានលោភៈជាដើម យ៉ាងណាមួយជាបរិវារ (ហែហម)ជាដើម ហេតុនៃចរិតទាំងឡាយ យ៉ាងនេះ គឺ

អ្នកដែលកើតមកដោយកម្មដែលមានអមោហៈជាបរិវារ រមែងជាមនុស្សពុទ្ធិចរិត យ៉ាងណា មនុស្សកើតមកដោយកម្មមានពលវសទ្ធាជាបរិវារ ក៏ជាមនុស្សសទ្ធាចរិត, មនុស្សកើតមកដោយកម្មដែលមានកាមវិតក្កៈជាដើម ជាបរិវារ ក៏ជាមនុស្សវិតក្កចរិត និងមនុស្សដែលកើតមកដោយកម្ម មានលោភៈជាដើម ដែលលាយគ្នាជាបរិវារ ក៏ជាមនុស្សមានចរិតលាយគ្នា (លោកហៅថា វោមិស្សចរិត) យ៉ាងនោះ ដូច្នេះ ។

## មើលលក្ខណៈចរិតមនុស្ស

បណ្តាចរិតទាំង ៦ យ៉ាងនោះ អ្នកបានអភិញ្ញាចិត្ត រមែងអាចដឹងថា អ្នកនេះមានចរិតយ៉ាងនេះ តែប្រសិនបើមិនបានអភិញ្ញាចិត្តទេ ប្រាថ្នានឹងដឹង ក៏ពិចារណាមើលការប្រព្រឹត្តិដោយអាការ ៥ យ៉ាង ក៏នឹងដឹងបានខ្លះ គឺ ឥរិយាបថ ៤. ការងារ. ការបរិភោគអាហារ. ការក្រលេកមើល និងការស្តាប់

ជាដើម ព្រមទាំងការប្រព្រឹត្តិធ្វើក្នុងវត្ថុផ្សេង ៗ តាមន័យនៃ វិសុទ្ធិមគ្គ ពោលថា ៖

២. ឥរិយាបថតោ កិច្ចា ភោជនា ទស្សនាទិតោ
ធម្មប្បវត្តិតោ ចេវ ចរិយាយោ វិភាវយេ ។

បណ្ឌិតគប្បីពន្យល់បង្ហាញ ឱ្យជាក់ច្បាស់នូវការប្រព្រឹត្តិ (ចរិត)ទាំងឡាយ បានដោយឥរិយាបថ ១ ដោយកិច្ច ១ ដោយការបរិភោគ ១ ដោយអាការ មានការក្រលេកមើលជាដើម ១ និងដោយការប្រព្រឹត្តិនៃធម៌ ១ ប៉ុណ្ណោះ ។

សេចក្តីពិស្តារ ជាប់ទាក់ទងដោយឥរិយាបថ និងដោយកិច្ចការជាដើម គប្បីត្រូតមើលក្នុងវិសុទ្ធិមគ្គ បឋមភាគចុះ ។

ចប់ ចរិតនៃបុគ្គលដោយសង្ខេប

## អធិប្បាយ ភាវនានិងនិមិត្ត

***ភាវនា*** *វចនត្ថថា* ***ភាវនាយ បដិសង្ខារកម្មភូតា អាទិកម្មភូតា វា បុព្វភាគភាវនា បរិកម្មភាវនា នាម*** *: ភាវនាដែលជាចំណែកខាងដើម ជាការប្រជុំតាក់តែងភាវនាឬ ជាកម្មខាងដើមនៃភាវនា ឈ្មោះថា បរិកម្មភាវនា ។*

***នីវរណវិក្ខម្ភនតោ បដ្ឋាយ គោត្រភូបរិយោសានា កាមាវចរភាវនា ឧបចារភាវនា នាម*** *: កាមាវចរភាវនា ចាប់ផ្តើមតាំងអំពីការគ្របសង្កត់នីវរណៈ ដែលមានគោត្រភូជាទីបំផុត ឈ្មោះថា ឧបចារភាវនា ព្រោះត្រាច់ទៅជិតអប្បនាដូចឧបចារកន្លែងខ្លះជាដើម ។*

***មហគ្គតភាវប្បត្តា អប្បនាភាវនា នាម អប្បនាសង្ខាតវិតក្កបមុខត្តា*** *: ភាវនាដែលដល់មហគ្គត ឈ្មោះថា អប្បនាភាវនា ព្រោះសេចក្តីដែលវិតក្កៈ គឺ អប្បនាជាប្រធាន ។*

*វិតក្កៈ ឈ្មោះថា អប្បនា ព្រោះអត្ថថា ប្រព្រឹត្តទៅដូច*

ញ៉ាំងសម្បយុត្តធម៌ឱ្យអែបជិតក្នុងអារម្មណ៍ ។ ពិតមែន វិតក្កនោះ ព្រះមានព្រះភាគទ្រង់ត្រាស់អធិប្បាយថា ជាអប្បនា (ញ៉ាំងសម្បយុត្តធម៌ឱ្យអែបជិតក្នុងអារម្មណ៍) ព្យប្បនា (អែបជិតវិសេស) ដូច្នេះ ។ សូម្បីឈានធម៌ដែលជាមហគ្គត និងជាអនុត្តរទាំងអស់ ព្រះមានព្រះភាគក៏ទ្រង់ត្រាស់ថា អប្បនា ដោយអំណាចនៃវិតក្កៈនោះជាប្រធាន ។

**និមិត្ត** ៣ មានវចនត្ថៈថា **បរិកម្មស្ស និមិត្តំ អារម្មណត្តាតិ = បរិកម្មនិមិត្តំ** : ដែលឈ្មោះថា និមិត្តនៃបរិកម្ម ព្រោះភាពជាអារម្មណ៍ ព្រោះដូច្នោះ ទើបឈ្មោះថា បរិកម្មនិមិត្តំ បានដល់ មណ្ឌលនៃកសិណជាដើម (ពាក្យថា ជាដើម បានដល់ អសុភនិមិត្តជាដើម) ។

**តទេវ ចក្ខុនា ទិដ្ឋំ វិយ មនសា ឧគ្គហេតព្វំ និមិត្តំ ឧគ្គហន្តស្ស វា និមិត្តន្តិ = ឧគ្គហនិមិត្តំ** : បរិកម្មនិមិត្តនោះឯង ឈ្មោះថា ឧគ្គហនិមិត្ត ព្រោះអត្ថថា ជានិមិត្តដែលព្រះ

យោគី គប្បីកាន់យកដោយចិត្ត ដូចឃើញដោយភ្នែក ឬថា ជានិមិត្តរបស់ព្រះយោគីអ្នកសិក្សា ។

**តប្បដិភាគវណ្ណាទិកសិណទោសរហិតំ និមិត្តំ ឧបចារប្បនានមារម្មណត្តា បដិភាគនិមិត្តំ** : និមិត្តដែលវៀរចាកទោសនៃកសិណ មានវណ្ណកសិណជាដើម ដែលមានចំណែកដូចគ្នា និងឧគ្គហនិមិត្តនោះ ឈ្មោះថា បដិភាគនិមិត្ត ព្រោះនិមិត្តនោះ ជាអារម្មណ៍ដល់ឧបចារភាវនា និងអប្បនាភាវនា ។

## អធិប្បាយពាក្យថា កសិណ

**កសិណ** មានវចនត្ថៈថា **បឋវី យេវ កសិណំ ឯកទេសេ អបត្វា អនន្តរស្ស ផរិតព្វតាយ សកលដ្ឋេនាតិ = បឋវីកសិណំ** : កសិណ គឺ បឋវី ដោយអត្ថថា ទាំងអស់ ដោយព្រះ

យោគីមិនតាំងទុក (គឺ វៀរ) ក្នុងចំណែកខ្លះ គប្បីផ្សព្វផ្សាយទៅទាំងអស់ មិនមានទីបំផុត ព្រោះហេតុនោះ ទើបឈ្មោះថា បឋវីកសិណ ។ មណ្ឌលនៃកសិណ (ដីដែលធ្វើជារង្វង់មូល)ក្តី បដិភាគនិមិត្តក្តី ឈានដែលមានបដិភាគនិមិត្តនោះ ជាអារម្មណ៍ក្តី ទាំង៣ នេះ បណ្ឌិតហៅថា បឋវីកសិណ ។

សូម្បីក្នុងន័យនៃអាបោកសិណ ក៏យ៉ាងនោះដែរ ។

បណ្តាកសិណទាំងនោះ បណ្ឌិតគប្បីជ្រាបថា កសិណ ៤ មានបឋវីជាដើម ឈ្មោះថា ភូតកសិណ, កសិណ ៤ មាននីលកសិណជាដើម ឈ្មោះថា វណ្ណកសិណ, បរិច្ឆិន្នាកាស ឈ្មោះថា អាកាសកសិណ. ពន្លឺនៃព្រះចន្ទជាដើម ឈ្មោះថា អាលោកកសិណ ។

## អធិប្បាយ អសុភ ១០

១- សាកសពដែលឡើងប៉ោង គឺ ហើមប៉ោង ឈ្មោះថា ឧទ្ធុមាត សាកសពឧទ្ធុមាតកនោះឯង ឈ្មោះថា ឧទ្ធុមាតកៈ ព្រោះអត្ថថា គួរស្អប់ខ្ពើម សូម្បីអសុភដែលនៅសល់ មាននីលកអសុភជាដើម ក៏គប្បីជ្រាបថា គួរខ្ពើមរអើមយ៉ាងនេះ ។

២- សាកសពដែលចំរុះលាយឡំដោយពណ៌ផ្សេង ៗ មានពណ៌ស និងពណ៌ក្រហមជាដើម ដោយច្រើនមានពណ៌ខៀវ ឈ្មោះថា នីលកៈ ព្រោះធ្វើវិគ្រោះថា មានពណ៌ខៀវដោយច្រើន ។

៣- សាកសពដែលមានខ្ទុះហូរចេញក្រៅ ឈ្មោះថា វិបុព្វកៈ ។

៤- សាកសពដែលកាត់ពាក់កណ្ដាលជាពីរកំណាត់ ឈ្មោះថា វិច្ឆិទ្ទកៈ ។

៥- សាកសពដែលសុនខ និងឆ្កែចចកជាដើម ទាំកកេរស៊ី ដោយអាការផ្សេង ៗ ឈ្មោះថា វិក្ខាយិតកៈ ។

៦- សាកសពដែលសុនខជាដើម ទាំកកេរ ស៊ី ដោយអាការផ្សេង ៗ ខ្ទាត់ខ្ទាយ រាត់រាយទៅក្នុងទីនោះ ៗ ឈ្មោះថា វិក្ខិត្តកៈ ។

៧- សាកសពដែលត្រូវសស្ត្រាវុធកាប់ចិញ្ច្រាំ ដោយអាការមានរូបកាកបាទ (សញ្ញា+)ជាដើម ចោលខ្ទាត់ខ្ទាយ រាត់រាយទៅ ឈ្មោះថា ហតវិក្ខិត្តកៈ ។

៨- សាកសពដែលមានលោហិតហូរចេញ ឈ្មោះថា លោហិតកៈ ។

៩- សាកសពដែលមានសត្វដង្កូវចោះច្រើន ឈ្មោះថា បុឡុវកៈ ។

១០- ដោយហោចទៅ សូម្បីឆ្អឹងមួយកំណាត់ ដែលគួរខ្ពើម ក៏ឈ្មោះថា អដ្ឋិកៈ ។

## អធិប្បាយ អនុស្សតិ

***អនុស្សតិ*** មានវចនត្ថថា ***អនុអនុស្សរណំ*** = ***អនុស្សតិ*** ការរលឹករឿយ ៗ ឈ្មោះថា អនុស្សតិ ។

ន័យមួយទៀតថា **បុនប្បុនំ ឧប្បជ្ជនតោ សតិយេវ** = ***អនុស្សតិ*** : សតិនុ៎ះឯង ឈ្មោះថា អនុស្សតិ ព្រោះកើតញឹកញាប់ ។

## អនុស្សតិ មាន ១០ យ៉ាង គឺ

១- ការរលឹករឿយ ៗ ដល់ព្រះពុទ្ធគុណ មានអរហត្តគុណជាដើម ជាអារម្មណ៍ ឈ្មោះថា ***ពុទ្ធានុស្សតិ*** ។ (អរហត្តគុណ គឺ គុណជាព្រះអរហន្ត មាន ៥ ន័យ គឺ ជាអ្នកឆ្ងាយចាកកិលេស ១, ជាអ្នកកំចាត់សឹកសត្រូវ ១, ជាអ្នកទម្លាយសង្សារចក្រ គឺ កង់នៃសង្សារ មានអវិជ្ជាជាដុំ ឬមូលរបស់សង្សារចក្រ ១, ជាអ្នកគួរដល់ទក្ខិណាវត្ថុទាំងឡាយ ១, និងភាពជាអ្នកមិនមានទីកំបាំង ក្នុងការធ្វើអំពើបាប

ឡើយ ១) ។

២- ការរលឹករឿយ ៗ ដល់ព្រះធម្មគុណ មានស្វាក្ខាតធម៌ជាដើម ជាអារម្មណ៍ ឈ្មោះថា **ធម្មានុស្សតិ** ។

៣- ការរលឹករឿយ ៗ ដល់គុណព្រះសង្ឃ មានសេចក្ដីជាអ្នកបដិបត្តិល្អហើយជាដើម ជាអារម្មណ៍ ឈ្មោះថា **សង្ឃានុស្សតិ** ។

៤- ការរលឹកដល់គុណនៃសីលរបស់ខ្លួន ដែលបរិសុទ្ធល្អហើយ ដោយភាពជាសីលមិនដាច់ជាដើមរឿយ ៗ ឈ្មោះថា **សីលានុស្សតិ** ។ (សីលមិនដាច់មិនធ្លុះធ្លាយ មិនពព្រុស មិនពពាល ជាសីលបរិសុទ្ធល្អ ។ សីលដាច់ ដូចសំពត់ដាច់ដាយ, សីលធ្លុះធ្លាយ ដូចសំពត់ធ្លុះត្រង់កណ្ដាល, សីលពព្រុស ដូចមេគោ មានខ្លួនរទុះអុច ៗផ្សេង ៗ, សីលពពាល ដូចមេគោដាងមានសម្បុរស្បែកឆ្លក មានខ្មៅ ស ក្រហម ។

៥- ការរលឹករឿយ ៗ ដល់ចាគៈរបស់ខ្លួន ដោយអំណាចមន្ទិល គឺ សេចក្ដីកំណាញ់ ប្រាសចាកទៅហើយ ឈ្មោះថា **ចាគានុស្សតិ** ។

៦- ការតាំងទេវតា ទុកក្នុងឋានជាសាក្សីយ៉ាងនេះថា "ពួកទេវតាប្រកបដោយគុណទាំងឡាយ មានសទ្ធាជាដើម បានដល់ ភាពជាទេវតា, គុណទាំងឡាយ ដូច្នោះ ក៏មាននៅក្នុងខ្លួនយើង" ដូច្នេះ. ហើយរលឹករឿយ ៗ ដល់គុណមានសទ្ធាជាដើមរបស់ខ្លួន ឈ្មោះថា **ទេវតានុស្សតិ** ។

៧- ការរលឹករឿយ ៗ ដល់គុណនៃព្រះនិព្វាន ជាធម៌ស្ងប់រម្ងាប់ទុក្ខទាំងពួង ឈ្មោះថា **ឧបសមានុស្សតិ** ។

៨- ការរលឹករឿយ ៗ ដល់សេចក្ដីស្លាប់ជាធម៌ដែលបង្អោនទៅកាត់ផ្ដាច់ជីវិតិន្ទ្រិយ ឈ្មោះថា **មរណានុស្សតិ** ។

៩- សតិ (ការរលឹកទៅ គឺ ដំណើរប្រព្រឹត្តទៅនៃកាយ មានកេសាជាដើម ឈ្មោះថា **កាយគតាសតិ** ។

១០- អានៈ ( ខ្យល់ចេញទៅក្រៅ ) អាបានៈ ( ខ្យល់ចូលទៅខាងក្នុង ) ឈ្មោះថា អានាបានៈ បានដល់ ខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូល សតិមានខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូលនោះ ជាអារម្មណ៍ ឈ្មោះថា **អានាបានស្សតិ** ។

## អធិប្បាយ អប្បមញ្ញា ៤

***អប្បមញ្ញា*** មានវចនត្ថៈថា ***អប្បមាណសត្តារម្មណត្តា អប្បមាណា តា ឯវ = អប្បមញ្ញា*** ឈ្មោះថា មិនមានប្រមាណ ព្រោះមានសត្វមិនមានប្រមាណជាអារម្មណ៍ អប្បនានុ៎ះឯង ឈ្មោះថា **អប្បមញ្ញា** ។

***មេត្តា*** មានវចនត្ថៈថា ***មិជ្ជតិ សិនិយ្ហតីតិ = មេត្តា*** : ធម្មជាតិណា រមែងស្រឡាញ់( រាប់អាន ) គឺ រមែងស្នេហា ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា មេត្តា ។ ***មិត្តេសុ***

**ភវតិ វា = មេត្តា** : ន័យម្យ៉ាងទៀត ធម្មជាតិដែលកើតក្នុងពួកមិត្រ ឈ្មោះថា មេត្តា ។

**ករុណា** មានវចនត្ថៈថា **ករោតិ បរទុក្ខេ សតិ សាធូនំ ហទយខេទំ ជនេតិ កិរតិ វា វិក្ខិបតិ បរទុក្ខំ កិណាតិ វា តំ ហឹសតិ កិរិយតិ វា ទុក្ខិតេសុ បសារិយតីតិ = ករុណា** : ធម្មជាតិណា កាលសត្វដទៃមានទុក្ខ រមែងធ្វើ គឺ រមែងឱ្យកើតសេចក្ដីលំបាកចិត្តរបស់មនុស្សល្អទាំងឡាយ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ករុណា ។ ម្យ៉ាងទៀត ធម្មជាតិណា រមែងកំចាត់កំចាយ គឺ រមែងជួយបំបាត់ទុក្ខរបស់សត្វដទៃ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ករុណា ឬ ធម្មជាតិណា រមែងផ្លាស់ប្ដូរ គឺ បៀតបៀនទុក្ខរបស់សត្វដទៃនោះ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ករុណា ឬធម្មជាតិណា ពេលសត្វជួបប្រសព្វទុក្ខ បុគ្គលរមែងជួយរំសាយចេញទៅ ព្រោះហេតុនោះ ធម្មជាតិ រំសាយ

ចេញទៅនោះ ក៏ឈ្មោះថាករុណា ។ ទុក្ខរបស់សត្វដទៃនោះ នឹងវិនាសទៅ ឬមិនវិនាសទៅក៏ដោយ ករុណានោះ ក៏ប្រព្រឹត្តទៅដោយអាការនោះ ។

**មុទិតា** មានវចនត្ថៈថា **មោទន្តិ ឯតាយាតិ = មុទិតា** បុគ្គលរមែងត្រេកអរ ដោយធម្មជាតិនោះ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា មុទិតា ។

**តត្រមជ្ឈត្តតា** (ឧបេក្ខា) មានវចនត្ថៈថា **តេសុ តេសុ ធម្មេសុ មជ្ឈត្តតា តត្រមជ្ឈត្តតា** ភាវៈនៃសេចក្ដីជាកណ្ដាល ក្នុងចិត្តនិងចេតសិកធម៌នោះ ៗ ដែលសម្បយុត្តជាមួយខ្លួន ឈ្មោះថា តត្រមជ្ឈត្តតា បានដល់ ឧបេក្ខា ជាសង្ខារក្ខន្ធ (គឺ តត្រមជ្ឈត្តតាសោភណចេតសិក) ។

<u>ក្នុងអត្ថយោជនា ទុតិយភាគ</u> ពោលថា ៖

ខ្លួន គឺ ភាវៈរបស់ខ្លួន តាំងនៅក្នុងកណ្ដាលនៃធម៌

ដែលប្រជុំគ្នានេះ ព្រោះហេតុនោះ ធម៌នោះ ទើបឈ្មោះថា មជ្ឈត្តតា ។ ភាវៈនៃមជ្ឈត្តតានោះ ឈ្មោះថា **តត្រមជ្ឈត្តតា** ។

## លក្ខណៈអប្បមញ្ញា ៤

១. ***សា សត្តានំ ហិតសុខូបសំហរណលក្ខណា មេត្តា :*** *មេត្តានោះ មានការនាំប្រយោជន៍ និងសេចក្ដីសុខចូលទៅឱ្យដល់សត្វទាំងឡាយ ជាលក្ខណៈ ។*

២. ***បរទុក្ខាបនយនកាមតាលក្ខណា ករុណា :*** *ករុណា មានការប្រាថ្នាបំបាត់ទុក្ខរបស់សត្វដទៃ ជាលក្ខណៈ*

៣. ***បរសម្បត្តិសម្មោទលក្ខណា មុទិតា :*** *មុទិតា មានការស្ងើចសសើរសម្បត្តិរបស់អ្នកដទៃ ជាលក្ខណៈ*

៤. ***ឥដ្ឋានិដ្ឋមជ្ឈត្តាការប្បវត្តិលក្ខណា ឧបេក្ខា :*** *ឧបេក្ខា មានការប្រព្រឹត្តិទៅដោយអាការជាកណ្ដាលក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ជាលក្ខណៈ ។*

ភាវនា មានមេត្តាជាដើម ឈ្មោះថា អប្បមញ្ញា ព្រោះមានសត្វមិនមានប្រមាណ ជាអារម្មណ៍, និងឈ្មោះថា ព្រហ្មវិហារ ព្រោះជាធម៌ដែលនៅប្រសើរបំផុត ឬព្រោះជាធម៌ជាទីនៅរបស់អ្នកប្រសើរបំផុត ។

## អធិប្បាយ អាហារេបដិកូលសញ្ញាជាដើម

សញ្ញាដែលប្រព្រឹត្តទៅថា "បដិកូលក្នុងកពឡិង្ការាហារដោយអំណាចការពិចារណាដោយកិច្ច មានការទៅ ការស្វែងរក និងការបរិភោគជាដើម" ឈ្មោះថា អាហារេបដិកូលសញ្ញា ។

<u>ក្នុងវិសុទ្ធមគ្គ ទុតិយភាគ</u> បានពោលថា ៖

អាការបដិកូល ក្នុងអាហាររបស់អ្នកចម្រើនសមថៈដើម្បីសង្កត់សង្កិននូវនីវរណៈ មាន ១០ យ៉ាង ដោយសង្ខេបដូចតទៅនេះ ៖

**១-គមនតោ** បដិកូលដោយការទៅ( ដើរទៅ )

**២-បរិយេសនតោ** បដិកូលដោយការស្វែងរក

**៣-បរិភោគតោ** បដិកូលដោយការបរិភោគ

**៤-អាសយតោ** បដិកូលដោយប្រឡូកប្រឡាក់

លាយជាមួយទឹកប្រមាត់ ស្លេស ខ្ទុះ ឈាម

**៥-និធានតោ** បដិកូលដោយក្រពះអាហារ

**៦-អបរិបក្កតោ** បដិកូលដោយនៅមិនទាន់រលួយ

**៧-បរិបក្កតោ** បដិកូលដោយរលួយហើយ

**៨-ផលតោ** បដិកូលដោយផលឱ្យកើតសក់

រោមជាដើម ឬឱ្យកើតរោគ

**៩-និស្សន្ទតោ** បដិកូលដោយហូរចេញ

**១០-សម្មក្ខនតោ** បដិកូលដោយការប្រឡាក់

ប្រឡូស

ចតុធាតុវវត្ថាន មានវិគ្រោះថា ការកំណត់ចែកធាតុ ៤ មានបឋវីធាតុជាដើម ដោយលក្ខណៈរបស់ខ្លួន និងដោយ

សម្ភារៈ[១] មានកេសាជាដើម ឈ្មោះថា ចតុធាតុវវត្ថាន ។

<u>ក្នុងវិសុទ្ធិមគ្គ ទុតិយភាគ</u> ពោលថា ៖

ចតុធាតុវវត្ថាន មាន ២ យ៉ាង គឺ ដោយសង្ខេប និង ដោយពិស្តារ ។

ដោយសង្ខេប សម្រាប់អ្នកមានប្រាជ្ញាវាងវៃ មានមកក្នុងមហាសតិប្បដ្ឋានសូត្រ[២] ។

ចំណែកដោយពិស្តារ សំរាប់អ្នកមានបញ្ញាមិនវាងវៃ មានមកនៅក្នុងមហាហត្ថិបទោបមសូត្រ[៣] ក្នុងរាហុលោវាទសូត្រ[២] និងធាតុវិភង្គសូត្រ[៣] ។

---

១. ក្នុងកន្លែងខ្លះពោលថា ធាតុ ៤ ឈ្មោះថា សម្ភារៈ, ចំណែកកោដ្ឋាសមានសក់ជាដើម ឈ្មោះថា សសម្ភារៈ ព្រោះប្រព្រឹត្តទៅជាមួយសម្ភារៈ ។
២. ទីឃ. មហា. ១៧. ១១៦/២៥៤ ។
៣. មជ្ឈិ. មូល. ២១. ៧៨/១៩៣ ។ ២. មជ្ឈិ. មជ្ឈិ. ២៣. ១៣៣/២២៩ ។ ៣. មជ្ឈិ. ឧប. ២៨. ១៤៨/១៧០ ។

ដែលព្រះអង្គទ្រង់សម្តែងដោយសង្ខេបច្រើន ក្នុងមហាសតិប្បដ្ឋានសូត្រនោះថា ៖

"ម្នាលភិក្ខុទាំងឡាយ បុរសអ្នកពិឃាតគោក្តី កូនសិស្សនៃបុរសអ្នកពិឃាតគោក្តី ដែលប៉ិនប្រសប់ គប្បីពិឃាតគោ ហើយរំលែកជាចំណែក ៗ អង្គុយនៅទៀបផ្លូវធំបែកជាបួន មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ដែលឋិតនៅយ៉ាងណា ដែលតាំងនៅ យ៉ាងណា ដោយកំណត់ថា **អត្ថិ ឥមស្មឹ កាយេ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ** : ក្នុងកាយនេះ មានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ មានឧបមេយ្យដូច្នេះឯង" ដោយប្រការ ដូច្នេះ ។

ចំណែកដោយពិស្តារ គប្បីពិនិត្យមើលក្នុងវិសុទ្ធិមគ្គ ឬនៅក្នុងសូត្រនោះ ៗ ។

**អារុប្ប** មានវិគ្រោះថា **អរូបេ អារម្មណេ បវត្តា** =

***អារុប្បា*** : ធម៌ទាំងឡាយ គឺ ចិត្តនិងចេតសិក ប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលមិនមានរូប ឈ្មោះថា អារុប្បា បានដល់អរូបជ្ឈានដែលមានកសិណុគ្ឃាដិមាកាសជាដើម ជាអារម្មណ៍ ។

ព្រះយោគាវចរ អ្នកជំនាញក្នុងចតុត្ថជ្ឈាន ប្រាថ្នានឹងចម្រើនអរូបកម្មដ្ឋាន ព្រោះឃើញទោសក្នុងករជរូប ដោយព្រះបាលីថា "**ទណ្ឌាទានសត្ថាទានកលហវិគ្គហវិវាទា** : ការកាន់ដំបង ការកាន់សស្ត្រា ការឈ្លោះប្រកែក ទាស់ទែងការវាយតប់គ្នា"[១] រមែងប្រាកដ ព្រោះមានរូបជាហេតុ តែទោសមានការកាន់ដំបងជាដើមនោះ រមែងមិនមាននៅក្នុងអរូបលោកពិចារណា យ៉ាងនេះហើយ រមែងជាអ្នកបដិបត្តិ ដើម្បីនឿយណាយក្នុងរូបទាំងឡាយ ដើម្បីកំចាត់នូវតម្រេកក្នុងរូបដើម្បីរំលត់ទៅនៃរូបទាំងឡាយ ដោយពិតប្រាកដ" ដូច្នេះក្តី,

---

១. ទីឃ. មហា. មហានិទានសុត្រ. ១៦. ៥៩/១២៥ ។

ឃើញទោស គឺ ការអាពាធ ១០០ យ៉ាង មានរោគភ្នែក រោគត្រចៀកជាដើមក្តី, ហើយញ៉ាំងចតុត្ថជ្ឈានឱ្យកើតឡើងក្នុង កសិណ មានបឋវីកសិណជាដើម យ៉ាងណាមួយ វៀរបរិច្ឆិន្នាកាសកសិណ ដើម្បីឈានកន្លងចេញនូវករជរូបនោះ ។ ពិតមែន ករជរូប ជាអារម្មណ៍របស់ព្រះយោគាវចរនោះ ឈានកន្លងហួសទៅហើយ ដោយអំណាច នៃរូបាវចរចតុត្ថជ្ឈាន ក៏ប៉ុន្តែ ព្រោះកសិណរូប (និមិត្តរបស់កសិណ) មានចំណែកដូចករជរូបនុ៎ះឯង ដូច្នោះ ទើបលោកប្រាថ្នា ដើម្បីនឹងឈានកន្លងរូបនោះទៀត ។ ប្រៀបដូចបុរសខ្លាចសត្វពស់ជាដើម ត្រូវពស់ក្នុងព្រៃដេញតាម ក៏គេចជៀសទៅ ដោយរហ័ស ឃើញស្លឹកត្នោតមានឆ្នូតជាស្នាម ដូចសត្វពស់ ឬវល្លិ ឬខ្សែឃើញ ស្នាមដីបែកក្រហែងក្តី ក្នុងទីកន្លែងដែលខ្លួនគេចទៅ រមែងខ្លាច រមែងតក់ស្លុត មិនចង់ឃើញឡើយ

យ៉ាងណា ឧបមាដូចជាគ្រឿងប្រៀបធៀបឱ្យឃើញនេះ បណ្ឌិតគប្បីជ្រាបយ៉ាងនោះ ។

ក៏ក្នុងវេលាដែលភិក្ខុព្រមព្រៀងដោយករជរូប ដោយអំណាចនៃអារម្មណ៍ ដូចវេលាដែលបុរសនោះត្រូវសត្វពស់កាចដេញតាម, វេលាដែលភិក្ខុឈានកន្លងករជរូប ដោយអំណាចនៃរូបាវចរចតុត្ថជ្ឈាន ដូចបុរសគេចជៀសទៅដោយរហ័ស ។ សេចក្ដីដែលភិក្ខុកំណត់ថា "សូម្បីកសិណរូបនេះ ក៏មានចំណែកដូច ករជរូបទុំះឯង" ដូច្នេះ ហើយប្រាថ្នានឹងឈានកន្លងកសិណរូបនោះទៀត ដូចសេចក្ដីដែលបុរសនោះ ឃើញរបស់( ផ្សេង )ដូចជាសត្វពស់ មានស្លឹកត្នោតជាដើម រមែងភ័យខ្លាច មិនចង់ឃើញទៀត ដូច្នោះ ។

ព្រះយោគាវចរនោះ នឿយណាយចាកកសិណរូបដែលជាអារម្មណ៍របស់ចតុត្ថជ្ឈាននោះហើយ ជាអ្នកប្រាថ្នាដើម្បីជៀសទៅ ជាអ្នកជំនាញក្នុងវសី ៥ ចូលឈាននិងចេញចាក

រូបាវចរចតុត្ថជ្ឈាន យ៉ាងរហ័សរហួន ឃើញទោសក្នុងឈាន នោះថា “ឈាននេះ ធ្វើរូបដែលយើងនឿយណាយហើយ ឱ្យជាអារម្មណ៍” ដូច្នេះខ្លះ “ឈាននេះ មានសត្រូវ គឺសោមនស្សនៅជិត” ដូច្នេះខ្លះ និងថា “ឈាននេះ គ្រោតគ្រាតជាង សន្តិវិមោក្ខ” ដូច្នេះខ្លះ ។

លុះព្រះយោគាវចរនោះឃើញទោស នៅក្នុងរូបាវចរចតុត្ថជ្ឈាននោះ យ៉ាងនេះហើយ កាត់ការជាប់ជំពាក់ធ្វើនៅក្នុងចិត្ត ដល់អាកាសានញ្ចាយតន ដោយសេចក្តីជាធម៌ស្ងប់ ហើយផ្សាយកសិណទៅ រហូតដល់កណ្តាប់ចក្រវាឡ ឬរហូតដល់ទីកន្លែងតាមដែលខ្លួនត្រូវការ មនសិការនូវឱកាសកសិណរូបនោះផ្សាយទៅដល់ថា “អាកាសោ អាកាសោ” ឬ “អនន្តោ អាកាសោ” ដូច្នោះ ឈ្មោះថា រមែងញុំាំងកសិណឱ្យបើក ក៏ឯពេលបើកកសិណ មិនមែន មូរយកដូចមូរកន្ទេលទេ មិនមែនលើកចេញ ដូចលើកនំចេញពីអំបែងទេ ត្រឹមតែមិនគិត

ដល់ មិនមនសិការដល់ មិនពិចារណាដល់កសិណនោះឯង កាលមិនគិត មិនមនសិការ មិនពិចារណា ត្រឹមតែមនសិការដល់ឱកាសដែលកសិណរូបនោះ ផ្សាយទៅហើយតែម្យ៉ាងថា "អាកាសោ អាកាសោ" ដូច្នេះ ឈ្មោះថា រមែងបើកកសិណ ។ សូម្បីកសិណសោត ពេលត្រូវបើក ក៏មិនមែនហូតចេញ មិនបានឱ្យខ្ទាត់ខ្ទាយ គ្រាន់តែអាស្រ័យការមិនធ្វើទុកក្នុងចិត្តដល់កសិណរូបនេះតែម្យ៉ាង និងធ្វើក្នុងចិត្តថា "អាកាសោ អាកាសោ" ដូច្នោះ ក៏ឈ្មោះថា កសិណរូបដែលព្រះយោគីនោះ បើកចេញហើយ ហេតុខាងដើមនៃកសិណុគ្ឃាដិមាកាស ទើបប្រាកដ ។

ពាក្យថា **កសិណុគ្ឃាដិមាកាសំ** ( អាកាសដែលបើកកសិណ )ក្តី ពាក្យថា **កសិណផុដ្ឋោកាសោ** ( ឱកាសដែលកសិណផ្សាយទៅ )ក្តី ពាក្យថា **កសិណវិវិត្តោកាសំ** ( ឱកាសដែលទទេចាកពីកសិណរូប )ក្តី ទាំងអស់ដូចតែគ្នានោះឯង ។

## អធិប្បាយ កម្មដ្ឋានដែលសមគួរនឹងចរិត

ឥឡូវនេះ ដើម្បីនឹងសម្ដែងកម្មដ្ឋានដែលសមគួរដល់ចរិតរបស់បុគ្គលនោះ ៗ ទើបលោកអាចារ្យបានពោលពាក្យជាដើមថា "ក៏ក្នុងបណ្ដាចរិតទាំងឡាយ" ដូច្នេះ ។

បុគ្គលដែលឈ្មោះថា រាគចរិត ព្រោះអត្ថថា មានរាគៈ ជាចរិត គឺ ជាប្រក្រតី បានដល់ មនុស្សមានរាគៈជាយ៉ាងច្រើន ។ អសុភកម្មដ្ឋាន ជាសប្បាយដល់មនុស្សរាគៈចរិតព្រោះអសុភកម្មដ្ឋាន ជាសត្រូវដោយត្រង់ចំពោះរាគ ។

**អានាបានៈ** ជាសប្បាយដល់មនុស្សមោហចរិត និងមនុស្សវិតក្កចរិត ព្រោះអានាបានៈ ជាបដិបក្ខចំពោះមោហៈដោយសេចក្ដីដែលអានាបានៈនោះ ជាអារម្មណ៍នៃសេចក្ដីដឹងនិងព្រោះហាមការឆ្លេឆ្លារបស់វិតក្កចរិតបាន ។

អនុស្សតិ ៦ ខាងដើម មានពុទ្ធានុស្សតិជាដើម ជាសប្បាយដល់មនុស្សសទ្ធាចរិត ព្រោះជាហេតុនៃការចម្រើន

សទ្ធា ។

កម្មដ្ឋាន ៤ គឺ មរណៈ ឧបសមៈ ( សេចក្ដីស្ងប់ ) សញ្ញា និងវវត្ថានៈ ជាសប្បាយដល់មនុស្សពុទ្ធិចរិត ព្រោះជាអារម្មណ៍នៃសេចក្ដីដឹងដោយពិត និងព្រោះមានសភាវកាន់តែល្អិត ជ្រាលជ្រៅ ។

កម្មដ្ឋាន ១០ ដែលនៅសល់ គឺ ភូតកសិណ ៤ អាកាសកសិណ ១ អាលោកកសិណ ១ និងអរូបសមាបត្តិ ៤ ជាសប្បាយដល់មនុស្សមានចរិតគ្រប់យ៉ាង ។ បណ្ដាកម្មដ្ឋាន ( កសិណ )ទាំង ១០ នោះ កសិណដែលធំទូលាយជាសប្បាយដល់មនុស្សមោហចរិត ព្រោះក្នុងឱកាសដែលតូចចង្អៀត ចិត្តក៏រឹងរឹតតែវង្វេងខ្លាំងឡើង ។ រង្វង់កសិណដែលតូចចង្អៀត ជាសប្បាយដល់មនុស្សវិតក្កចរិត ព្រោះអារម្មណ៍ធំជាបច្ច័យឱ្យវិតក្កៈរត់ឆ្វេឆ្វាបាន ។

ក៏ពាក្យថា អសុភ ១០ នេះ លោកអាចារ្យពោលទុក

ព្រោះជាសត្រូវដោយត្រង់ និងព្រោះជាសប្បាយដ៏ក្រៃលែង ។

ពិតមែន ដែលឈ្មោះថា ការចម្រើនកម្មដ្ឋាន មានកសិណាជាដើម នឹងមិនគ្របសង្កត់កិលេសមានរាគៈជាដើម ឬនឹងមិនជាឧបការដល់កុសលធម៌ មានសទ្ធាជាដើមផងរមែងមិនមាន ។

## អធិប្បាយ កម្មដ្ឋានដល់អប្បនា និងមិនដល់

ក្នុងសមថកម្មដ្ឋាន ៤០ អប្បនាមិនមានក្នុងកម្មដ្ឋាន ១០ គឺ អនុស្សតិ ៨ មានពុទ្ធានុស្សតិជាដើម (វៀរកាយគតាសតិ អានាបានស្សតិ) សញ្ញា ១ និងវវត្ថាន: ១ ព្រោះព្រះគុណរបស់ព្រះពុទ្ធជាដើម ជាបរមត្ថ[1] និងមានច្រើនអនេកប្រការ សូម្បីព្រះគុណតែមួយប្រការ ក៏ជារបស់

១. បរមត្ថអារម្មណ៍ ដល់អប្បនាមាន ៣ គឺ លោកុត្តរសមាធិ អរូបជ្ឈានទី២ និងទី៤ ។

ជ្រាលជ្រៅ សមាធិទើបមិនអាចតាំងនៅមាំ ដោយអំណាចនៃអប្បនា, សមាធិនោះមិនដល់អប្បនា រមែងតាំងមាំដោយសភាពជាឧបចារៈប៉ុណ្ណោះ ។ ប៉ុន្តែ លោកុត្តរសមាធិ អរូបជ្ឈានទី ២ និងទី ៤ រមែងដល់អប្បនា សូម្បីក្នុងអារម្មណ៍ដែលជាសភាវធម៌ ដោយអំណាចភាវនាវិសេស ។ ពិតមែន លោកុត្តរសមាធិ រមែងដល់អប្បនាបានដោយកម្លាំងតាមលំដាប់នៃវិសុទ្ធិភាវនា, អារុប្បសមាធិ រមែងដល់អប្បនាដោយអំណាចភាវនា ដែលឈានកន្លងនូវអារម្មណ៍ ។ ពិតមែន ពេលសមាធិអរូបជ្ឈានទី ៤ ដល់អប្បនាហើយទុំះឯងរមែងមានត្រឹមតែការឈានកន្លងនូវអារម្មណ៍ប៉ុណ្ណោះ ។

កម្មដ្ឋានដែលនៅសល់ ៣០ បានដល់ កម្មដ្ឋានមានបឋវីកសិណជាដើម រមែងនាំមកនូវអប្បនា ។ ដូចវិគ្រោះថា ឈាន ៥ បានដល់ កម្មដ្ឋានមានបឋវីកសិណជាដើមទាំងនោះ ព្រោះហេតុនោះ កម្មដ្ឋានមានបឋវីកសិណជាដើម ទើបឈ្មោះ

ថា មានឈាន ៥ គឺ ដល់អប្បនាទាំង ៥ ឈាន ។

អសុភ ១០ បានត្រឹមតែបឋមជ្ឈាន ។ ចិត្តរមែងប្រព្រឹត្តទៅ ក្នុងអសុភកម្មដ្ឋានបាននោះ ដោយកម្លាំងនៃវិតក្កៈតែម៉្យាង ដូចទូកអុំទៅក្នុងទន្លេ ដែលមានក្រសែទឹកកួចខ្លាំងដោយកម្លាំងនៃថ្នោល (ជួយដោល) ព្រោះការចម្រើនអសុភមានអារម្មណ៍បដិកូល ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **បឋមជ្ឈានិកា** ប្រែថា មានត្រឹមតែបឋមជ្ឈាន ព្រោះឈានដែលមិនមានវិតក្កៈ មិនកើតក្នុងអសុភកម្មដ្ឋាន ។

ការដែលមេត្តា ករុណា និងមុទិតា ប្រកបដោយសោមនស្សដែលជាបដិបក្ខ ចំពោះទោមនស្សតែម៉្យាងសមគួរហើយ ព្រោះមេត្តាជាដើម លះព្យាបាទ លះការបៀតបៀន លះការមិនត្រេកអរក្រៃលែង ដែលសហគតដោយទោមនស្ស ព្រោះដូច្នោះ អប្បមញ្ញា ៣ មានមេត្តាជាដើមទើបលោកអាចារ្យពោលថា "ចតុត្ថជ្ឈានិកា" ប្រែថា មានក្នុង

ឈានទី ៤, ឧបេក្ខា ទើបលោកអាចារ្យពោលថា "បញ្ចមជ្ឈានិកា" ប្រែថា មានក្នុងឈានទី ៥ ព្រោះឧបេក្ខាព្រហ្មវិហារ មិនកើតសហគតដោយសុខ. ព្រោះតត្រមជ្ឈត្តុបេក្ខា កើតឡើងដោយភាវនា ដែលលះការខ្វល់ខ្វាយទាំង ៣ ដែលប្រព្រឹត្តដោយអំណាចនៃមេត្តាជាដើមថា "សត្វទាំងឡាយទាំងពួង ចូរមានសេចក្តីសុខ ចូរផុតចាកទុក្ខ ចូរកុំព្រាត់ប្រាសពីសុខសម្បត្តិ ដែលខ្លួនបានហើយ" ដូច្នេះ ហើយប្រព្រឹត្តដោយអាការជាកណ្តាល ក្នុងសត្វទាំងឡាយ ដោយឃើញសត្វទាំងឡាយ មានកម្មជារបស់ខ្លួន ៗ ជាធម្មជាតិមានកម្លាំងខ្លាំងជាង ។

ក្នុងពាក្យថា **បរិកម្មនិមិត្ត ឧគ្គហនិមិត្ត** រមែងបានកម្មដ្ឋានគ្រប់យ៉ាង ដោយបរិយាយតាមសមគួរនោះ ៗ ពាក្យថា **យថារហំ** (តាមសមគួរ) គឺ ដោយសមគួរដល់អារម្មណ៍នោះ ៗ លោកអាចារ្យពោលថា "ដោយបរិយាយ"

ព្រោះអារម្មណ៍ខ្លះមិនប្រាកដច្បាស់ ។ ពិតមែន ចំពោះក្នុងកសិណ, អសុភៈ, កោដ្ឋាស គឺ កាយគតាសតិ, និងអានាបានស្សតិប៉ុណ្ណោះ មាននិមិត្តប្រាកដច្បាស់ ។

ពាក្យថា "ព្រះយោគីអាទិកម្មិកកាន់យកនិមិត្តក្នុងកសិណ មានមណ្ឌលនៃបឋវីជាដើម" អធិប្បាយថា ពេលព្រះយោគីជម្រះចតុបារិសុទ្ធិសីលឱ្យបរិសុទ្ធ ក្នុងខាងដើមមុន ហើយកាត់ផ្តាច់បលិពោធ ១០ យ៉ាង[១] ចូលទៅរកកល្យាណមិត្ត អ្នកប្រកបដោយគុណទាំងឡាយ មានភាពជាអ្នកគួរស្រលាញ់ គួរគោរព និងគួរសរសើរជាដើម ហើយរៀនយកកម្មដ្ឋាន ដែលសមគួរដល់ចរិតតាមប្រក្រតីរបស់ខ្លួន លះវិហារដែលមិនសមគួរ ១៨ យ៉ាង នៅក្នុងវិហារដ៏សមគួរ

---

១. គឺ អាវាស ត្រកូល លាភ គណៈ ការងារ ដើរផ្លូវ ញាតិ អាពាធ គន្ថៈ ឥទ្ធិឫទ្ធិ ។

ដែលប្រកបដោយអង្គ ៥ កាត់បលិពោធតូច ៗ មានការកោរសក់ និងកាត់ក្រចកជាដើម ហើយធ្វើវង្វង់កសិណ ខាងមុខ តាំងចិត្តទុកត្រង់ខ្យល់ដកដង្ហើមចូល-ចេញ ឬត្រង់កោដ្ឋាស គឺកាយគតាសតិជាដើម អង្គុយកាន់យកនិមិត្ត ក្នុងអារម្មណ៍នោះ ៗ មានបឋវីកសិណជាដើម តាមលំដាប់នៃការភាវនានោះ ដោយន័យនៃបរិកម្មថា **បឋវី បឋវី** ជាដើម ។ វិធីដែលគប្បីបដិបត្តិល្មមជាសង្ខេប ក្នុងទីនេះ មានត្រឹមតែប៉ុណ្ណោះ ។

ចំណែកភាវនាវិធីពិស្តារ គប្បីកាន់យកអំពីវិសុទ្ធិមគ្គ ត្រង់វគ្គដែលសម្តែងអំពីភាវនាចុះ ។ ពិតមែន ភាវនាទាំង ២ យ៉ាងនោះ លោកអាចារ្យពោលទុកក្នុងទីនេះ សង្ខេបច្រើន ។

## អធិប្បាយ ន័យនៃនិមិត្ត ៣

ពាក្យថា "ក៏ឯនិមិត្តនោះ ជាវត្ថុដែលចិត្តកំណត់បានល្អហើយ" អធិប្បាយថា បរិកម្មនិមិត្តនោះ ជាធម្មជាតិដែលចិត្តកំណត់ទុកដោយប្រពៃដោយអំណាចភាវនា តាមលំដាប់ដែលប្រព្រឹត្តទៅហើយដោយន័យពោលទុកយ៉ាងនេះ ។

ពាក្យថា "មកកាន់គន្លងនៃមនោទ្វារ" សេចក្តីថា ពេលព្រះយោគាវចរធ្មេចភ្នែកជិតអស់ ឬទៅក្នុងទីដទៃ មនសិការនិមិត្ត ដូចជារង្វង់កសិណតែម្តង មកកាន់គន្លងនៃជវនដែលប្រព្រឹត្តទៅក្នុងមនោទ្វារក្នុងខណៈនោះ ។

ពាក្យថា "ភាវនារមែងតាំងមាំ" បានដល់ ភាវនារមែងតាំងមាំ តាមដែលបានសម្រេចឯកគ្គតានៃចិត្តដោយពិសេស ។ សូម្បីបុគ្គល ក៏ជាអ្នកតាំងមាំដូចគ្នា ដោយអំណាចការតាំងមាំនៃចិត្ត ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា "ពេលព្រះយោគាវចរនោះ មានចិត្តតាំងមាំ ជា

សមាធិយ៉ាងនោះហើយ” ដូច្នេះ ។

ពាក្យថា **“តប្បដិភាគំ”** ( ប្រាកដដូចកសិណ ) នោះ គឺ អារម្មណ៍ដូចគ្នានឹងឧគ្គហនិមិត្ត ។ ពិតមែន អារម្មណ៍នេះ បណ្ឌិតហៅថា បដិភាគនិមិត្ត ព្រោះដូចគ្នានឹងឧគ្គហនិមិត្តនុ៎ះឯង តែបដិភាគនិមិត្តនោះ ជានិមិត្ត បរិសុទ្ធក្រៃលែងជាងឧគ្គហនិមិត្ត ។

ពាក្យថា **វត្ថុធម្មវិមុច្ចិតំ** : បញ្ញត្តិផុតចាកវត្ថុធម៌ សេចក្ដីថា អារម្មណ៍ផុតចាកបរមត្ថធម៌ ឬផុតចាកវត្ថុធម៌ គឺ ផុតទៅចាកពីកសិណដែលប្រព្រឹត្តទៅក្នុងវង្វង់កសិណ ឈ្មោះថា សម្រេចដោយភាវនា ព្រោះកើតអំពីភាវនា ។

ពាក្យថា **“សម្មប្បិតំ”** ស្ងប់ស្ងៀម បានដល់ អែបណែបជិតស្និទល្អ ។

ពាក្យថា **“តតោ បដ្ឋាយ”** ចាប់តាំងពីនោះ គឺ តាំងអំពីបដិភាគ និមិត្តកើតឡើង ។

## អធិប្បាយ វសី ៥

សេចក្ដីដែលអាច ក្នុងការនឹកដល់អង្គឈានជាប់តគ្នា មិនហួសពីជវនៃ ៤ ឬ ៥ និងភវង្គបន្ទិចបន្តួច ក្នុងលំដាប់នៃអាវជ្ជនៈដែលកើតឡើងក្នុងអារម្មណ៍មួយ ៗ មានវិតក្កៈអារម្មណ៍ជាដើម ក្នុងបណ្ដាអង្គនៃឈាន ៥ ឈ្មោះថា អាវជ្ជនវសិតា បានដល់ អាវជ្ជនវសី ។ (ក្នុងវិចារៈជាដើមដែលជាអារម្មណ៍ ក៏ន័យនេះឯង) ។

ការដែលអាច ដើម្បីចូលឈានក្នុងលំដាប់នៃអាវជ្ជនៈដែលកើតឡើង ដោយមិនហួសភវង្គបន្ទិចបន្តួចទៅ ក្នុងលំដាប់នៃភាពជាអ្នកប្រាថ្នានឹងចូល ឈ្មោះថា សមាបជ្ជនវសិតា បានដល់ សមាបជ្ជនវសី ។

ការដែលអាចកាត់ក្រសែភវង្គ (ភវង្គវេគំ) ហើយញ៉ាំងឈានឱ្យតាំងនៅបានរហូត តាមពេលដែលកំណត់ ដូចទំនប់កាត់ក្រសែទឹក ដែលមានក្រសែកួចខ្លួលខ្លាញ់ គឺ ភាពជាអ្នក

ប្រកបក្នុងការរក្សាឈានចិត្តទុក តពីការធ្លាក់ទៅជាភវង្គ ឈ្មោះថា អធិដ្ឋានវសិតា បានដល់ អធិដ្ឋានវសី ។

សេចក្តីដែលអាចចេញចាកឈាន មិនកន្លងហួសពេលដែលកំណត់ទុក ឈ្មោះថា វុដ្ឋានវសិតា ។ ម្យ៉ាងទៀត ការដែលអាចក្នុងការតម្រង់ឈានទុក មិនឱ្យហួសវេលាកំណត់ ឈ្មោះថា អធិដ្ឋានវសិតា ។ ការមិនចេញចាកឈានមុនវេលាដែលកំណត់ (គឺ នៅមិនទាន់ដល់វេលាដែលកំណត់) ហើយអាចចេញ ចាកឈានបានតាមវេលាកំណត់ទុក ឈ្មោះថា វុដ្ឋានវសិតា ។

ក៏**បច្ចវេក្ខណវសិតា** (បច្ចវេក្ខណវសី) ស្រេចហើយដោយភាពជាអ្នកជំនាញក្នុងអាវជ្ជនទ្ទុំះឯង ពិតមែន ជវនទាំងឡាយ ក្នុងលំដាប់នៃអាវជ្ជនទ្ទុំះឯង ឈ្មោះថា បច្ចវេក្ខណជវន (ជវនក្នុងការពិចារណា) ។

## អធិប្បាយរូបជ្ឈានលះអង្គដែលគ្រោតគ្រាតជាដើម

*ពាក្យថា "ដើម្បីលះអង្គដែលគ្រោតគ្រាត មានវិតក្កៈជាដើម" បានដល់ ដើម្បីការមិនកើតឡើងនៃអង្គ មានវិតក្កៈជាដើមដែលគ្រោតគ្រាត ក្នុងខណៈនៃឈានមានទុតិយជ្ឈានជាដើម ។*

*ពាក្យថា "តាំងសេចក្ដីព្យាយាម" គឺ ធ្វើបរិកម្ម ។ តែបណ្ឌិតគប្បីឃើញថា ឧបចារភាវនារបស់ព្រះយោគីនោះឈ្មោះថា សម្រេចហើយចាប់តាំងអំពីការគ្របសង្កត់សេចក្ដីត្រេកអរក្នុងអង្គ មានវិតក្កៈជាដើម ។*

*ពាក្យថា* **យថារហំ : តាមសមគួរ** *គឺ សមគួរដល់អារម្មណ៍ មានកសិណជាដើម ដែលជាអារម្មណ៍របស់ឈាននោះ ៗ ។*

*លោកអាចារ្យពោលថា "វៀរអាកាសកសិណចេញ" ដូច្នេះ ក៏ព្រោះកសិណ គឺ អាកាសមិនអាចបើកដកបាន ។*

បទថា **កសិណំ** បានដល់ បដិភាគនិមិត្តដែលជាកសិណ ។

បទថា **ឧគ្ឃាដេត្វា** បានដល់ លើកលែង ដោយអំណាចមិនធ្វើទុកក្នុងចិត្ត ។ ពាក្យថា "ពេលធ្វើបរិកម្មអាកាស ដែលខូនបានដោយអំណាចការមិនមានទីបំផុត " អធិប្បាយថា ពេលព្រះយោគីធ្វើបរិកម្ម ប្រារព្ធអាកាសថា "អាកាសមិនមានទីបំផុត, អាកាសមិនមានទីបំផុត" ដូច្នេះ តែមិនមែនធ្វើបរិកម្មថា "មិនមានទីបំផុត មិនមានទីបំផុត"តែម្យ៉ាងទេ, សូម្បីក្នុងវិញ្ញាណញ្ចាយតនៈ ក៏ន័យយ៉ាងនេះដែរ ។ លោកអាចារ្យទាំងឡាយពោលថា "ព្រះយោគីទោះបីមិនពោលថា **អនន្តំ** មិនមានទីបំផុត ក៏គួរធ្វើទុកក្នុងចិត្តថា **អាកាសោ អាកាសោ វិញ្ញាណំ វិញ្ញាណំ**" ដូច្នេះ ។

ពាក្យថា "ពេលធ្វើបរិកម្មអរូបទី ៣ ថា **សន្តមេតំ បណីតមេតំ** ដូច្នេះ អរូបជ្ឈានទី ៤ រមែងសម្រេច"

អធិប្បាយថា កាលព្រះយោគីចម្រើនកម្មដ្ឋានថា "អរូបទី ៣ នេះ ស្ងប់ អរូបទី ៣ នេះ ប្រណីត" ដូច្នេះ ក៏ព្រោះសេចក្តីដែលអរូបទី ៣ មានត្រឹមតែសភាព មិនមានជាអារម្មណ៍ ។

## កម្មដ្ឋាន ១០ មិនដល់អប្បនា

ពាក្យថា ***អវសេសេសុ ច : និងកម្មដ្ឋានដែលនៅសល់*** សេចក្តីថា ក្នុងកម្មដ្ឋាន ១០ គឺ អនុស្សតិ ៨ ខាងដើម មានពុទ្ធានុស្សតិជាដើម សញ្ញា ១ វវត្ថាន ១ ដែលសល់ពីកម្មដ្ឋាន ៣០ នាំមកនូវអប្បនា មានកសិណ ១០ ជាដើម ។ ពាក្យថា "ធ្វើបរិកម្ម" បានដល់ ការធ្វើបរិកម្មដោយវិធីដែលពោលហើយថា "ព្រះមានព្រះភាគ ព្រះអង្គនោះជាព្រះអរហន្ត ព្រោះហេតុយ៉ាងនេះ ជាព្រះសម្មាសម្ពុទ្ធ ព្រោះហេតុយ៉ាងនេះ"ជាដើម ។

ពាក្យថា "កាន់យកនិមិត្តនោះល្អហើយ" គឺ ពេល

កំណត់ និមិត្តបានដោយល្អដោយអំណាចនៃភាពជាអ្នកមានចិត្តបង្អោនទៅ សសៀរទៅ ជម្រាលទៅក្នុងគុណ មានគុណនៃព្រះសម្ពុទ្ធជាដើម ។

ពាក្យថា "បរិកម្មភាវនា រមែងតាំងមាំ" គឺ បរិកម្មភាវនា ជាធម៌តាំងមាំហើយ រមែងសម្រេច ។

ពាក្យថា "និងឧបចារសមាធិ រមែងកើតឡើង" បានដល់ ទាំងឧបចារៈសមាធិ ក៏គ្របសង្កត់នូវកិលេសទាំងឡាយមាននីវរណៈជាដើមកើតឡើង ។

ចប់ ន័យនៃកម្មដ្ឋាន ៤០

## អធិប្បាយ អភិញ្ញា ៥

ពាក្យថា "**អភិញ្ញាវសេន បវត្តមានំ** : ដែលប្រព្រឹត្តទៅដោយអំណាចអភិញ្ញា" សេចក្តីថា រូបាវចរបញ្ចមជ្ឈានទុំះ ៦ង ដែលប្រព្រឹត្តទៅដោយអំណាចអភិញ្ញាលោកិយ ៥ មាន

ឥទ្ធិវិធញ្ញាណជាដើម ដែលបណ្ឌិតហៅថា អភិញ្ញា ព្រោះអត្ថថា ដឹងក្រៃលែង គឺ ដឹងវិសេស ។

ពាក្យថា "ចេញចាកបញ្ចមជ្ឈាន ដែលជាបាទនៃអភិញ្ញា" អធិប្បាយថា ពេលព្រះយោគីហ្វឹកហាត់ចិត្ត ដោយអាការ ១៤ យ៉ាង មានកសិណានុលោមជាដើម ធ្វើឱ្យគួរដល់អភិនិហារ ហើយចូលរូបាវចរបញ្ចមជ្ឈានទុំះឯង ព្រោះប្រកបដោយឧបេក្ខា ឯកគ្គតា និងព្រោះភាវៈនៃឈានទី ៥ សមគួរជាបាទ គឺ បញ្ចមជ្ឈាន ដែលមានបឋវីកសិណជាដើមជាអារម្មណ៍ ជាបាទ គឺ ជាទីតាំងនៃអភិញ្ញា ហើយចេញចាកបញ្ចមជ្ឈាននោះ ។

ពាក្យថា "ពិចារណាអារម្មណ៍ មានរូបជាដើម ដែលនឹងគប្បីអធិដ្ឋាន" អធិប្បាយថា រំពឹងដល់រូបជាដើម មានចំនួនទាំងរយរូបជាដើម ដែលគួរអធិដ្ឋាន គឺ គួរធ្វើឱ្យជាប្រភេទផ្សេង ៗ ក្នុងវេលាបរិកម្មនៃឥទ្ធិវិធញ្ញាណក្តី, រំពឹងដល់

សំឡេងដែលផ្សេងដោយសំឡេងគ្រោតគ្រាត និងសំឡេងល្អិតក្នុងវេលាបរិកម្មនៃទិព្វសោតក្តី, រំពឹងដល់ចិត្តរបស់អ្នកដទៃ ដែលផ្សេងដោយចិត្តមានរាគៈជាដើម ដោយការឃើញពណ៌ដែលប្រព្រឹត្តទៅក្នុងហទយ ក្នុងវេលាបរិកម្មនៃចេតោបរិយញ្ញាណក្តី រំពឹងដល់ខន្ធដែលធ្លាប់អាស្រ័យនៅ ក្នុងកាលមុនដែលផ្សេងដោយចុតិចិត្តជាដើម ក្នុងភពមុន ៗ ក្នុងសម័យនៃបរិកម្មនៃបុព្វេនិវាសានុស្សតិញាណក្តី, រំពឹងដល់រូបដែលប្រព្រឹត្តទៅ ក្នុងទីដែលមានពន្លឺផ្សាយទៅដល់ ក្នុងសម័យនៃបរិកម្មនៃទិព្វចក្ខុក្តី ។

ពាក្យថា "ធ្វើបរិកម្ម" គឺ កាលធ្វើបរិកម្ម ដោយន័យថា "យើងចូរជាមួយរយនាក់, យើងចូរជាមួយរយនាក់" ។

ពាក្យថា "អារម្មណ៍មានរូបជាដើម" បានដល់ ក្នុងអារម្មណ៍ទាំងឡាយ ដែលផ្សេងដោយអារម្មណ៍ មានរូប, ឈានដែលជាបាទ, សំឡេង, ចិត្តរបស់អ្នកដទៃ, និងខន្ធ

ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាដើម ដែលជាអារម្មណ៍របស់បរិកម្ម ។

## អធិប្បាយ អារម្មណ៏របស់អភិញ្ញា ៥ ដោយសង្ខេប

ពិតមែន បណ្ដាអារម្មណ៍មានរូបជាដើម ឥទ្ធិវិធញាណមានអារម្មណ៍ ៦ យ៉ាង គឺ ឈានជាបាទ ១ រូបកាយ ១ និង អារម្មណ៍ ៤ មានសំឡេងជាដើម ក្នុងទីជាទីអធិដ្ឋាននូវរូបជាដើម ។

ចំណែកទិព្វសោត មានសំឡេងតែមួយជាអារម្មណ៍ ក៏ឯសំឡេងនោះ ជាបច្ចុប្បន្នារម្មណ៍ ។

ក៏នៅក្នុងបរចិត្តវិជាននៈ ព្រះអាចារ្យអ្នករចនាមហាអដ្ឋកថាពោលថា "ចិត្តប្រព្រឹត្តទៅក្នុងកាល ៣, ក្នុងបណ្ដាកាមាវចរចិត្តណាមួយ ដែលប្រព្រឹត្តទៅក្នុងអតីត ៧ ថ្ងៃ និងក្នុងអនាគត ៧ ថ្ងៃ ជាអារម្មណ៍ ។ ប៉ុន្តែអាចារ្យ

អ្នករចនា អដ្ឋកថាសង្គហៈពោលថា ខន្ធ ៤ ជាអារម្មណ៍របស់បរចិត្តវិជាននៈ ដូច្នេះខ្លះ[១] ។

សួរថា ក៏សេចក្ដីដែលបរចិត្តវិជាននៈនោះ មានចិត្តជាអារម្មណ៍បច្ចុប្បន្ន យ៉ាងណា ?

ឆ្លើយថា ក្នុងអដ្ឋកថាលោកប្រកបសេចក្ដីដែលបរចិត្តវិជាននៈនោះ មានចិត្តជាអារម្មណ៍បច្ចុប្បន្ន ដោយសន្តតិបច្ចុប្បន្ន និងអទ្ធានបច្ចុប្បន្នមុន ។ ចំណែកព្រះនន្ទាចារ្យ ពោលថា ព្រះយោគាវចរចេញចាកឈានដែលជា

---

១. ក្នុងបដ្ឋានព្រះមានព្រះភាគត្រាស់ថា **កុសលា ខន្ធា ឥទ្ធិវិធញ្ញាណស្ស ចេតោបរិយញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មុបគត-ញ្ញាណស្ស អនាគតំសញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ** : ពួកកុសលក្ខន្ធ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគតញ្ញាណ អនាគតំសញ្ញាណ ដោយអារម្មណបច្ច័យ ។

បាទហើយ មិនចែកអារម្មណ៍ មានអារម្មណ៍ដែលជាបច្ចុប្បន្ន ជាដើម ធ្វើបរិកម្មថា "យើងនឹងដឹងចិត្តរបស់បុគ្គលនេះតែ ម្យ៉ាងប៉ុណ្ណោះ" ហើយចូលឈានដែលជាបាទទៀត ចេញ ហើយ នឹកដល់ចិត្តដោយមិនប្លែកគ្នានុ៎ះឯង ក្នុងលំដាប់នៃ បរិកម្ម ៣ ឬ ៤ វារៈ នឹងដឹងចិត្តរបស់បុគ្គលដទៃបាន ដោយចេតោបរិយញ្ញាណ ដូចដឹងច្បាស់នូវរូបដោយទិព្វចក្ខុ ដូច្នោះ ។ ក្នុងខាងក្រោយ នឹងកំណត់ចិត្ត មានរាគៈជាដើម បានដោយកាមាវចរចិត្ត ដូចការកំណត់ពណ៌ទាំងឡាយ មាន ពណ៌ខៀវជាដើម ដូច្នោះ ក៏កិច្ចមានការបរិកម្មជាដើមទាំងអស់ ជាអារម្មណ៍របស់ចិត្តចំពោះមុខប៉ុណ្ណោះ មួយទៀត ទោស គឺ សេចក្តីដែលបរចិត្តវិជាននៈនោះ មានអារម្មណ៍ផ្សេង ៗ ក្នុង ឋានៈដែលមិនប្រាថ្នា នឹងមិនមាន ព្រោះប្រព្រឹត្តទៅដោយ អាការមិនផ្សេងគ្នា ។

+ បុព្វេនិវាសានុស្សតិញ្ញាណនេះ ព្រះដីកាចារ្យពោល

ថា ខន្ធដែលខ្លួននៅអាស្រ័យក្នុងកាលមុន នាមនិងគោត្រដែលជាប់ដោយខន្ធ និងព្រះនិព្វាន ជាអារម្មណ៍របស់បុព្វេនិវាសានុស្សតិញ្ញាណ ។

+ ទិព្វចក្ខុអភិញ្ញា មានរូបបច្ចុប្បន្នជាអារម្មណ៍តែម្យ៉ាង អភិញ្ញា ៥ ទាំងនេះ មានការចែកអារម្មណ៍ទុកដោយប្រការដូច្នេះ ។

ពាក្យថា "**យថា រហមប្បេតិ**" រមែងទៀង ត្រង់តាមសមគួរគឺ រូបាវចរ-បញ្ចមជ្ឈានអែបជិតជាប់ដោយសមគួរដល់បរិកម្មនោះ ៗឯង ។

## អធិប្បាយ សេចក្ដីផ្សេងគ្នានៃអភិញ្ញា ៥

ឥឡូវនេះ ដើម្បីនឹងសម្ដែងសេចក្ដីផ្សេងគ្នានៃអភិញ្ញាទាំងឡាយ ដោយសេចក្ដីផ្សេងគ្នានៃអារម្មណ៍នុ៎ះឯង ទើបលោកអាចារ្យពោលពាក្យថា **ឥទ្ធិវិធា** ជាដើម គប្បីជ្រាប

វិគ្រោះ ដូចតទៅ ៖

អភិញ្ញា ដែលឈ្មោះថា ឥទ្ធិវិធា( សម្ដែងឫទ្ធិផ្សេង ៗ ) ព្រោះអត្ថថា មានប្រភេទនៃឫទ្ធិទាំងឡាយ មានឫទ្ធិកើតអំពីការអធិដ្ឋានជាដើម ។ ដែលឈ្មោះថា ទិព្វសោត ព្រោះអត្ថថា សោត( ត្រចៀក )នោះផង ជាទិព្វផង ព្រោះដូចត្រចៀករបស់ពួកទេវតា[១] និងព្រោះជាធម្មជាតិ អាស្រ័យទិព្វវិហារធម៌ ( គឺ រូបាវចរបញ្ចមជ្ឈាន ) ។ ដែលឈ្មោះថា បរចិត្តវិជាននៈ ព្រោះអត្ថថា ជាហេតុដឹងចិត្តអ្នកដទៃ ។ ឈ្មោះថា បុព្វេនិវាសានុស្សតិ ព្រោះអត្ថថា តាមរលឹកដល់ខន្ធជាដើម ក្នុងកាលមុន គឺ ក្នុងអតីតភពដោយអំណាចដែលធ្លាប់រស់នៅរួចមកហើយ និងដោយអំណាចនៃស្ថានទីអាស្រ័យនៅដោយជាអារម្មណ៍ ក្នុងការបន្តភពរបស់ខ្លួន ។

---

១. ត្រចៀកទិព្វរបស់ពួកទេវតា មិនត្រូវរុំព័ទ្ធដោយទឹកប្រមាត់និងស្លេស្មជាដើម ទើបអាចទទួល អារម្មណ៍បានសូម្បីក្នុងទីឆ្ងាយ ។

ឈ្មោះថា ទិព្វចក្ខុ ព្រោះអត្ថថា ជាចក្ខុនោះផង ជាទិព្វផង ដោយន័យដែលពោលហើយ ព្រោះដូច្នោះ ទើបឈ្មោះថា ទិព្វចក្ខុ, ក៏ទិព្វចក្ខុនោះឯង បណ្ឌិតរមែងហៅថា ចុតូបបាត-ញាណ ។ សូម្បីយថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ រមែងសម្រេចដោយអំណាចទិព្វចក្ខុនុ៎ះឯង ។

ពិតមែនហើយ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណទាំងនោះ មិនមានបរិកម្មមួយផ្នែកផ្សេងទេ ។

ក្នុងញាណទាំង ២ នោះ អនាគតំសញ្ញាណ មានចិត្ត និងចេតសិកដែលប្រព្រឹត្តទៅខាងមុខ ៧ ថ្ងៃ ក្នុងអនាគតជាអារម្មណ៍មុន[១] និងមានធម៌យ៉ាងណាមួយ ដែលប្រព្រឹត្តទៅ

---

១. ចេតោបរិយញ្ញាណ ដឹងចិត្ត ១៦ គឺ ចិត្តមានរាគៈ ក៏ដឹងថា ចិត្តមានរាគៈជាដើម ប្រព្រឹត្តទៅក្នុងអតីត ៧ ថ្ងៃ ក្នុងអនាគត ៧ ថ្ងៃ អានាគតំសញ្ញាណដឹងធម៌ដែលជាអនាគតតែម្យ៉ាង ដោយន័យតាំងពីថ្ងៃទី ២ ជាដើមទៅ ១៥ ថ្ងៃទី ១ ត្រឹមតែជាបច្ចុប្បន្ន ដែលអ្វី ៗក្នុងអនាគត

តាំងពីថ្ងៃទី ២ ជាអារម្មណ៍ ។ ពិតមែន អនាគតំសញ្ញាណ នោះ លោកអាចារ្យពោលថា មានគតិដូចគតិនៃសព្វញ្ញុតញ្ញាណ ក្នុងអារម្មណ៍របស់ខ្លួន ។ ចំណែកយថាកម្មូបគញ្ញាណ បណ្ឌិតគប្បីឃើញថា មានកុសលចេតនា និងអកុសលចេតនា ឬខន្ធសូម្បីទាំង ៤ ជាអារម្មណ៍ ។ សេចក្តីផ្សេងគ្នានៃ អារម្មណ៍ ហៅថា គោចរភេទ ។

ចប់ ន័យក្នុងសមថកម្មដ្ឋាន

---

ឈ្មោះថា មិនជាអារម្មណ៍របស់អនាគតំសញ្ញាណ មិនមានឡើយ ដូច្នោះ ទើបលោកពោលថា មានគតិដូចគតិនៃសព្វញ្ញុតញ្ញាណ ។

# ២-វិបស្សនាកម្មដ្ឋាន

នៅក្នុងវិបស្សនាកម្មដ្ឋាន បណ្ឌិតគប្បីជ្រាប វិសុទ្ធិសង្គហៈ ដោយអាការ ៧ យ៉ាង គឺ ៖

១- សីលវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃសីល

២- ចិត្តវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃចិត្ត

៣- ទិដ្ឋិវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃទិដ្ឋិ

៤- កង្ខាវិតរណវិសុទ្ធិ សេចក្តីបរិសុទ្ធិ ព្រោះឈាន កន្លងសេចក្តីសង្ស័យ ១៦ យ៉ាង

៥- មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃ មគ្គាមគ្គញ្ញាណទស្សនៈ

៦- បដិបទាញ្ញាណទស្សនវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃ បដិបទាញ្ញាណទស្សនៈ

៧- ញ្ញាណទស្សនវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃញ្ញាណ ទស្សនៈ ។

-លក្ខណៈ ៣ គឺ អនិច្ចលក្ខណៈ ១ ទុក្ខលក្ខណៈ ១ និងអនត្តលក្ខណៈ ១ ។

-អនុបស្សនា ៣ គឺ អនិច្ចានុបស្សនា១ ទុក្ខានុបស្សនា ១ និងអនត្តានុបស្សនា១ ។

## វិបស្សនាញាណ ១០

| | |
|---|---|
| ១-សម្មសនញាណ | ៦-និព្វិទាញាណ |
| ២-ឧទយព្វយញាណ | ៧-មុញ្ចិតុកម្យតាញាណ |
| ៣-ភង្គញាណ | ៨-បដិសង្ខាញាណ |
| ៤-ភយញាណ | ៩-សង្ខារុបេក្ខាញាណ |
| ៥-អាទីនវញាណ | ១០-អនុលោមញាណ |

-វិមោក្ខ ៣ គឺ សុញ្ញតវិមោក្ខ ១ អនិមិត្តវិមោក្ខ ១ អប្បណិហិតវិមោក្ខ ១ ។

-វិមោក្ខមុខ ៣ គឺ សុញ្ញតានុបស្សនា ១ អនិមិត្តានុបស្សនា ១ និង អប្បណិហិតានុបស្សនា ១ ។

## ប្រភេទនៃវិសុទ្ធិ ៧

វិសុទ្ធិ ៧ តើគប្បីជ្រាបយ៉ាងណា ?

គប្បីជ្រាបថា បារិសុទ្ធិសីលមាន ៤ គឺ បាតិមោក្ខសំវរសីល ១ ឥន្ទ្រិយសំវរសីល ១ អាជីវបារិសុទ្ធិសីល ១ បច្ចយសន្និស្សិតសីល ១ ឈ្មោះថា សីលវិសុទ្ធិ ។

សមាធិទាំង ២ គឺ ឧបចារសមាធិ ១ និងអប្បនាសមាធិ ១ ឈ្មោះថា ចិត្តវិសុទ្ធិ ។

ការកំណត់នាម និងរូប ដោយអំណាចលក្ខណៈ, កិច្ច, បច្ចុប្បដ្ឋាន និងបទដ្ឋាន ឈ្មោះថា ទិដ្ឋិវិសុទ្ធិ ។

ការកំណត់បច្ច័យនៃនាម និងរូបទាំងនោះឯង ឈ្មោះថា កង្ខាវិតរណវិសុទ្ធិ ។

តពីនោះ ក៏កំណត់ចែកលក្ខណៈនៃមគ្គ (ផ្លូវ) ដោយអំណាចការកំណត់ដល់អន្តរាយ គឺ វិបស្សនូបកិលេស ១០ មានឱភាសជាដើម យ៉ាងនេះ គឺ

១.ឱភាស ២.បីតិ ៣.បស្សទ្ធិ ៤.អធិមោក្ខ ៥.បគ្គហៈ ៦.សុខ ៧.ញាណ ៨.បដ្ឋាន ៩.ឧបេក្ខា ១០.និកន្តិ របស់ព្រះយោគាវចរអ្នកប្រាជ្ញទូន័យ មានខន្ធជាដើមក្នុងសង្ខារ ដែលមានក្នុងភូមិ ៣ ព្រមទាំងបច្ច័យដែលផ្សេងគ្នា ដោយកាលមានអតីតកាលជាដើម ដែលខ្លួនកំណត់ហើយយ៉ាងនោះ រួបរួមឱ្យខ្លីហើយ ដោយអំណាចនៃកលាប(ជាពួកក្រុម) ហើយពិចារណាត្រៃលក្ខណ៍ ដោយសម្មសនញាណថា "នាមរូបមិនទៀង ព្រោះអត្ថថា អស់ទៅ, ជាទុក្ខ ព្រោះអត្ថថា ជាភ័យ, ជាអនត្តា ព្រោះអត្ថថា មិនមានខ្លឹមសារ". ដូច្នេះ ដោយអទ្ធានបច្ចុប្បន្ន ឬដោយអំណាចសន្តតិបច្ចុប្បន្ន ឬដោយអំណាចខណៈបច្ចុប្បន្ន និងតាមឃើញនូវការកើតឡើង និងរលត់ទៅ ក្នុងសង្ខារទាំងពួងនោះឯង ដោយឧទយព្វយញាណ ដោយអំណាចនៃបច្ច័យ និងដោយអំណាច

នៃខណៈចិត្ត ឈ្មោះថា មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ។

ក៏វិបស្សនាទាំង ៩ របស់ព្រះយោគាវចរនោះ អ្នកផុតចាកអន្តរាយហើយយ៉ាងនោះ ដំណើរឆ្ពោះទៅកាន់ត្រៃលក្ខណ៍ដោយបន្តនៃវិបស្សនា ចាប់ផ្តើមតាំងពីឧទយព្វយញ្ញាណរហូតដល់អនុលោមញ្ញាណ ឈ្មោះថា បដិបទាញ្ញាណទស្សនវិសុទ្ធិ ។

មគ្គញ្ញាណទាំង ៤ ឈ្មោះថា ញាណទស្សនវិសុទ្ធិ ។

ក៏កាលព្រះយោគាវចរនោះបដិបត្តិយ៉ាងនេះ វិបស្សនាចិត្ត ២-៣ ខណៈប្រារព្ធលក្ខណៈយ៉ាងណាមួយ មានអនិច្ចលក្ខណៈជាដើម រមែងប្រព្រឹត្តទៅ ដោយឈ្មោះថា បរិកម្មឧបចារ និងអនុលោម ក្នុងលំដាប់នៃមនោទ្វារាវជ្ជនៈដែលអាស្រ័យសេចក្តីចាស់ជុំវិញនៃវិបស្សនា (វិបស្សនាចាស់ក្លា) កាត់កវត្ត ដាច់ចុះហើយ កើតឡើងក្នុងខណៈដែលគួរពោល

ថា "អប្បនា នឹងកើតក្នុងពេលឥឡូវនេះ" ដូច្នេះ ។

វិបស្សនាណា ដល់ទីបំផុត វិបស្សនានោះ បណ្ឌិតហៅថា សានុលោម ហៅថា សង្ខារុបេក្ខា និងថា វុដ្ឋានគាមិនីវិបស្សនា ។ ខាងមុខពីនោះ គោត្រភូចិត្ត ក៏កាន់យកព្រះនិព្វានជាអារម្មណ៍ គ្របសង្កត់គោត្របុថុជ្ជននឹងដល់គោត្រព្រះអរិយ រមែងប្រព្រឹត្តទៅក្នុងលំដាប់នៃគោត្រភូចិត្តនោះ មគ្គរមែងធ្លាក់ចុះកាន់អប្បនាវិថី កំណត់ដឹងទុក្ខសច្ចៈ លះសមុទយសច្ចៈ ធ្វើនិរោធសច្ចៈឱ្យជាក់ច្បាស់ ដោយអំណាចនៃការចម្រើនមគ្គសច្ចៈ ។ តពីនោះ ផលចិត្ត ២-៣ ខណៈប្រព្រឹត្តទៅ ហើយក៏រលត់តពីនោះ ជាភវង្គបាតតែម្តង ។

ចំណែកបច្ចវេក្ខណញាណទាំងឡាយ កាត់ភវង្គដាច់ក៏ប្រព្រឹត្តទៅទៀត ។

## សង្គហគាថា សរុបវិសុទ្ធិ ៧

៣. មគ្គំ ផលញ្ច និព្ពានំ បច្ចវេក្ខតិ បណ្ឌិតោ

បហីនេ ក្លេសេ ច បច្ចវេក្ខតិ វា ន វា ។

៤. ឆព្វិសុទ្ធិក្កមេនេវំ ភាវេតព្វោ ចតុព្វិធោ

ញាណទស្សនវិសុទ្ធិ នាម មគ្គោ បវុច្ចតិ ។

*អរិយបណ្ឌិត រមែងពិចារណាមគ្គ ផល និងនិព្វាន តពីនោះ រមែងពិចារណាកិលេសដែលលះបានហើយ និងកិលេសដែលនៅសល់ លោកខ្លះក៏ពិចារណា លោកខ្លះក៏មិនពិចារណា ។ មគ្គទាំង ៤ ដែលព្រះអរិយបុគ្គល គប្បីធ្វើឱ្យកើត ដោយលំដាប់នៃវិសុទ្ធិ ៦ ដោយអាការយ៉ាងនេះ ឈ្មោះថា ញាណទស្សនវិសុទ្ធិ ។*

*ចប់ ប្រភេទវិសុទ្ធិ ៧*

## ប្រភេទនៃវិមោក្ខ

ក្នុងឧទ្ទេសដោយន័យដែលពោលហើយនោះ អនត្តានុបស្សនា លះនូវសេចក្ដីប្រកាន់មាំ ក្នុងសង្ខារទាំងឡាយថាអត្តា ឈ្មោះថា សុញ្ញតានុបស្សនា ជាវិមោក្ខមុខ (គឺ ជាផ្លូវនៃការរួចផុត) អនិច្ចានុបស្សនា លះនូវវិបល្លាសនិមិត្ត ឈ្មោះថា អនិមិត្តានុបស្សនា ជាវិមោក្ខមុខ ។ ទុក្ខានុបស្សនា លះនូវតណ្ហាបណិធិ (សេចក្ដីតាំងនៅនៃតណ្ហា) ឈ្មោះថា អប្បណិហិតានុបស្សនា ជាវិមោក្ខមុខ ។ ព្រោះដូច្នោះ មគ្គទើបបានឈ្មោះ ៣ យ៉ាង ដោយអំណាចនៃការចូលដល់វិបស្សនា គឺ ៖

បើវុដ្ឋានគាមិនីវិបស្សនា ឃើញច្បាស់នូវសង្ខារដោយសភាពជាអនត្តា មគ្គ ក៏ឈ្មោះថា សុញ្ញតវិមោក្ខ ១ ។

បើវុដ្ឋានគាមិនីវិបស្សនា ឃើញច្បាស់ដោយសភាពមិនទៀង, មគ្គ ក៏ឈ្មោះថា អនិមិត្តវិមោក្ខ ១ ។

បើវុដ្ឋានគាមិនីវិបស្សនា ឃើញច្បាស់ដោយសភាពជាទុក្ខ, មគ្គ ក៏ឈ្មោះថា អប្បណិហិតវិមោក្ខ ១ ។

និងផលក្នុងមគ្គវិថី ក៏មានឈ្មោះយ៉ាងនោះ ដោយអំណាចនៃការចូលដល់មគ្គ ។ ក៏ផល សូម្បីកើតឡើងតាមកិច្ចរបស់ខ្លួនដល់ព្រះយោគីអ្នកឃើញច្បាស់ ក្នុងផលសមាបត្តិវិថី ដោយន័យដែលពោលហើយ លោកហៅថា វិមោក្ខមានសុញ្ញតវិមោក្ខជាដើម ដោយអំណាចនៃការចូលដល់វិបស្សនាដូចគ្នា ។ ចំណែកឈ្មោះទាំង ៣ មានសុញ្ញតវិមោក្ខជាដើមដូចគ្នាតែម្តង. សូម្បីមគ្គនិងផលទាំងអស់ ទាំងក្នុងវិថី និងផលសមាបត្តិវិថីគ្រប់ប្រការ ដោយអំណាចនៃអារម្មណ៍ និងដោយអំណាចកិច្ចរបស់ខ្លួនទុំះឯង ។

ចប់ ប្រភេទនៃវិមោក្ខ

## ប្រភេទនៃបុគ្គល

បណ្ដាព្រះអរិយបុគ្គលទាំងនោះ ព្រះអរិយបុគ្គលដែលឈ្មោះថា សោតាបន្ន បានលះបង់ការទៅកាន់អបាយហើយ មានការកើតត្រឹមតែ ៧ ជាតិទៀត ជាយ៉ាងក្រៃលែង ព្រោះបានញ៉ាំងសោតាបត្តិមគ្គ ឱ្យកើតឡើងហើយ លះទិដ្ឋិ និងវិចិកិច្ឆាចេញបាន ។

ព្រះអរិយបុគ្គល អ្នកមកនៅក្នុងលោកនេះ ត្រឹមតែម្ដងទៀតប៉ុណ្ណោះ, ឈ្មោះថា សកទាគាមី ព្រោះបម្រើនសកទាគាមិមគ្គហើយ ធ្វើរាគៈ ទោសៈ និងមោហៈឱ្យស្រាលស្តើង ។

ព្រះអរិយបុគ្គលឈ្មោះថា អនាគាមី ព្រោះចម្រើនអនាគាមិមគ្គហើយ លះកាមរាគៈ និងព្យាបាទ ដោយមិនមានសេសសល់ មិនមកកាន់ភាពជាយ៉ាងនេះទៀតឡើយ ។

ព្រះអរិយបុគ្គលឈ្មោះថា អរហន្ត ព្រោះចម្រើនអរហត្តមគ្គហើយ លះកិលេសមិនមាននៅសល់អស់អាសវៈ

ហើយ ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរក្នុងលោក ។

ចប់ ប្រភេទនៃបុគ្គល

## ប្រភេទនៃសមាបត្តិ

បណ្ដាសមាបត្តិទាំងនោះ ផលសមាបត្តិ រមែងទូទៅ សូម្បីដល់ព្រះអរិយបុគ្គលទាំងអស់ ដោយអំណាចនៃផល តាមដែលជារបស់ខ្លួន ៗ តែក្នុងការចូលនិរោធសមាបត្តិ រមែងមានបាន ( គឺ អាចកើត ) ដល់ព្រះអនាគាមី និងព្រះអរហន្តប៉ុណ្ណោះ ។ ក្នុងការចូលនិរោធសមាបត្តិនោះ ព្រះអនាគាមី ឬព្រះអរហន្ត ចូលមហគ្គតសមាបត្តិ មានបឋមជ្ឈានជាដើម ចេញហើយពិចារណាសង្ខារធម៌ដែលប្រព្រឹត្តទៅក្នុងសមាបត្តិនោះ ឃើញច្បាស់ក្នុងសមាបត្តិនោះ ៗ តាមលំដាប់ដំណើរទៅដរាបដល់អាកិញ្ចញ្ញាយតនៈ តពី

នោះ ក៏ធ្វើបុព្វកិច្ចមានការអធិដ្ឋានជាដើម ហើយចូលនេវសញ្ញានាសញ្ញាយតនៈ ។ ខាងមុខអប្បនាជវនៈ ២ ខណៈរបស់នេវសញ្ញានាសញ្ញាយតនៈនោះ ការបន្តរបស់ចិត្តក៏ធ្លាក់ចុះ តពីនោះ លោកឈ្មោះថា ជាអ្នកចូលនិរោធហើយ ។ ក្នុងវេលាចេញរបស់ព្រះអនាគាមី អនាគាមិផលចិត្ត និងព្រះអរហន្ត អរហត្តផលចិត្ត ប្រព្រឹត្តទៅត្រឹមតែមួយខណៈប៉ុណ្ណោះ ក៏ជាភវង្គបាតតែម្តង ។ តពីនោះ បច្ចវេក្ខណញាណទាំងឡាយ រមែងប្រព្រឹត្តទៅ ដូច្នេះឯង ។

## ចប់ ប្រភេទនៃសមាបត្តិ

## និង ចប់ ន័យនៃវិបស្សនាកម្មដ្ឋាន ត្រឹមតែប៉ុណ្ណោះ ។

## សង្គហគាថា

៥. ភាវេតព្វំ បនិច្ចេវំ ភាវនាទ្វយមុត្តមំ

បដិបត្តិរសស្សាទំ បត្ថយន្តេន សាសនេ ។

ក៏បុគ្គលដែលប្រាថ្នាសេចក្ដីត្រេកអររសនៃការបដិបត្តិក្នុងព្រះពុទ្ធសាសនា គប្បីចម្រើនភាវនា ២ យ៉ាង ដ៏ខ្ពង់ខ្ពស់បំផុត ដូចពណ៌នាមកយ៉ាងនេះ ។

*បរិច្ឆេទទី៩ ឈ្មោះថា កម្មដ្ឋានសង្គហវិភាគ ក្នុងបករណ៍ ឈ្មោះថា អភិធម្មត្ថសង្គហៈ ចប់ហើយ ដោយប្រការដូច្នេះឯង ៗ*

# អធិប្បាយ វិបស្សនាកម្មដ្ឋាន

## *ក្នុងអភិធម្មត្ថសង្គហដីកា*

*វិបស្សនា វចនត្ថៈថា* ***អនិច្ចាទិវសេន វិវិធាការេន បស្សតីតិ = វិបស្សនា អនិច្ចានុបស្សនាទិកា ភាវនាបញ្ញា :*** *ធម្មជាតិណា រមែងឃើញដោយអាការផ្សេង ៗ ដោយអំណាចលក្ខណៈមានការមិនទៀងជាដើម ព្រោះហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា វិបស្សនា បានដល់ ភាវនាបញ្ញា មានអនិច្ចានុបស្សនាជាដើម ។*

*កម្មដ្ឋានរបស់វិបស្សនានោះ ឬថា វិបស្សនានោះឯង ជា កម្មដ្ឋាន ព្រោះហេតុនោះ ទើបឈ្មោះថា វិបស្សនាកម្មដ្ឋាន ។ ក្នុងវិបស្សនាកម្មដ្ឋាននោះ វិសុទ្ធិសង្គហៈ រមែងមានដោយ អាការ ៧ យ៉ាង ព្រោះដូច្នោះ ទើបពោលថា សម្ព័ន្ធគ្នា ។*

## អធិប្បាយត្រៃលក្ខណ៍

គប្បីជ្រាបវិគ្រោះថា ដែលឈ្មោះថា លក្ខណៈ ព្រោះអត្ថថា ជាធម្មជាតិគួរកំណត់ ឬធម៌ជាគ្រឿងកំណត់ គឺអនិច្ចតា ព្រោះដូច្នោះ ទើបឈ្មោះថា អនិច្ចលក្ខណៈ ។

លក្ខណៈ គឺ សេចក្ដីទុក្ខ ពោលគឺ ការបៀតបៀនដោយការកើតឡើងនិងការវិនាសទៅ ព្រោះដូច្នោះ ទើបឈ្មោះថា ទុក្ខលក្ខណៈ ។

ការមិនមាននៃអត្តា ដែលពួកជនដទៃកំណត់ទុក ឈ្មោះថា អនត្តាលក្ខណៈ គឺ ការមិនមានអត្តានោះឯង ព្រោះដូច្នោះ ទើបឈ្មោះថា អនត្តលក្ខណៈ ។

ការពិចារណារឿយ ៗនូវលក្ខណៈ ៣ មានអនិច្ចលក្ខណៈជាដើម ឈ្មោះថា អនិច្ចានុបស្សនាជាដើម ។

# អធិប្បាយ វិបស្សនាញាណ ១០

+ ញាណដែលប្រព្រឹត្តទៅដោយអំណាចការពិចារណាធម៌មានខន្ធជាដើម ដោយកលាប ឈ្មោះថា សម្មសនញាណ ។

+ ញាណដែលប្រព្រឹត្តទៅដោយអំណាចការតាមឃើញការកើត និងការរលត់ ឈ្មោះថា ឧទយព្វយញាណ ។

+ ញាណដែលលែងចោល ( មិនកាន់យក ) នូវការកើតហើយប្រព្រឹត្តទៅក្នុងការរលត់ ឈ្មោះថា ភង្គញាណ ។

+ ញាណដែលប្រព្រឹត្តទៅដោយអំណាចការតាមឃើញសង្ខារទាំងឡាយ ជារបស់គួរខ្លាច ឈ្មោះថា ភយញាណ ។

+ ញាណដែលប្រព្រឹត្តទៅដោយអំណាចការត្រិះរិះពិចារណាសង្ខារទាំងឡាយ គួរខ្លាច ដែលឃើញហើយដោយការមានទោស ឈ្មោះថា អាទីនវញាណ ។

+ ញាណដែលប្រព្រឹត្តទៅដោយអំណាចការនឿយ

ណាយ ក្នុងសង្ខារទាំងឡាយ មានទោសដែលឃើញហើយ ឈ្មោះថា និព្វិទាញាណ ។

+ ញាណដែលប្រព្រឹត្តទៅដោយអំណាចការនឿយណាយហើយ ភាពជាអ្នកប្រាថ្នា ដើម្បីនឹងចេញឱ្យផុតពីសង្ខារទាំងឡាយ ឈ្មោះថា មុញ្ចិតុកម្យតាញាណ ។

+ ញាណដែលប្រព្រឹត្តទៅដោយអំណាចការកំណត់សង្ខារទាំងឡាយទៀត ដើម្បីជាឧបាយនៃការផុត ( ពីសង្ខារ ) ដល់ព្រម ឈ្មោះថា បដិសង្ខាញាណ ។

+ ញាណដែលព្រងើយ ប្រព្រឹត្តទៅដោយអំណាចការវៀរចាកសេចក្តីគួរខ្លាច និងសេចក្តីត្រេកអរក្នុងធម៌ទាំងឡាយដែលពិចារណាហើយ ឈ្មោះថា សង្ខារុបេក្ខាញាណ ។

+ ញាណដែលសមគួរដល់ ( អនុកូល គឺ ការសង្គ្រោះជួយជ្រោមជ្រែង ) ការសម្រេចកិច្ចនៃញាណទាំង ៩ ខាងដើម ( មានសម្មសនញាណជាដើម ) និង ដល់ពោធិ

បក្ខិយធម៌ ៣៧ ក្នុងខាងលើ ឈ្មោះថា អនុលោមញាណ ។

## អធិប្បាយ មគ្គមានឈ្មោះ ៣ យ៉ាង

មគ្គ ឈ្មោះថា សុញ្ញតៈ ព្រោះជាសភាពទទេចាកអត្តា, ឈ្មោះថា វិមោក្ខៈ ព្រោះអត្ថថា ផុតចាកកិលេស មានសញ្ញោជនជាដើម (ក្នុងអដ្ឋកថាជាសុញ្ញតវិមោក្ខ) ។

មគ្គ ឈ្មោះថា អនិមិត្តៈ ព្រោះមិនមាននិមិត្ត មាននិច្ចនិមិត្តជាដើម ។

មគ្គ ឈ្មោះថា អប្បណិហិត ព្រោះមិនមានការប្រាថ្នា គឺ មិនមានសេចក្តីប្រាថ្នាដោយតណ្ហា ។

# អធិប្បាយ វិសុទ្ធិ ៧

## អធិប្បាយ សីលវិសុទ្ធិ

*សីល* មានវចនត្ថៈថា បុគ្គលណា រមែងរក្សាសីល សីលនោះ រមែងញ៉ាំងបុគ្គលអ្នករក្សានោះ ឱ្យផុតចាកទុក្ខទាំងឡាយ មានអបាយភូមិជាដើម ព្រោះហេតុនោះ សីលនោះទើបឈ្មោះថា បាតិមោក្ខ, បាតិមោក្ខនោះឯង ឈ្មោះថា សំវរៈ ព្រោះការពារទុច្ចរិត មានកាយទុច្ចរិតជាដើម, និងឈ្មោះថា សីល ព្រោះអត្ថថា គឺ ជាទីតាំងទុកដោយប្រពៃនៃកាយកម្ម និងវចីកម្មនិងជាទីទទួលរងនៃកុសលធម៌ ព្រោះដូច្នោះ ទើបឈ្មោះថា បាតិមោក្ខសំវរសីល ។

សីលដែលប្រព្រឹត្តទៅដោយអំណាចនៃការសង្រួមនូវឥន្ទ្រិយទាំងឡាយ មានចិត្តជាគម្រប់ ៦ ក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ឈ្មោះថា ឥន្ទ្រិយសំវរសីល ។

សីលដែលប្រព្រឹត្តទៅដោយអំណាចនៃសេចក្តីបរិសុទ្ធិនៃ

អាជីវៈ ដោយវៀរចាកមិច្ឆាជីវៈ ឈ្មោះថា អាជីវបារិសុទ្ធិសីល ។

សីលដែលអាស្រ័យបច្ច័យទាំងឡាយ បានដល់ សីល គឺ ការពិចារណាដោយសេចក្ដីជាបច្ច័យទាំងនោះ មានប្រយោជន៍យ៉ាងនេះ ឈ្មោះថា បច្ចយសន្និស្សិតសីល ។

ឈ្មោះថា ចតុបារិសុទ្ធិសីល ព្រោះមាន ៤ យ៉ាង និង ព្រោះបរិសុទ្ធបានដោយសារការសម្ដែងអាបត្តិ ការសង្រួមឥន្ទ្រិយ ការស្វែងរក និងការពិចារណានូវបច្ច័យ ។

## អធិប្បាយ ចិត្តវិសុទ្ធិនិងទិដ្ឋិវិសុទ្ធិ

សមាធិ ឈ្មោះថា ចិត្តវិសុទ្ធិ ព្រោះការជម្រះចិត្តឱ្យបរិសុទ្ធហ្មត់ចត់ ដោយអំណាចឱ្យដល់ការប្រាសចាកនីវរណៈ ឬ ឈ្មោះថា ចិត្តវិសុទ្ធិ ព្រោះធ្វើពាក្យអធិប្បាយថា ព្រោះសមាធិដែលទ្រង់សម្ដែងដោយចិត្តជាប្រធានផង[១] ព្រោះ

១. ចិត្តេកគ្គតា គឺ សមាធិ ទ្រង់សម្ដែងដោយពាក្យថា ចិត្តសីសំ ចិត្ត

សមាធិចិត្តនោះ បរិសុទ្ធហើយផង ។

ការកំណត់ធម៌ដែលមានលក្ខណៈជាដើម លោកពោលទុកយ៉ាងនេះថា "ធម៌ទាំងឡាយ មានសភាពស្មើគ្នា ជាលក្ខណៈ, មានកិច្ច និងសម្បត្តិ ជារស, មានអាការ គឺការប្រាកដ និងផល ជាបច្ចុប្បដ្ឋាន" ដូច្នេះ កាលពោលពិស្ដារដោយន័យមានន័យជាដើមថា "ផស្សៈ មានការប៉ះខ្ទប់ជាលក្ខណៈ បឋវីមានភាពរឹង ជាលក្ខណៈ" ដូច្នេះ និងកាលពោលសង្ខេបដោយន័យជាដើមថា "នាម មានការបង្អោនទៅជាលក្ខណៈ រូបមានការប្រែប្រួល ជាលក្ខណៈ" ដូច្នេះ គឺការកំណត់សំដៅយកដោយអំណាចលក្ខណៈ មានបច្ចត្តលក្ខណៈជាដើម បានដល់ ការកំណត់ទុក្ខសច្ចៈ ។ ឈ្មោះថាទិដ្ឋិវិសុទ្ធិ ព្រោះធ្វើវិគ្រោះថា "ឈ្មោះថា ទិដ្ឋិ ព្រោះឃើញថា

---

ជាប្រធាន ។

ដែលឈ្មោះថា អត្តាដទៃក្រៅអំពីនាមរូប រមែងមិនមាន និង ឈ្មោះថា វិសុទ្ធិ ព្រោះជម្រះមន្ទិល គឺ អត្តទិដ្ឋិ” ដូច្នេះ ។

## ១-លក្ខណាទិចតុក្កៈរបស់ផស្សៈ

១-ផុស្សនលក្ខណោ ផស្សៈមានការប៉ះខ្ទប់ ជាលក្ខណៈ

២-សង្ឃដ្ដនរសោ មានការនាំមកប្រជុំ ជាកិច្ច

៣-សង្គតិបច្ចុប្បដ្ឋានោ មានការប្រជុំ ជាអាការប្រាកដ

៤-អាបាថគតវិសយបទដ្ឋានោ មានអារម្មណ៍មកកាន់គន្លង ជាបទដ្ឋាន ។

## ២-លក្ខណាទិចតុក្កៈរបស់បឋវី

១-កក្ខឡលក្ខណា បឋវីមានការរឹង ជាលក្ខណៈ

២-បតិដ្ឋានរសា មានការតាំងនៅមាំ ជាកិច្ច

៣-សម្បដិច្ឆន្នបច្ចុប្បដ្ឋានា មានការទទួលទុក ជាផល

៤-អវសេសធាតុត្តយបទដ្ឋានា មានធាតុ ៣ ដែលនៅសល់

ជាបទដ្ឋាន ។

## ៣_ លក្ខណាទិចតុក្កៈរបស់នាម

**១-នមនលក្ខណំ** នាមមានការបង្អោនទៅកាន់អារម្មណ៍ ជាលក្ខណៈ

**២-សម្បយោគរសំ** មានការប្រកបរួមគ្នា ជាកិច្ច

**៣-អវិនិព្ភោគបច្ចុប្បដ្ឋានំ** មានការមិនបែកចាកពីចិត្ត ជាផល

**៤-វិញ្ញាណបទដ្ឋានំ** មានវិញ្ញាណ ជាបទដ្ឋាន ។

## ៤_ លក្ខណាទិចតុក្កៈរបស់រូប

**១-រុប្បនលក្ខណំ** រូបមានការប្រែប្រួល ជាលក្ខណៈ

**២-វិកិរណរសំ** មានការខ្ចាត់ខ្ចាយ ជាកិច្ច

**៣-អព្យាកតបច្ចុប្បដ្ឋានំ** មានភាពជាព្យាកត ជាអាការប្រាកដ

**៤-វិញ្ញាណបទដ្ឋានំ** មានវិញ្ញាណ ជាបទដ្ឋាន ។

## អធិប្បាយ កង្ខាវិតរណវិសុទ្ធិ

ពាក្យថា **បច្ចយបរិគ្គហោ** : កំណត់បច្ច័យ បានដល់ការកំណត់បច្ច័យមានកម្មជាដើម ដែលសម្រេចហើយ ដោយប្រចក្សជាដើមនៃការប្រព្រឹត្តទៅរបស់នាមរូប ក្នុងកាលទាំង ៣ ដោយអំណាចនៃបច្ច័យដែលទូទៅ និងបច្ច័យដែលមិនទូទៅ (សាធារណាសាធារណវិសេស)[១] យ៉ាងនេះ គឺ ៖

នាមនិងរូបក្នុងបដិសន្ធិកាល រមែងកើតឡើងដោយអំណាចនៃហេតុ គឺ អវិជ្ជា តណ្ហា ឧបាទាន និងកម្មមុន ប៉ុន្តែ ក្នុងបវត្តិកាល រូបកើតឡើងដោយអំណាចនៃបច្ច័យ គឺ កម្ម ចិត្ត ឧតុ និងអាហារ, ចំណែកនាម កើតឡើងដោយអំណាចនៃបច្ច័យ មាននិស្សយប្បច្ច័យ និងអារម្មណប្បច្ច័យ

---

១. សាធារណបច្ច័យ មានអវិជ្ជានិងតណ្ហាជាដើម, អសាធារណបច្ច័យវិសេស មានយោនិសោ មនសិការជាដើម ។

មានចក្ខុ និងរូបជាដើម ដោយការផ្សេងគ្នា ។ កុសលរមែង កើតឡើងដោយចតុក្កសម្បត្តិ[១] មានយោនិសោមនសិការជា ដើម អកុសល រមែងកើតឡើងដោយបរិយាយផ្ទុយគ្នានៃ ចតុក្កសម្បត្តិ មានយោនិសោមនសិការៈជាដើម. វិបាករមែង កើតឡើងដោយអំណាចនៃកុសល និងអកុសល, អាវជ្ជន រមែងកើតឡើង ដោយអំណាចនៃ ភវង្គជាដើម, កិរិយាជវន រមែងកើតឡើងដោយអំណាចនៃសន្តានរបស់ព្រះខីណាស្រព យ៉ាងនេះ ដោយប្រការដូច្នេះឯង ជាការកំណត់សមុទយសច្ចៈ ឈ្មោះថា កង្ខាវិតរណវិសុទ្ធិ ព្រោះធ្វើវិគ្រោះថា "បញ្ញា ឈ្មោះថា កង្ខាវិតរណៈ ព្រោះឆ្លង គឺ ឈានកន្លងសេចក្តី សង្ស័យ ១៦ យ៉ាង[២] មានជាដើមថា ក្នុងអតីត កាលដ៏យូរ

---

១. ចតុក្កសម្បត្តិ គឺ ១.យោនិសោមនសិការ ( អត្តសមាបណិធិ ) ២.បដិរូប ទេសវាសៈ ៣.បុព្វេកតបុញ្ញតា ៤.សប្បុរិសូបស្សយ ។

២. មជ្ឈិ. មូល. សព្វាសវសំវរសូត្រ. ២០. ១២/២៥ សេចក្តីសង្ស័យ

អង្វែង យើងបានមានហើយទេហ្ន៎ ហើយសេចក្ដីសង្ស័យ ៨ យ៉ាង មានជាដើមថា ការសង្ស័យក្នុងព្រះសាស្ដា និងឈ្មោះថា វិសុទ្ធិ ព្រោះជម្រះមន្ទិល គឺ ទិដ្ឋិ (ឃើញថា) នាមរូបទាំងពីរនេះ មិនមានហេតុប្បច្ច័យ និងឃើញថា ជាវិសមហេតុ គឺ ហេតុស្មើគ្នា ដោយត្រៃលក្ខណៈ ក៏មិនមាន ។

## អធិប្បាយ មគ្គាមគ្គញាណទស្សនវិសុទ្ធិ

បន្ទាប់ពីការកំណត់បច្ច័យនោះ ការដែលព្រះយោគាវចរប្រារព្ធន័យ មានខន្ធនិងអាយតនៈជាដើម ក្នុងនាមរូបទាំងឡាយ ដែលខ្លួនកំណត់ហើយយ៉ាងនោះ គឺ ដែលកំណត់ដោយអំណាចការកំណត់បែកសភាវៈ មានបច្ចត្តលក្ខណៈជា

---

១៦ យ៉ាង ។ អភិ. សង្គ. សញ្ញោជនគោច្ឆក. ៧៩. ២២៤/១៦២ សេចក្ដីសង្ស័យ ៨ គឺ ពុទ្ធេ កង្ខតិ ។ បេ ។ បដិច្ចសមុប្បាទេ កង្ខតិ ។

ដើម និងដោយអំណាចនៃការកំណត់ចែកបច្ច័យដែលជាប់ទាក់ទងក្នុងភូមិ ៣ មានកាមភូមិជាដើម វៀរលោកុត្តរភូមិ ដែលផ្សេងគ្នាដោយកាល មានអតីតកាលជាដើម គឺ ប្រារព្ធន័យមានខន្ធជាដើមហើយ ដោយអំណាចខន្ធ ៥ ទ្វារ ៦ អារម្មណ៍ ៦ និងធម៌ដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ ជាដើម រួបរួមចូលដោយអំណាចនៃកលាប គឺ ដោយអំណាចការប្រមូលមក ហើយពិចារណាដល់លក្ខណៈ ៣ ដោយសម្មសនញ្ញាណ គឺ ដោយញាណដែលប្រព្រឹត្តទៅដោយអំណាចការពិចារណាកលាប ដែលប្រព្រឹត្តទៅដោយអំណាចការពិចារណាត្រៃលក្ខណ៍ ពោលគឺ អាការដែលមានហើយ ក៏មិនមានទេ គឺ ត្រូវការកើត និងការរលត់ បៀតបៀន និងមិនប្រព្រឹត្តទៅក្នុងអំណាច, ដោយអំណាចនៃកាលដ៏យូរ

---

ឬបរិច្ឆេទទី១ ទំព័រ ១៣៤ ។

អង្វែង មានអតីតកាលជាដើម ដោយអំណាចការបន្តរបស់ធម៌ដែលជាអតីតជាដើម និងដោយអំណាចនៃខណៈ មានខណៈដែលជាអតីតជាដើម ដោយន័យជាដើមថា "រូបណាដែលកើតហើយក្នុងអតីត រូបនោះ ក៏រលត់ទៅហើយក្នុងអតីតនុ៎ះឯង, រូបណា នឹងមានក្នុងអនាគត សូម្បីរូបនោះ ក៏នឹងរលត់ទៅក្នុងអនាគតដូចគ្នា, រូបណា ដែលជាបច្ចុប្បន្នរូបនោះ មិនទាន់ដល់អនាគត ក៏នឹងរលត់ក្នុងបច្ចុប្បន្ននោះ ដូចគ្នា, ធម៌ទាំងឡាយមានរូបខាងក្នុង រូបខាងក្រៅ រូបល្អិត រូបគ្រោតគ្រាត រូបថោកទាប រូបប្រណីតជាដើម" ក៏ដូចគ្នា ព្រោះដូច្នោះ រូបនោះ ឈ្មោះថា **អនិច្ចំ** គឺ ជារូបដែលមិនគួរប្រាថ្នា បានដល់ មិនគប្បីចូលដល់ ដោយអំណាចនៃភាវៈមានអត្ថាជាដើម ព្រោះអត្ថថា អស់ទៅ គឺ ព្រោះដល់ការអស់ទៅ, ឈ្មោះថា ទុក្ខ ព្រោះអត្ថថា គួរខ្លាច គឺ ព្រោះជាហេតុនៃការខ្លាច, ឈ្មោះថា អនត្តា ព្រោះអត្ថថា មិនមានខ្លឹម

សារ គឺ ព្រោះមិនមានអត្តា មានអត្តាដែលជាខ្លឹមសារជាដើម” ដូច្នេះ និងដោយន័យជាដើមថា “ភ្នែកមិនទៀង ត្រចៀកមិនទៀង ។ល ។ ចិត្តមិនទៀង, រូបមិនទៀង សំឡេងមិនទៀង ។ល ។ ធម្មារម្មណ៍មិនទៀង, ចក្ខុវិញ្ញាណមិនទៀង ។ល ។ មនោវិញ្ញាណមិនទៀង ជាទុក្ខ ជាអនត្តា” ដូច្នេះ ។

តែកាលសម្មសនញាណកើតឡើងហើយ ព្រះយោគាវចរអ្នកអារទ្ធវិបស្សក: (អ្នកមានវិបស្សនាប្រារព្ធហើយ) ក៏ពិចារណានូវការកើតនិងការរលត់ ក្នុងសង្ខារទាំងឡាយនោះទៀត ដោយឧទយព្វយញាណ ដោយអាការ ៥០ ដោយអាចឃើញការកើតនិងការរលត់នៃខន្ធ ៥ ខន្ធនីមួយ ៗ ១០ យ៉ាង គឺ ឃើញការកើតដោយអាការ ៥ យ៉ាង ការរលត់ដោយអាការ ៥ យ៉ាង គឺ ឃើញថា ឃើញ ៤ យ៉ាង ដោយអំណាចនៃបច្ច័យ, និងឃើញមួយយ៉ាងទៀត ដោយអំណាចនៃខណៈក្នុងខន្ធនីមួយ ៗ គឺ ដោយអំណាចនៃការ

កើតឡើងនៃបច្ច័យ និងការរលត់នៃបច្ច័យ ក្នុងរូបក្ខន្ធ[១] យ៉ាង
នេះ គឺ ៖

ការកើតឡើងនៃរូប ព្រោះកើតឡើងនៃអវិជ្ជា
ការកើតឡើងនៃរូប ព្រោះកើតឡើងនៃតណ្ហា
ការកើតឡើងនៃរូប ព្រោះកើតឡើងនៃកម្ម
ការកើតឡើងនៃរូប ព្រោះកើតឡើងនៃអាហារ
ការរលត់ទៅនៃរូប ព្រោះរលត់ទៅនៃអវិជ្ជា
ការរលត់ទៅនៃរូប ព្រោះរលត់ទៅនៃតណ្ហា
ការរលត់ទៅនៃរូប ព្រោះរលត់ទៅនៃកម្ម
ការរលត់ទៅនៃរូប ព្រោះរលត់ទៅនៃអាហារ

និងសូម្បីក្នុងវេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ ដកអាហារចេញ ដាក់ផស្សៈជំនួសយ៉ាងនេះថា "ព្រោះអវិជ្ជា,

---

១. ខុទ្ទ. បដិ. មហាវគ្គ. ៦៩. ១០៦/១២៥,

តណ្ហា, កម្ម, និងផស្សៈកើត វេទនាទើបកើត. ព្រោះអវិជ្ជា, តណ្ហា, កម្ម, និងផស្សៈរលត់ វេទនាទើបរលត់” ដូច្នេះ ។

ក្នុងវិញ្ញាណក្ខន្ធ[១] ដាក់នាមជំនួស យ៉ាងនេះថា

ការកើតឡើងនៃវិញ្ញាណ ព្រោះកើតឡើងនៃអវិជ្ជា

ការកើតឡើងនៃវិញ្ញាណ ព្រោះកើតឡើងនៃតណ្ហា

ការកើតឡើងនៃវិញ្ញាណ ព្រោះកើតឡើងនៃកម្ម

ការកើតឡើងនៃវិញ្ញាណ ព្រោះកើតឡើងនៃអាហារ

ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់ទៅនៃអវិជ្ជា

ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់ទៅនៃតណ្ហា

ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់ទៅនៃកម្ម

ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់ទៅនៃអាហារ

និងដោយអំណាចនៃខណៈ ដោយមិនបានជាប់ទាក់ទង

---

១. ខុទ្ទ. បដិ. មហាវគ្គ. ៦៩. ១១១/១២៨ ។

ដល់បច្ច័យទាំងឡាយ មានអវិជ្ជាជាដើម តែឃើញត្រឹមតែលក្ខណៈ គឺ ការកើតឡើង (និព្វត្តិលក្ខណៈ) និងឃើញត្រឹមតែលក្ខណៈ គឺការប្រែប្រួលទៅ (វិបរិណាមលក្ខណៈ) ក្នុងខណៈទាំងឡាយ ដែលជាបច្ចុប្បន្នប៉ុណ្ណោះ កាលកើតវិបស្សនូបកិលេស ១០ យ៉ាង មានឱភាសជាដើម គឺ

១. ឱភាស ពោលគឺ ពន្លឺភ្លឺស្វាង ផ្សាយចេញពីសរីរៈ កើតពីវិបស្សនាចិត្ត (ចិត្តសម្បយុត្តដោយវិបស្សនា) ។

២. បីតិ ៥ យ៉ាង មានខុទ្ទកាបីតិជាដើម កើតព្រមជាមួយ នឹងវិបស្សនាចិត្ត ។

៣. បស្សទ្ធិ ២ យ៉ាង ដោយអំណាចកាយបស្សទ្ធិ និងចិត្តបស្សទ្ធិ មានការរម្ងាប់សេចក្តីក្រវល់ក្រវាយកាយនិងចិត្តជាលក្ខណៈ ដែលកើតព្រមជាមួយនឹងវិបស្សនាចិត្តដូចគ្នា ។

៤. អធិមោក្ខ ពោលគឺ សទ្ធិន្ទ្រិយដែលមានកម្លាំង

៥. បគ្គហ ពោលគឺ វីរិយសម្ពោជ្ឈង្គៈ ដែលញ៉ាំងកិច្ច

នៃសម្មប្បធានឱ្យសម្រេច ។

៦. សុខដែលប្រណីតក្រៃលែង ។

៧. ញាណដែលជាវិបស្សនាប្រព្រឹត្តទៅក្នុងត្រៃលក្ខណ៍ ដូចជាវជិរាវុធ (អាវុធពេជ្រ) ដែលព្រះឥន្ទ្រទ្រង់គ្រវែងចុះមកហើយ ។

៨. សតិ ពោលគឺ ឧបដ្ឋាន[១] ជាសតិប្បដ្ឋានដែលអាចតាមរលឹកដល់កិច្ច ដែលខ្លួនធ្វើទុកមកយូរហើយជាដើម ។

៩. ឧបេក្ខាទាំងពីរ គឺ តត្រមជ្ឈត្តុបេក្ខា ដែលជាឧបេក្ខាសម្ពោជ្ឈង្គៈដែលកើតរួមជាមួយនឹងវិបស្សនា ប្រព្រឹត្តទៅដោយប្រពៃ និងអាវជ្ជនុបេក្ខា ក្នុងមនោទ្វារ ។

១០. រូបនិកន្តិ គឺ កាលវិបស្សនូបកិលេស ៩ យ៉ាង

---

១. វចនត្ថថា អារម្មណំ ឧបដ្ឋបេតីតិ = ឧបដ្ឋានំ ធម្មជាតិដែលញ៉ាំងអារម្មណ៍ ឱ្យចូលទៅតាំងទុក ឈ្មោះថា ឧបដ្ឋាន បានដល់ សតិប្បដ្ឋាន ។

មានឱភាសជាដើម រូបនិកន្តិ (ការប្រាថ្នាក្នុងរូប ពោលគឺឱភាសជាដើម) ដែលជាតណ្ហាល្អិត ធ្វើសេចក្ដីហួងហែងក្នុងឱភាសជាដើមនោះ ដោយន័យជាដើមថា "ឱភាស ដូច្នេះ មិនធ្លាប់កើតឡើងដល់យើង ក្នុងកាលមុនអំពីកាលនេះហ្ន៎" ដូច្នេះ

មួយទៀត កាលវិបស្សនូបកិលេស ១០ យ៉ាង មានឱភាសកើតឡើង ក៏មិនប្រកាន់ថា "ឱភាសជាដើម ដូច្នេះ មិនធ្លាប់កើតឡើងដល់យើងហ្ន៎ យើងជាអ្នកបានសម្រេចផលពិតប្រាកដហើយ" ដូច្នេះ ហើយកំណត់ គឺ វិនិច្ឆ័យលក្ខណៈនៃមគ្គ យ៉ាងនេះថា "ឱភាសជាដើមទាំងនេះ មិនមែនមគ្គ ព្រោះជាវត្ថុនៃតណ្ហា និងមានះ ដោយការពិត ជាវិបស្សនូបក្កិលេសទុំះឯង ក៏វិបស្សនាញាណដែលដំណើរទៅកាន់វិធីផុតចាកវិបស្សនូបក្កិលេស មានឱភាសជាដើមនោះ ជាមគ្គ" ដូច្នេះ ឈ្មោះថា មគ្គាមគ្គញាណទស្សនវិសុទ្ធិ ព្រោះដឹង គឺ ព្រោះឃើញមគ្គ និងមិនមែនមគ្គ (ផ្លូវ និងមិន

មែនផ្លូវ ) និងព្រោះជម្រះសេចក្តីសំគាល់ខុសក្នុងទីមិនមែនជាមគ្គថា ជាមគ្គឱ្យបរិសុទ្ធស្អាត ។

## អធិប្បាយ បដិបទាញាណទស្សនវិសុទ្ធិ

ពាក្យថា "**យាវានុលោមា : ដរាបដល់ទាំងអនុលោម** គឺ រហូតដល់ទាំងសច្ចានុលោមញាណ ។

ពាក្យថា "**នវវិបស្សនាញាណានិ : វិបស្សនាញាណ** ៩ សេចក្តីថា ញាណ ៩ នោះ គឺ

១- ញាណដែលដឹងការកើត និងការរលត់របស់ខន្ធទាំងឡាយ ឈ្មោះថា ឧទយព្វយញាណ ។

២- ញាណដែលលែងចោល ( មិនកាន់យក ) នូវការកើត ហើយពិចារណាត្រឹមតែការរលត់ ឈ្មោះថា ភង្គញាណ ។

៣- ញាណដែលសម្លឹងមើលអាការរបស់សង្ខារដែលប្រាកដហើយ ដោយអំណាចនៃភង្គជារបស់គួរខ្លាច ដូចការ

សម្លឹងមើលអាការរបស់សត្វកាច មានសីហជាដើមដែលគួរខ្លាច ដូច្នេះ ឈ្មោះថា ភយញាណ ។

៤- ញាណដែលសម្លឹងមើលអាការត្រង់ទោសនៃសង្ខារដែលខ្លួនឃើញហើយ ដោយអាការគួរខ្លាច យ៉ាងនោះ ដូចជាការឃើញទោសនៃផ្ទះដែលភ្លើងឆេះសព្វទាំងអស់ហើយ ដូច្នោះ ឈ្មោះថា អាទីនវញាណ ។

៥- ញាណដែលប្រព្រឹត្តទៅដោយការនឿយណាយក្នុងខន្ធដែលមានទោស ដែលឃើញហើយ ឈ្មោះថា និព្វិទាញាណ ។

៦- ញាណដែលប្រព្រឹត្តទៅដោយអំណាចជាអ្នកប្រាថ្នាដើម្បីនឹងចេញឱ្យផុតទៅពីធម៌ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ នោះ ដូចសត្វមានត្រីជាដើម ត្រូវការរួចផុតចាកគ្រឿងទាក់មានសំណាញ់ជាដើម ដូច្នោះ ឈ្មោះថា មុញ្ចិតុកម្យតាញាណ ។

៧- ញាណដែលប្រព្រឹត្តទៅដោយអំណាចនៃការ

ពិចារណារឿយ ៗ ក្នុងខន្ធ សូម្បីដែលមានទោសដែលខ្លួន ឃើញហើយ ដើម្បីញ៉ាំងឧបាយនៃការរួចផុត ឱ្យដល់ព្រមដូច បក្សីសមុទ្រ ដូច្នោះ ឈ្មោះថា បដិសង្ខានុបស្សនាញាណ ។

៨- ញាណដែលប្រព្រឹត្តទៅដោយអាការ គឺ ការ ព្រងើយកន្តើយក្នុងសង្ខារទាំងនោះដែលមានទោស ដែលខ្លួន ឃើញហើយ ដូចបុរសមានភរិយាលែងលះហើយ ដូច្នោះ ឈ្មោះថា សង្ខារុបេក្ខាញាណ ។

៩- ញាណទី ៩ គឺ សច្ចានុលោមិកញាណដែល ប្រព្រឹត្តទៅក្នុងមគ្គវិថី មុនគោត្រភូញាណ ដោយអនុលោម ដល់វិបស្សនាញាណ ៨ ដែលប្រព្រឹត្តទៅហើយក្នុងកាលមុន ព្រោះមានលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ជាអារម្មណ៍ និងដល់ពោធិបក្ខិយធម៌ ៣៧ ដែលនឹងសម្រេចក្នុងខណៈនៃ មគ្គខាងលើ ឈ្មោះថា អនុលោមញាណ ។

រួមជា ៩ ប្រការ ឈ្មោះថា បដិបទាញាណទស្សន

វិសុទ្ធិ ព្រោះជាបដិបទានៃការបរិសុទ្ធិរបស់ញាណទស្សនៈ ដោយអត្ថថា ដឹងត្រៃលក្ខណ៍ ដោយអត្ថថា ឃើញដោយប្រចក្ស និងព្រោះបរិសុទ្ធចាកពីធម៌ជាសត្រូវ ។

## អធិប្បាយ ញាណទស្សនវិសុទ្ធិ

សេចក្តីចាស់ក្លាជុំវិញនៃវិបស្សនា គឺ សង្ខារុបេក្ខាញាណ ដែលមកដល់ហើយ គឺ អាស្រ័យសង្ខារុបេក្ខាញាណនោះ ។

ពាក្យថា "អប្បនា នឹងកើតក្នុងកាលឥឡូវនេះ"

សេចក្តីថា ក្នុងខណៈដែលគួរពោលថា "ឥឡូវនេះ លោកុត្តរមគ្គ ពោលគឺ អប្បនា នឹងកើតឡើង" ដូច្នេះ ។

ពាក្យថា "**យង្កិញ្ចិ**" (ប្រែថា អនិច្ចលក្ខណៈជាដើម យ៉ាងណាមួយ) បានដល់ ក្នុងបណ្តាលក្ខណៈ ៣ ដែលសង្ខារុបេក្ខាញាណកាន់យកហើយ មួយលក្ខណៈប៉ុណ្ណោះ ឈ្មោះថា លក្ខណៈយ៉ាងណាមួយ ។ វិបស្សនាណា ដល់

ភាវៈដ៏ខ្ពស់បំផុត ដោយដល់ទីបំផុតនៃវិបស្សនា, វិបស្សនានោះ លោកហៅ ឈ្មោះថា សានុលោម ព្រោះប្រព្រឹត្តទៅជាមួយអនុលោមញាណ វិបស្សនានោះឯង ហៅថា សង្ខារុបេក្ខា ព្រោះព្រងើយក្នុងសង្ខារទាំងឡាយ និងហៅថា វុដ្ឋានគាមិនី ក៏ព្រោះដំណើរទៅកាន់មគ្គ ពោលគឺ ការចេញ ព្រោះចេញចាកអបាយភូមិជាដើម និងចេញចាកនិមិត្ត គឺ សង្ខារតាមសមគួរ ។

ពាក្យថា **អភិសម្ភោន្តំ : យាងឡើងកាន់គោត្រភូព្រះអរិយបុគ្គល** បានដល់ គោត្រភូចិត្ត ។

ពាក្យថា **បរិជានន្តោ : មគ្គកំណត់ដឹង** គឺ កំណត់ដឹងថា "ទុក្ខនេះ មានប៉ុណ្ណេះ មិនខ្វះ និងមិនលើសជាងនេះ" ។

ពាក្យថា **សច្ឆិករោន្តោ : ការធ្វើនិរោធសច្ចៈឱ្យច្បាស់** បានដល់ ការធ្វើឱ្យប្រចក្សដោយអំណាចការធ្វើឱ្យជាអារម្មណ៍ ។

ពាក្យថា **មគ្គសច្ចភាវនាវសេន : ដោយអំណាចការ**

**ចម្រើនមគ្គសច្ចៈ** បានដល់ ដោយអំណាចនៃការឱ្យសច្ចៈទី ៤ ពោលគឺ មគ្គសច្ចៈ ដែលបណ្ឌិតហៅថា អង្គនៃមគ្គសម្បយុត្តគ្នាជាបច្ច័យ មានសហជាតប្បច្ច័យជាដើម ចម្រើន ។ ការដែលញាណមួយប៉ុណ្ណោះ ធ្វើកិច្ច ៤ យ៉ាងឱ្យសម្រេចបាន បណ្ឌិតគួរទទួលរង ព្រោះការសម្តែងកិច្ច ៤ យ៉ាង មានការដេះប្រដេះជាដើមនៃប្រទីបជាដើម និងព្រោះព្រះបាលីដែលមកថា ៖

"យោ ភិក្ខវេ. ទុក្ខំ បស្សតិ ទុក្ខសមុទយម្បិ សោ បស្សតិ. ទុក្ខនិរោធម្បិ បស្សតិ. ទុក្ខនិរោធគាមិនី បដិបទម្បិ បស្សតិ ។ យោ ទុក្ខសមុទយំ បស្សតិ ទុក្ខម្បិ សោ បស្សតិ. ទុក្ខនិរោធម្បិ បស្សតិ. ទុក្ខនិរោធគាមិនី បដិបទម្បិ បស្សតិ ។ យោ ទុក្ខនិរោធំ បស្សតិ ទុក្ខម្បិ សោ បស្សតិ. ទុក្ខសមុទយម្បិ បស្សតិ. ទុក្ខនិរោធគាមិនី បដិបទម្បិ បស្សតិ ។ យោ ទុក្ខនិរោធគាមិនី បដិបទំ បស្សតិ ទុក្ខម្បិ

**សោ បស្សតិ. ទុក្ខសមុទយម្បិ បស្សតិ. ទុក្ខនិរោធម្បិ បស្សតិ** : ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ឃើញទុក្ខ, បុគ្គលនោះ ឈ្មោះថា ឃើញទុក្ខសមុទ័យផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង ។ បុគ្គលណា ឃើញទុក្ខសមុទ័យ, បុគ្គលនោះ ឈ្មោះថា ឃើញទុក្ខផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង ។ បុគ្គលណា ឃើញទុក្ខនិរោធ, បុគ្គលនោះ ឈ្មោះថា ឃើញទុក្ខផង ឃើញទុក្ខសមុទ័យផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង ។ បុគ្គលណា ឃើញទុក្ខនិរោធគាមិនីបដិបទា, បុគ្គលនោះ ឈ្មោះថា ឃើញទុក្ខផង ឃើញទុក្ខសមុទ័យផង ឃើញទុក្ខនិរោធផង ។ ”[១]

---

១. សំយុ. មហា. គវម្បត្តិសូត្រ. ៣៩. ៤១២/២៧១ ។

<u>ក្នុងវិសុទ្ធិមគ្គ</u>[១] សម្តែងថា ៖

មគ្គញាណតែមួយ ធ្វើកិច្ច ៤ មិនមុនមិនក្រោយ គឺព្រមគ្នា ប្រៀបដូចប្រទីប ធ្វើកិច្ច ៤ គឺ ៖

**១-វដ្តិ ឈាបេតិ** ដុតប្រឆេះឱ្យឆេះ

**២-អន្ធការំ វិធមតិ** កំចាត់សេចក្តីងងឹត

**៣-អាលោកំ បរិវិទំសេតិ** បញ្ចេញពន្លឺភ្លឺស្វាងស្វៃ

**៤-សិនេហំ បរិយាទិយតិ** ធ្វើប្រេងឱ្យអស់ទៅ ។

ពាក្យថា **ផលចិត្ត ២-៣ ខណៈប្រព្រឹត្តទៅ** សេចក្តីថា ព្រោះផលចិត្ត ២ ឬ ៣ ខណៈប្រព្រឹត្តទៅហើយក្នុងសន្តានសូម្បីមានកិលេសត្រូវកាត់ដាច់អស់ហើយ តាមសមគួរដល់ការកើតឡើងរបស់មគ្គ ដោយជាធម្មជាតិរម្ងាប់រំលត់សេចក្តីក្តៅក្រហាយ ដូចទឹកដែលបុគ្គលយកថ្នាំងទឹកចាក់ស្រោចក្នុងទី

---

១. វិសុទ្ធិ. ៣. ៤៦១/១៤០៣ ។

ដែលគេយកភ្លើងចេញហើយ ដើម្បីត្រូវការឱ្យកម្តៅរលត់ទៅ ដូច្នោះ មានពាក្យអធិប្បាយថា ព្រោះការប្រព្រឹត្តិទៅនៃផលចិត្តប៉ុណ្ណោះ ។

ពាក្យថា "បច្ចវេក្ខណញាណទាំងឡាយ" បានដល់ញាណដែលជាកាមាវចរមានមគ្គ និងផលជាដើមជាអារម្មណ៍ ដែលព្រះមានព្រះភាគទ្រង់សំដៅយកត្រាស់ទុកថា "កាលចិត្តរួចផុតហើយ ញាណ គឺ សេចក្តីដឹងថា ចិត្តរួចផុតហើយ រមែងមាន" ដូច្នេះ ។

## អធិប្បាយ សង្គហគាថាទី ៣

ឥឡូវនេះ ដើម្បីនឹងសម្តែងភូមិនៃបច្ចវេក្ខណៈ (ការពិចារណា) ទើបលោកអាចារ្យពោលពាក្យថា **"មគ្គំ ផលញ្ច"**ជាដើម បណ្តាមគ្គ និងផលជាដើមទាំងនោះ បណ្ឌិតរមែងពិចារណាមគ្គថា "យើងមកហើយ ដោយមគ្គនេះ"

ដូច្នេះ ។ ក្នុងលំដាប់នៃការពិចារណាមគ្គនោះ រមែងពិចារណានូវផលរបស់មគ្គនោះថា "អានិសង្ស ឈ្មោះនេះ យើងបានហើយ" ដូច្នេះ ។ ក្នុងលំដាប់នៃការពិចារណាផលនោះ រមែងពិចារណានិព្វានថា "ធម៌ឈ្មោះនេះ យើងធ្វើឱ្យជាក់ច្បាស់ដោយជាអារម្មណ៍" ដូច្នេះ ។ ក្នុងលំដាប់តពីការពិចារណា និព្វាននោះ ក៏ពិចារណា កិលេសទាំងឡាយដែលលះបានហើយថា "កិលេសទាំងឡាយ ឈ្មោះនេះ យើងលះបានហើយ" រមែងពិចារណាកិលេសដែលនៅសល់ថា "កិលេសទាំងនេះ នៅសល់ដល់យើង" ដូច្នេះ ។

បទថា **បច្ចវេក្ខតិ វា ន វា : រមែងពិចារណាខ្លះមិនពិចារណាខ្លះ** គឺ ព្រះសេក្ខៈខ្លះ លោករមែងពិចារណា, ខ្លះទៀត ក៏មិនពិចារណា អធិប្បាយថា ក្នុងការពិចារណាដល់កិលេសដែលលះបានហើយ និងនៅសល់នោះ រមែងប្រព្រឹត្តទៅតាមប្រាថ្នា ។

ពិតមែនហើយ ស្ដេចសក្យមហានាម ទូលសួរព្រះមានព្រះភាគ ដល់កិលេសដែលមិនទាន់បានលះថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ ទើបមានសេចក្ដីត្រិះរិះថា ចុះធម៌អ្វីហ្ន៎ នៅក្នុងសន្ដានដែលអាត្មាអញមិនទាន់លះបង់អស់"[១] ដូច្នេះ ។

តែការពិចារណាដល់កិលេសដែលនៅសល់ រមែងមិនមានដល់ព្រះអរហន្ត ព្រោះកិលេសទាំងឡាយ លោកលះបានអស់ហើយ ព្រោះដូច្នោះ បណ្ឌិតគប្បីឃើញថា "បច្ចវេក្ខណញ្ញាណ មាន១៩ គឺ ព្រះសេក្ខៈ ៣ពួក មានបច្ចវេក្ខណញ្ញាណ ១៥ សំរាប់ព្រះអរហន្ត មានបច្ចវេក្ខណញ្ញាណ ៤" ដូច្នេះ ។

ពាក្យថា **ដោយលំដាប់នៃវិសុទ្ធិ ៦ យ៉ាង** បានដល់ ដោយលំដាប់នៃវិសុទ្ធិ ៦ យ៉ាងនេះ គឺ វិសុទ្ធិ ២ ដែលជាមូល (ផ្ទៃឋាន) ដោយអំណាចនៃសីលវិសុទ្ធិ និងចិត្តវិសុទ្ធិ

១. មជ្ឈិ. មូល. ចូឡទុក្ខក្ខន្ធសូត្រ. ២០. ២០៩/៣៣៥ ។

ចំណែកវិសុទ្ធិ ៤ ជាសរីរៈ ដោយអំណាចនៃទិដ្ឋិវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ មគ្គាមគ្គញាណទស្សនវិសុទ្ធិ និងបដិបទាញាណទស្សនវិសុទ្ធិ ។ មគ្គ ឈ្មោះថា ញាណទស្សនវិសុទ្ធិ ព្រោះដឹង គឺ ព្រោះធ្វើឱ្យប្រចក្សនូវសច្ចៈ ៤ និងព្រោះបរិសុទ្ធចាកមន្ទិល គឺ កិលេស ។

ពាក្យថា **ឯត្ថ** ៖ ក្នុងអធិការនៃវិសុទ្ធិនេះ គឺ ក្នុងវិបស្សនាកម្មដ្ឋាន ។

កេចិអាចារ្យប្រៀបធៀបវិសុទ្ធិ ៧ ដូចការតាំងនៅនៃព្រះសថូប គឺ ចេតិយដែលជារបស់គួរគោរពបូជានោះ ទុកដូចតទៅនេះ ៖

-សីលវិសុទ្ធិ និងចិត្តវិសុទ្ធិទាំង ២ នេះ ប្រៀបដូចមូលស្ថាន (គ្រឹះ) របស់ព្រះសថូប ។

-ទិដ្ឋិវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ មគ្គាមគ្គញាណទស្សនវិសុទ្ធិ និងបដិបទាញាណទស្សនវិសុទ្ធិទាំង ៤ នេះ ប្រៀប

ដូចអគ្គព្រះសថូប ។

-ញាណទស្សនវិសុទ្ធិ (ទី ៧) ប្រៀបដូចឆត្រមាសប្រដាប់ ដោយរតនៈ ៧ ប្រការ ជាកំពូលរបស់ព្រះសថូបនោះ ដូច្នេះឯង[១] ។

## ចប់ អធិប្បាយវិសុទ្ធិ ៧

## អធិប្បាយ អនុបស្សនា ៣ នៃវិមោក្ខមុខ

ក្នុងអនុបស្សនាឧទ្ទេសនោះ អនុបស្សនា ដែលប្រព្រឹត្តទៅហើយថា "អនត្តាប៉ុណ្ណោះ លែងចោលនូវការប្រកាន់មាំក្នុងសង្ខារទាំងឡាយថា ជាអត្តា គឺ ការប្រកាន់មាំ បានដល់ការប្រកាន់មាំ យ៉ាងនេះថា ខ្លួនរបស់យើងនេះ ជាអ្នកធ្វើកម្ម

---

១.ម្យ៉ាងទៀត សីលវិសុទ្ធិ មានគុណប្រៀបដូចផែនដី ជាទីអាស្រ័យ, ចិត្តវិសុទ្ធិ គឺ សមាធិ ២ ប្រៀបដោយជើងទាំង ២ វិសុទ្ធិ ៤ ប្រៀបដូចសរីរៈ" វិសុទ្ធិទី ៧ ប្រៀបដូចសីស" ។

និងជាអ្នកសោយផលរបស់កម្ម” ដូច្នេះ ឈ្មោះថា សុញ្ញតានុបស្សនា ព្រោះឃើញដោយអាការ គឺសូន្យចាកពីអត្តា ជាវិមោក្ខមុខ (ផ្លូវនៃសេចក្តីរួចផុត) គឺ ជាទ្វារនៃមគ្គផលដែលជាលោកុត្តរ ពោលគឺ វិមោក្ខដោយអំណាចការផុតចាកធម៌ ដែលជាសិកសត្រូវ ។ សម្ព័ន្ធសេចក្តីថា ៖

អនុបស្សនាដែលប្រព្រឹត្តទៅហើយ ក្នុងសង្ខារទាំងឡាយថា មិនទៀង លែងចោល គឺ លះវិបល្លាសនិមិត្តដែលហៅថា សញ្ញាវិបល្លាស ចិត្តវិបល្លាស និងទិដ្ឋិវិបល្លាសដែលប្រព្រឹត្តទៅហើយក្នុងការមិនទៀងថា ទៀង ដូច្នេះឈ្មោះថា អនិមិត្តានុបស្សនា ព្រោះការតាមឃើញអាការដែលប្រាសចាកនិមិត្ត គឺ វិបល្លាសជាវិមោក្ខមុខ ។

អនុបស្សនាដែលប្រព្រឹត្តទៅហើយថា ជាទុក្ខ ដែលលែងចោលនូវបណិធិ គឺ តណ្ហា បានដល់ សេចក្តីប្រាថ្នា គឺ តណ្ហា ដែលហៅថា កាមតណ្ហា និងភវតណ្ហា ដែលប្រព្រឹត្ត

ទៅក្នុងសង្ខារទាំងឡាយ ដោយន័យជាដើមថា "វត្ថុនេះរបស់យើង សេចក្តីសុខនេះរបស់យើង" គឺ បោះបង់ដោយការឃើញអាការដែលជាទុក្ខ ឈ្មោះថា អប្បណិហិតានុបស្សនា ព្រោះការតាមឃើញអាការដែលវៀរចាកបណិធិ (ការតាំងសេចក្តីប្រាថ្នា) ចាត់ជាវិមោក្ខមុខ ។

## អធិប្បាយ មគ្គ មានឈ្មោះ ៣ យ៉ាង

ពាក្យថា "ព្រោះដូច្នោះ មគ្គ ទើបមានឈ្មោះ ៣ យ៉ាង" អធិប្បាយថា ព្រោះអនុបស្សនាទាំង ៣ នោះ មានអនត្តានុបស្សនាជាដើម ជាឈ្មោះនៃអនុបស្សនាទាំង ៣ ពួកនោះ មានសុញ្ញតានុបស្សនាជាដើម ដូច្នោះ បើវិបស្សនាដែលជាវុដ្ឋានគាមិនី ឃើញច្បាស់ដោយជាអនត្តា មគ្គក៏ជាវិមោក្ខ ឈ្មោះថា សុញ្ញតៈ ព្រោះបានឈ្មោះ ដោយអំណាចធម៌ដែលជាហេតុមក ។

-បទថា **វិបស្សនាគមនវសេន** បានដល់ ដោយអំណាចធម៌ដែលជាហេតុមក ពោលគឺ វិបស្សនា ។ វិបស្សនា និងមគ្គដែលឈ្មោះថា អាគមនា ( ហេតុដែលមក ) ក្នុងទីនេះ ព្រោះអត្ថថា ជាគ្រឿងមករបស់មគ្គនិងផល ។

បទថា **យថាវុត្តនយេន** បានដល់ ដោយអំណាចនៃអនុបស្សនា មានអនត្តានុបស្សនាជាដើម តាមន័យដែលពោលទុកក្នុងកាលមុន ។

ពាក្យថា **យថាសកំ ផលមុប្បជ្ជមានម្បិ** សេចក្ដីថា ផលរបស់ខ្លួន ៗ ដែលជាផលនៃមគ្គតាមដែលបានហើយ សូម្បីកាលកើតឡើង ក៏មិនមានឈ្មោះដោយអំណាចធម៌ដែលជាហេតុមក គឺ មគ្គ រមែងបានឈ្មោះ ៣ យ៉ាង ដោយអំណាចធម៌ ដែលជាហេតុមក គឺ វិបស្សនាប៉ុណ្ណោះ ព្រោះមគ្គនោះ មិនប្រកបដោយភាពជាទ្វារ ក៏ព្រោះក្នុងវេលានោះមិនមានការប្រព្រឹត្តិទៅនៃមគ្គ ។

បទថា **អាលម្ពនវសេន** ដោយអំណាចនៃអារម្មណ៍ សេចក្ដីថា ឈ្មោះទាំង ៣ ដូចគ្នាតែម្ដង ដល់មគ្គនិងផលទាំងអស់ ដោយអំណាចនៃព្រះនិព្វាននោះ ព្រោះប្រារព្ធព្រះនិព្វានប្រព្រឹត្តទៅ គឺ ដែលឈ្មោះសុញ្ញត ព្រោះជាធម្មជាតិ សូន្យចាកពីសង្ខារទាំងពួង, ដែលឈ្មោះថា អនិមិត្តៈ ព្រោះវៀរចាកនិមិត្ត គឺ សង្ខារ, ដែលឈ្មោះថា អប្បណិហិតៈ ព្រោះវៀរចាកសេចក្ដីប្រាថ្នា គឺ តណ្ហា ។

បទថា **សរសវសេន : ដោយអំណាចកិច្ចរបស់ខ្លួន** គឺ ដោយអំណាចនៃគុណរបស់ខ្លួន ព្រោះសូន្យចាកពីកិលេសមានរាគៈជាដើម ព្រោះវៀរចាកអារម្មណ៍ មានរូបនិមិត្តជាដើម និងព្រោះវៀរចាកបណិធិ គឺ កិលេស ។

បទថា **សព្វត្ថាបិ** គឺ វិធីនៃមគ្គ និងក្នុងវិធីនៃផលសមាបត្តិ ។

បទថា **សព្វេសម្បិ** គឺ ទាំងដល់មគ្គ ទាំងដល់ផល ។

## អធិប្បាយ ប្រភេទបុគ្គលនិងសមាបត្តិ

ព្រះសោតាបន្ន ដែលឈ្មោះថា សត្តក្ខត្តុំបរមៈ ព្រោះអត្ថថា កាន់បដិសន្ធិក្នុងសុគតិអស់ ៧ ដង គឺ ៧ វារៈ (ជាតិ)យ៉ាងក្រៃលែង អធិប្បាយថា លោកមិនទៅកាន់ភពទី ៨ ជាដើម(ទៀតឡើយ) ។ ព្រះមានព្រះភាគទ្រង់សំដៅយកព្រះសោតាបន្នបុគ្គលណាទៅហ្ន៎ ទើបទ្រង់ត្រាស់ថា "**ន តេ ភវំ អដ្ឋមមាទិយន្តិ** : អរិយបុគ្គលទាំងនោះ គង់មិនកាន់យកភពជាគម្រប់ ៨"[១] ដូច្នេះ ។

**មោហះ**ស័ព្ទក្នុងបទថា "រាគទោសមោហានំ" គប្បីឃើញថា សំដៅយក មោហៈដែលតាំងនៅក្នុងឋានតែមួយជាមួយរាគៈ និងទោសៈ ។ ព្រះអរិយបុគ្គល ឈ្មោះថា ខីណាស្រព ព្រោះអាសវៈ ៤ របស់លោកអស់ហើយ ។

---

១. ខុទ្ទ. បាឋ. រតនសូត្រ. ៥២. ៧/៩ ។

ព្រះទីណាស្រេព ឈ្មោះថា ជាព្រះទក្ខិណេយ្យបុគ្គលដ៏ប្រសើរ ក្នុងបណ្តាលោកដែលគួរដល់ទក្ខិណាទាំងឡាយ ។

## ប្រភេទសមាបត្តិ

***សមាបត្តិ*** មានវចនត្ថៈថា ***សមាបជ្ជនំ*** = ***សមាបត្តិ*** : ការចូលដល់ ឈ្មោះថា សមាបត្តិ ។ ***និរោធស្ស សមាបត្តិ*** = ***និរោធសមាបត្តិ*** : ( ការចូលដល់សេចក្តីរលត់ ឈ្មោះថា និរោធសមាបត្តិ ) ។

បទថា ***សព្វេសម្បិ*** បានដល់ ព្រះអរិយបុគ្គល សូម្បីទាំង ៤ ពួក ។ ការចូលដល់ការរលត់ ដែលបណ្ឌិតហៅថា ការមិនប្រព្រឹត្តទៅនៃចិត្តនិងចេតសិក ឈ្មោះថា និរោធសមាបត្តិ គឺ ការដល់សេចក្តីរលត់នៃចិត្តហើយ សម្រាកនៅក្នុងបច្ចុប្បន្នទាំះឯង ។

បទថា ***អនាគាមីនញ្ច*** សេចក្តីថា រមែងមានដល់ព្រះ

អនាគាមីអ្នកបានសមាបត្តិ ៨ អ្នកនៅរស់ក្នុងកាមភព និងរូបភពប៉ុណ្ណោះ និងដល់ព្រះខីណាស្រព អ្នកបានសមាបត្តិ ៨ អ្នកនៅក្នុងកាមភព, និងរូបភព យ៉ាងនោះដូចគ្នា ។

បទថា "តត្ថ" គឺ ក្នុងនិរោធសមាបត្តិ ។

ពាក្យថា **ដំណើរទៅដរាបដល់អាកិញ្ចញ្ញាយតនៈ** សេចក្ដីថា ព្រះអរិយបុគ្គលនោះ ដំណើរទៅយ៉ាងរហ័សដរាបដល់អកិញ្ចញ្ញាយតនៈ ដោយការញ៉ាំងសមថៈ និងវិបស្សនាឱ្យដល់ភាពជាធម៌ជាប់ជំពាក់គ្នាជាគូយ៉ាងនេះ ។ ពាក្យថា **មានការអធិដ្ឋាន** ជាដើម បានដល់ ធ្វើបុព្វកិច្ច ៤ យ៉ាងគឺ ៖

**១-នានាពទ្ធអវិកោបនំ** មិនឱ្យវត្ថុផ្សេង ៗ ដែលជាប់គ្នា ខូចខាត, បាត់បង់ ។

**២-សង្ឃបដិមាននំ** ការរង់ចាំរបស់សង្ឃ

**៣-សត្ថុបកោសនំ** ការទទួលតម្រាស់របស់ព្រះសាស្ដា

**៤-អទ្ធានបរិច្ឆេទនំ** ការកំណត់កាលនៃអាយុ

គឺ ការអធិដ្ឋានបរិក្ខារទាំងឡាយ មានចីវរជាដើម ដែលមាននៅជាចំណែក ៗ វៀររបស់ដែលជាប់ដោយកាយ និងទីអាស្រ័យមានផ្ទះ កុដិទីនៅជាដើម មិនឱ្យវិនាសដោយភ្លើង ការចេញមុន ការរង់ចាំរបស់សង្ឃ និងការដែលព្រះសាស្តាត្រាស់ហៅរក ការត្រួតមើលអាយុសង្ខារអាចនៅប្រព្រឹត្តទៅបាន ៧ ថ្ងៃ ។ ក្នុងសង្គហគាថា ពាក្យថា **បដិបត្តិរសស្សាទំ** បានដល់ សេចក្តីត្រេកអររសរបស់ការបដិបត្តិ គឺ សមថៈ និងវិបស្សនា ដែលផ្សេងដោយសេចក្តីសុខ មានសេចក្តីសុខដែលសម្បយុត្តដោយឈាន និងសេចក្តីសុខដែលសម្បយុត្តដោយផលជាដើម ។

**ចប់ អភិធម្មត្ថសង្គហដីកា**

## អវសានគាថានៃបករណ៍

បករណ៍ណា ដែលឧបាសក ឈ្មោះថា នម្ពៈ ដែលកើតក្នុងត្រកូលមហាសាល ល្អស្អាតដោយចរិត ជាអណ្តូងកើតនៃគុណដែលចម្រើនរុងរឿង និងបរិសុទ្ធស្អាតផូរផង់ដោយសទ្ធា ប្រាថ្នាសេចក្តីអនុគ្រោះអ្នកដទៃដោយចេតនាដែលតាំងទុកនោះ បានចប់សព្វគ្រប់ហើយ ។

ក៏ដោយបុណ្យដ៏បរិបូរណ៍នោះ សូមពួកភិក្ខុលជ្ជី ល្អស្អាត ដោយគុណដែលបរិសុទ្ធផូរផង់ដោយបញ្ញា ចូរសំគាល់មូលសោមវិហារ ដែលជាទីនៅរបស់លោកអ្នកមានបុណ្យ និងជាស្ថានទីមានកេរ្តិ៍ឈ្មោះល្បីខ្ទរខ្ទារ សុសសាយទៅ ដើម្បីមង្គល គឺ ការកើតបុញ្ញសម្បត្តិរហូតអស់អាយុកាលនៃព្រះពុទ្ធសាសនាចុះ ។ បករណ៍ ឈ្មោះអភិធម្មត្ថសង្គហៈ ដែលព្រះអនុរុទ្ធាចារ្យរចនាទុកបាកអំពីគន្ថៈ ដែលរៀបរៀងទុក ៨៥០ គម្ពីរ ចប់បរិបូរណ៍ហើយដោយប្រការដូច្នេះ ។

**បរិច្ឆេទទី ៩ កម្មដ្ឋានសង្គហវិភាគ ចប់**

យំ ឯត្ថ វុឌ្ឍិមន្តោ សលក្ខណា បូជិតា បរិច្ឆិន្នា
វុត្តាធិកា ច ធម្មា អភិធម្មោ តេន អក្ខាតោ ។
ព្រោះហេតុដែលធម៌ទាំងឡាយ មានសេចក្តីចម្រើន
មានការកំណត់ ជាធម៌ដែលបុគ្គលបូជាហើយ ជាធម៌
ដែលបណ្ឌិតកាត់ជាចំណែកៗ និងជាធម៌ដ៏ក្រៃលែង
ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ក្នុងព្រះ
អភិធម្មនេះ ដូច្នោះ ទើបលោកពោលថា អភិធម្ម ។



ភិក្ខុ អគ្គធីរោ គង់ សុមិត្ត